ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# សិក្សាសង្គម




# ប្រវត្តិវិទ្យា

៩

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាសង្គម

## ថ្នាក់ទី ៩

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៥៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក អេង វ៉ាត់ | លោក ស្រ៊ុន ណាត្រី |
| | លោក មួង សុផាត | លោកស្រី មាស សុក្ខន |
| | លោក តែម គីមគុន | លោកស្រី បែន នាង |
| **អ្នកវាយអត្ថបទ** | លោក ហៃ វីរៈ | លោក ប៉ាន់ ជាតិ |
| **វិចិត្រករ** | លោក ឡុង សុវណ្ណា | |
| **អ្នករៀបរៀង** | លោក លឹម ហ៊ិន | លោក ខាត់ ធី |
| **រចនាទំព័រ** | លោក គង់ ចិត្រា | |
| **អ្នកឯកទេស** | លោកបណ្ឌិត នៅ ស៊ុន | |
| **គណៈកម្មការពិនិត្យ** | លោកស្រី ប៉ាង ចិន្តា | លោកស្រី ព្រាប សុភួង |
| | លោក ភុក ប៉ាវ | លោកស្រី ស្វាយ ធឿម |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ១៥៤៨ អយក.ប្រក. ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ២០១៦

ISBN 9-789-995-001-339

# អារម្ភកថា

សៀវភៅសិក្សាសង្គមថ្នាក់ទី១ នេះ គណៈកម្មការនិពន្ធបានរៀបចំចងក្រងឡើងដោយផ្អែកលើ កម្មវិធីសិក្សាថ្មី (2009) របស់ក្រសួងអប់រំ យុវជន និងកីឡា ។ នៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាសិក្សាសង្គម មានមុខវិជ្ជារងចំនួនបួន ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា និងគេហវិទ្យា ។

ខ្លឹមសារមេរៀនដែលមានក្នុងសៀវភៅនេះនឹងជួយប្អូនៗឱ្យមានចំណេះដឹងបន្ថែមទៀតទៅលើ ធនធានធម្មជាតិ រ៉ែ តំបន់ទេសចរណ៍ សេដ្ឋកិច្ចប្រទេសរបស់ខ្លួន និងប្រទេសមួយចំនួនក្នុងតំបន់និង បានដឹងពីប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន ប្រទេសក្នុងតំបន់និងលើពិភពលោក ហើយនឹងមានចំណេះ ដឹងបន្ថែមទៀតទៅលើចំណងទាក់ទងជាមួយអ្នកដទៃ និងចំណងទាក់ទងជាមួយសហគមន៍ ពិសេស ទៅទៀតក៏បានដឹងពីវិជ្ជាធ្វើម្ហូប វិជ្ជាកាត់ដេរ ប៉ាក់ និងសម្លៀកបំពាក់ជាដើម ។

គ្រប់មេរៀនដែលមាននៅក្នុងសៀវភៅនេះ គឺមានទម្រង់ដូចៗគ្នាទាំងអស់ដូចជាការកំណត់ វត្ថុបំណងនៃមេរៀនសម្រាប់ឱ្យប្អូនៗដឹងពីអ្វីដែលត្រូវសិក្សាក្នុងមេរៀននីមួយៗ ពិសេសនៅចុងបញ្ចប់ នៃជំពូកនីមួយៗមានតេស្តបញ្ចប់ជំពូក សម្រាប់វាយតម្លៃលើចំណេះដឹងនៅពេលរៀនចប់ជំពូក នីមួយៗ ។ តាមរយៈខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅនេះ ប្អូនៗនឹងទទួលបានចំណេះដឹង បំណិន ឥរិយាបថ ការសង្កេតរូបភាព ការបញ្ចេញមតិយោបល់ ការពិភាក្សាជាដៃគូ ឬជាក្រុម និង តាមការសិក្សាស្រាវជ្រាវជាដើម ។ ជាមួយនេះដែរការរៀបចំសៀវភៅនេះក៏មានការចូលរួមផ្តល់ យោបល់ កែលម្អពីសំណាក់លោកគ្រូ អ្នកគ្រូនៅតាមបណ្តាខេត្តក្រុងមួយចំនួនផងដែរ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅសិក្សាសង្គមថ្នាក់ទី១នេះនឹងក្លាយជាមិត្តដ៏ល្អរបស់ប្អូនៗ សិស្សានុសិស្សជាក់ជាមិនខាន ។ ទន្ទឹមគ្នានោះដែរ គណៈកម្មការនិពន្ធរីករាយនឹងទទួលយករាល់មតិ កែលម្អពីសំណាក់ លោកគ្រូ អ្នកគ្រូ និងគ្រប់មជ្ឈដ្ឋាន ។

គណៈកម្មការនិពន្ធ

## ជំពូក 1 : សង្គ្រាមលោកនិងអង្គការរក្សាសន្តិភាព (ប្រវត្តិវិទ្យា)


1. សង្គ្រាមលោកលើកទី 1 (1914-1918).......82
2. សន្តិភាពនិងសង្គមប្រជាជាតិ.............86
3. សង្គ្រាមលោកលើកទី 2 (1939-1945).......90
4. អង្គការសហប្រជាជាតិ................96
5. សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ASEAN )100


## ជំពូក 2 : ប្រវត្តិសាស្ត្រប្រទេសកម្ពុជា


1. អាណានិគមនិយមបារាំង (1863-1953).....106
2. សម័យសង្គមរាស្ត្រនិយម (1955-1970).....112
3. សម័យសាធារណរដ្ឋខ្មែរ (1970-1975) .....120
4. របបកម្ពុជាប្រជាធិបតេយ្យ (1975-1979) ...124
5. សាធារណរដ្ឋប្រជាមានិតកម្ពុជា-រដ្ឋកម្ពុជា (1979-1991) ព្រះរាជាណាចក្រកម្ពុជា 1993 ....130


## ជំពូក 3 : ប្រវត្តិសាស្ត្រប្រទេសក្នុងតំបន់


1. ប្រទេសឥណ្ឌូណេស៊ី....................140
2. ប្រទេសម៉ាឡេស៊ី......................144
3. ប្រទេសសិង្ហបុរី......................148
4. ប្រទេសថៃ...........................152
5. ប្រទេសវៀតណាម.....................156

# ជំពូកទី 1 សង្គ្រាមលោក និងអង្គការរក្សាសន្តិភាព



សង្គ្រាមលោកលើកទី I

សង្គ្រាមលោកលើកទី I (1914-1918) បានឆាបឆេះរាលដាលពេញពិភពលោកដោយសារតែមហាអំណាចសេដ្ឋកិច្ចលោកខាងលិចប្រកួតប្រជែងគ្នាដណ្តើមដីអាណានិគមសម្រាប់ត្រួតត្រា និងធ្វើជាទីផ្សារឬក៏ទាញយកផលប្រយោជន៍ ជាពិសេសភោគទ្រព្យធម្មជាតិ និងធនធានពីប្រទេសដែលស្ថិតនៅក្រោមអាណានិគមទាំងនោះ ។ ទាំងនេះជាកត្តាចម្បងដែលធ្វើឱ្យសង្គ្រាមលោកលើកទី I បំផ្លាញអាយុជីវិតមនុស្សរាប់លាននាក់ បំផ្លាញទ្រព្យសម្បត្តិនិងហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសសេចក្តីសុខសាន្តនិងការអភិវឌ្ឍរបស់ពិភពលោក ។ ពិភពលោកត្រូវការសន្តិភាព សេរីភាព និងការអភិវឌ្ឍ ។

# 1 សង្គ្រាមលោកលើកទី១ (១៩១៤_១៩១៨)

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីបុព្វហេតុនៃសង្គ្រាមលោកលើកទី ١
- ពន្យល់ពីផលវិបាកនៃសង្គ្រាមលោកលើកទី ١
- បណ្ដុះស្មារតីស្រឡាញ់សន្តិភាពនិងការអភិវឌ្ឍសង្គម ។

## 1. មូលហេតុនៃសង្គ្រាម

នៅដើមសតវត្សទី 20 ប្រទេសមហាអំណាចឧស្សាហកម្មនៅទ្វីបអឺរ៉ុបជាច្រើនមានបញ្ហាតានតឹងកាន់តែធ្ងន់ធ្ងរឡើងៗដោយសារតម្រូវការឧស្សាហកម្ម និងចំណែងចែកដែនដីអាណានិគមមិនស្មើគ្នា ។ ប្រទេសអង់គ្លេសជាចក្រពត្តិចាស់តែកម្លាំងសេដ្ឋកិច្ចមិនសូវរីកចម្រើន តែមានទឹកដីអាណានិគមច្រើន ចំណែកប្រទេសអាល្លឺម៉ង់ជាប្រទេសចក្រពត្តិក្មេងខ្ចី កម្លាំងសេដ្ឋកិច្ចមានសន្ទុះរីកលូតលាស់ឆាប់រហ័ស ប៉ុន្តែមានទឹកដីអាណានិគមតិច ទើបប្រទេសអាល្លឺម៉ង់មានបំណងធ្វើការបែងចែកពិភពលោកសារជាថ្មី ។

ប្រទេសអង់គ្លេសបានស្នើសុំលុបការវិវាទចាស់ៗជាមួយប្រទេសបារាំងនិងប្រទេសរុស្ស៊ី តាមរយៈការតាមសង្កត់ពីប្រទេសអាល្លឺម៉ង់ ។ ចំណែកប្រទេសបារាំងវិញមានការព្រួយបារម្ភយ៉ាងខ្លាំងពីការគំរាមកំហែងរបស់អាល្លឺម៉ង់ ព្រោះប្រទេសនេះមានទឹកដីអាណានិគមជាច្រើនកន្លែងបន្ទាប់ពីអង់គ្លេស ។ បារាំងចង់ទាមទារខេត្ត 2 របស់ខ្លួនគឺ អាល់សាស់ និងឡូរ៉ែន រួមទាំងចង់បានតំបន់សម្បូរធ្យូងមួយទៀតគឺតំបន់សារដែលស្ថិតនៅព្រំប្រទល់ប្រទេសបារាំង និងអាល្លឺម៉ង់ ។ ប្រទេសរុស្ស៊ីវិញមានការព្រួយបារម្ភចំពោះការជ្រៀតជ្រែករបស់ប្រទេសអាល្លឺម៉ង់ដោយមានគម្រោងស្ថាបនាផ្លូវរថភ្លើងមួយខ្សែ ។ ប្រការនេះអាចជាការគំរាមកំហែងទៅលើតំបន់ កូកាស និងសមុទ្រខ្មៅរបស់រុស្ស៊ី ។

## 2. បុព្វហេតុនៃសង្គ្រាមលោកលើកទី1

នៅថ្ងៃទី 28 មិថុនា 1914 ព្រះអង្គម្ចាស់ ហ្វ្រង់ស្វ័រហ្វឺឌីណង់ ដែលជារជ្ជទាយាទនៃប្រទេសអូទ្រីស-ហុងគ្រីត្រូវនិស្សិតសញ្ជាតិ ស៊ែប៊ីធ្វើឃាតនៅក្រុង សេរ៉ាស្សីវូ(Serajivo) ។ ប្រទេសអូទ្រីស-ហុងគ្រីយកលេសនេះក៏បានប្រកាសសង្គ្រាមជាមួយប្រទេសស៊ែប៊ីភ្លាមនៅថ្ងៃទី 28 កក្កដា 1914 ចំណែករុស្ស៊ីមិនអាចនៅស្ងៀមបានក៏ប្រកាសថាខ្លួននឹងគាំទ្រប្រទេសស៊ែប៊ីដោយមិនបណ្តោយឱ្យប្រទេសអូទ្រីស-ហុងគ្រីសម្លាប់សម្ព័ន្ធមិត្តរបស់ខ្លួន ។

ប្រទេសអាល្លឺម៉ង់បានប្រកាសសង្គ្រាមជាមួយរុស្ស៊ីនៅថ្ងៃទី 01 សីហា1914 ។ លុះដល់ថ្ងៃទី 03 សីហា 1914 ប្រទេសអាល្លឺម៉ង់បានប្រកាសសង្គ្រាមជាមួយបារាំងទៀត ។

ថ្ងៃទី 04 សីហា 1914 ប្រទេសអង់គ្លេសបានប្រកាសសង្គ្រាមជាមួយអាល្លឺម៉ង់ បន្ទាប់ពីអាល្លឺម៉ង់វាយលុកឆ្លងកាត់ប្រទេសបែលហ្ស៊ិក ។ មហាសង្គ្រាមមួយដែលគេទំនាំគ្នាបញ្ចៀសតាំងពីយូរនោះបានចាប់ផ្តើមផ្ទុះឡើងដោយមានរយៈពេល 4 ឆ្នាំ ចាប់ពីខែ សីហា 1914 ដល់ខែ វិច្ឆិកា 1918 ។



*ការធ្វើឃាតព្រះអង្គម្ចាស់ហ្វ្រង់ស្វ័រហ្វឺឌីណង់*

## 3. ប្រទេសចូលរួមក្នុងចម្បាំង

ចាប់ផ្តើមដំបូង សង្គ្រាមនេះមានលក្ខណៈជាចម្បាំងក្នុងទ្វីបអឺរ៉ុបតែប៉ុណ្ណោះ ក្រោយមកចម្បាំងនេះបានរីករាលដាលពេញពិភពលោកដោយមានប្រទេសផ្សេងៗទៀតបានចូលរួមជាបន្តបន្ទាប់ក្នុងប្លុកទាំង 2 ជាហេតុនាំឱ្យចម្បាំងនេះប្រែក្លាយទៅជាសង្គ្រាមលោក ។

- ប្លុកទី 1 គេហៅថាសម្ព័ន្ធត្រីភាគីមាន ប្រទេសអាល្លឺម៉ង់ អូទ្រីស-ហុងគ្រី ក្រោយមកមាន តួកគី ប៊ុលហ្គារី(តុលា 1915) ។
- ប្លុកទី 2 គេហៅថាអនុសញ្ញាត្រីភាគីមាន ប្រទេសបារាំង អង់គ្លេស រុស្ស៊ី ក្រោយមកមាន បែលហ្ស៊ិក ស៊ែប៊ី អ៊ីតាលី ជប៉ុន ក្រិក រូម៉ានី សហរដ្ឋអាមេរិក ។

## 4. ការវាយប្រយុទ្ធគ្នា

គេចែកចម្បាំងនេះជា 3 ដំណាក់កាលសំខាន់ៗដូចតទៅ ៖

### 4.1. ដំណាក់កាលទី1

ការវាយលុករបស់ប្រទេសអាល្លឺម៉ង់បានប្រព្រឹត្តទៅអស់រយៈពេល 4 ខែ (សីហា-វិច្ឆិកា 1914) ប្រទេសអាល្លឺម៉ង់បានទុកចិត្តលើឧត្តមភាពនៃកងទ័ព គ្រឿងអាវុធយុទ្ធភណ្ឌ និងលើល្បិចកលរបស់ខ្លួន

ហើយសង្ឃឹមថានឹងទទួលបានជោគជ័យយ៉ាងឆាប់រហ័ស ។ តែការចាំន់ស្មានរបស់ប្រទេសអាល្លឺម៉ង់មិនបានសម្រេចដូចអ្វីដែលខ្លួនបានគ្រោងទុកឡើយ កងទ័ពអាល្លឺម៉ង់ត្រូវកងទ័ពបារាំងវាយបញ្ឈប់ក្នុងសមរភូមិទន្លេម៉ាន(Marne)នៅថ្ងៃទី 17 ខែវិច្ឆិកា 1914 ។ នៅដំណាច់ឆ្នាំ 1914 លទ្ធផលទទួលបានមាន ៖

- ប្រទេសអាល្លឺម៉ង់វាយយកបានប្រទេសប៊ែលហ្សិកទាំងមូល បារាំងមួយផ្នែក ប៉ូឡូញមួយផ្នែក ។
- ប្រទេសរុស្ស៊ីដែលជាសម្ព័ន្ធមិត្តបារាំងវាយយកបានប្រទេសអូទ្រីស និងមួយផ្នែកនៃប្រទេសព្រុស (Prusse) ។

ដូចនេះ ឆ្នាំ 1914 កន្លងទៅ ប្រទេសអាល្លឺម៉ង់ដែលប៉ុនប៉ងកម្ទេចប្រទេសបារាំងតែក្នុង 3 ឬ 4 សប្តាហ៍នោះបែរជាបរាជ័យទៅវិញ ។

## 4.2. ដំណាក់កាលទី 2 : ចម្បាំងក្នុងលេណដ្ឋាន

បន្ទាប់ពីការប្រយុទ្ធគ្នាយ៉ាងសាហាវក្នុងដំណាក់កាលទី 1 របស់កងទ័ពអាល្លឺម៉ង់នៅឆ្នាំ 1914 មកដំណាក់កាលទី 2 បានចាប់ផ្តើមឡើងគឺ "ចម្បាំងចំហ" ។ កងទ័ពទាំងសងខាងបានជីករណ្តៅទល់មុខគ្នាប្រវែង 780km ចាប់ពីសមុទ្រខាងជើងមកទល់ និងប្រទេសស្វីស រួចបានត្រៀមខ្លួនក្នុងលេណដ្ឋានរហូតដល់ឆ្នាំ 1917 ។ ចាប់ពីឆ្នាំ 1915-1917 ការប្រយុទ្ធគ្នាមានភាពសាហាវព្រៃផ្សៃ ។ គ្រប់មធ្យោបាយថ្មីៗត្រូវបានយកមកប្រើទាំងសងខាងដូចជា កាំភ្លើងធំ យន្តហោះ ផ្សែងឈ្មក់ រថក្រោះ នាវាមុជទឹក ... ។ នៅឆ្នាំ 1916 ការប្រយុទ្ធគ្នានៅវែរដង់(Verdan)ភាគីទាំងសងខាងបានប្រយុទ្ធគ្នាទាំងយប់ទាំងថ្ងៃអស់រយៈពេល 5 ខែ ។ នៅខែ កក្កដា ឆ្នាំ 1916 ការប្រយុទ្ធនេះបានបញ្ចប់ជាមួយនឹងបរាជ័យយ៉ាងធ្ងន់ធ្ងរនៃកងទ័ពអាល្លឺម៉ង់ ។ រួមទាំងកងទ័ពអាល្លឺម៉ង់និងបារាំងមានមនុស្សស្លាប់អស់ចំនួន 700 000 នាក់ ។

## 4.3. ដំណាក់កាលទី 3

នៅដើមឆ្នាំ 1918 ការវាយលុករបស់ភាគីសម្ព័ន្ធមិត្ត និងការខំប្រឹងប្រែងរបស់កងទ័ពអាល្លឺម៉ង់ពុំបានទទួលលទ្ធផលអ្វីជាធំដុំឡើយ ។ កងទ័ពអាល្លឺម៉ង់បានវាយទម្លុះកងទ័ពសម្ព័ន្ធមិត្តជាច្រើនលើក ៖

- លើកទី 1 (ខែមីនា-ឧសភា 1918)នៅភូមិភាគពីកាឌីប្លង់ និងអែស ប៉ុន្តែឧត្តមសេនីយ៍ ហ្វុក បានស្រោចស្រង់ស្ថានការណ៍នេះដោយវាយកម្ចាត់កងទ័ពអាល្លឺម៉ង់ចេញពីសមរភូមិ ។
- លើកទី 2 (ថ្ងៃទី 15-18 កក្កដា 1918)នៅសមរភូមិទន្លេម៉ាន ។ ថ្ងៃទី 08 ខែសីហាឆ្នាំ 1918 ឧត្តមសេនីយ៍ ហ្វុក ត្រូវបានតែងតាំងជាមេបញ្ជាការលើទ័ពសម្ព័ន្ធមិត្តទាំងអស់រួមមាន បារាំង អង់គ្លេស សហរដ្ឋអាមេរិកជាដើម ។ បន្ទាប់មក គ្រប់សមរភូមិបើកការវាយប្រយុទ្ធគ្រប់មុខព្រួញ ដោយពុំអាចទប់ទល់តទៅទៀតបាន ប្រទេសអាល្លឺម៉ង់ត្រូវចុះហត្ថលេខាលើយុទ្ធសន្តិភាពនៅថ្ងៃទី 11 ខែវិច្ឆិកា ឆ្នាំ 1918 ហើយសង្គ្រាមលោកលើកទី 1 ក៏បានបញ្ចប់ដែរ ។

## 5. សន្ធិសញ្ញាបញ្ចប់សង្គ្រាម

- សន្និសីទក្រុងប៉ារីសបានប្រព្រឹត្តទៅចាប់ពីខែ មករា ដល់មិថុនា 1919 ដោយមានប្រទេសចំនួន 32 បានចូលរួម ។ សេចក្តីសម្រេចផ្សេងៗធ្វើឡើងដោយក្រុមចតុភាគីមាន(សហរដ្ឋអាមេរិក អង់គ្លេស បារាំង អ៊ីតាលី) ។ ក្រុមប្រឹក្សានេះផ្តោតទៅលើការបែងចែកដែនទីទ្វីបអឺរ៉ុបតាមឆន្ទៈប្រជាជននិងការបង្កើតសង្គមប្រជាជាតិដើម្បីរក្សាសន្តិភាព ។
- សន្ធិសញ្ញាទីក្រុងវែរសៃ(Versailles)ចុះហត្ថលេខាដោយប្រទេសអាល្លឺម៉ង់នៅថ្ងៃទី 28 ខែមិថុនា ឆ្នាំ 1919 ដែលមាន 27 ប្រទេសចូលរួម ។ សន្ធិសញ្ញាចែងពី ៖

### 5.1. បញ្ហាទឹកដី

អាល្លឺម៉ង់ត្រូវប្រគល់ទឹកដីអាល់សាស និងឡូរ៉ែន(Alsace Lorraine)ឱ្យបារាំងវិញ ។ អាល្លឺម៉ង់ត្រូវប្រគល់ប៉ូសណានីឱ្យប៉ូឡូញហើយអាណានិគមរបស់អាល្លឺម៉ង់នៅអាហ្វ្រិក និងប៉ាស៊ីហ្វិកត្រូវដាក់ក្រោមអាណត្តិ(Mandat)របស់អង់គ្លេស ។ ចំណែកតំបន់សារត្រូវស្ថិតក្រោមការត្រួតត្រារបស់សង្គមប្រជាជាតិ ។ តំបន់ច្រាំងខាងឆ្វេងទន្លេរ៉ាំងស្ថិតក្រោមការត្រួតត្រារបស់សម្ព័ន្ធមិត្តរយៈពេល 15 ឆ្នាំ ។

### 5.2. បញ្ហាសេដ្ឋកិច្ច

អាល្លឺម៉ង់ត្រូវសងការខូចខាតនិងជួសជុលចំនួន 33 ពាន់លានដុល្លារ ។

### 5.3. បញ្ហាកងទ័ព

អាល្លឺម៉ង់ត្រូវកាត់បន្ថយកងទ័ពមកនៅត្រឹម 10 ម៉ឺននាក់ ។

## 6. ផលវិបាកនៃសង្គ្រាមលោកលើកទី1

សង្គ្រាមលោកលើកទី 1 (1914-1918) ជាសង្គ្រាមលោកមានទំហំធំដែលគេមិនដែលជួបប្រទះ ហើយសង្គ្រាមបានអូសទាញប្រទេសចំនួន 33 ដែលមានប្រជាជន 1500 លាននាក់នៅគ្រប់ទិសទីឱ្យធ្លាក់ក្នុងគ្រោះមហន្តរាយ និងវិនាសកម្ម ។

សង្គ្រាមនេះផ្ទុះឡើងបណ្តាលឱ្យខូចខាតសម្ភារៈ ផ្ទះសំបែង រោងចក្រ ផ្លូវគមនាគមន៍ សាលារៀន និងធ្វើឱ្យមនុស្សស្លាប់ប្រហែល 10 លាននាក់របួសប្រហែល 20 លាននាក់ ។

**? សំណួរ**

1. តើមូលហេតុអ្វីខ្លះដែលនាំឱ្យមានសង្គ្រាមលោកលើកទី 1 ?
2. តើប្លុកទី 1 និងទី 2 មានប្រទេសណាខ្លះបានចូលរួម ?
3. ចូររៀបរាប់ពីផលវិបាកនៃសង្គ្រាមលោកលើកទី 1 ។

# 2 សន្តិភាពនិងសង្គមប្រជាជាតិ

**ចប់មេរៀននេះ សិស្សអាច**

- អធិប្បាយពីលទ្ធផលនៃសង្គ្រាម សន្ធិសញ្ញាសន្តិភាព និងការបង្កើតសង្គមប្រជាជាតិ
- រៀបរាប់ពីស្ថាប័នអន្តរជាតិ
- ស្រឡាញ់សន្តិភាពនិងគាំទ្រការបង្កើតសង្គមប្រជាជាតិ ។

តាមការសម្គាល់ ក្នុងពេលមានសង្គ្រាមរ៉ាំរ៉ៃ ពួកមនុស្សដែលកំពុងច្បាំងគ្នា តែងប្រាថ្នាសូមឱ្យជាសង្គ្រាមចុងក្រោយបំផុតសម្រាប់ពួកគេ និងសូមឱ្យមានសន្តិភាពជាដរាបតទៅ ។

## 1. លទ្ធផលនៃសង្គ្រាមលោកលើកទី1 និងការធ្លាក់ចុះនៃប្រទេសអឺរ៉ុប

ចំនួនមនុស្សស្លាប់នៅអឺរ៉ុបកើនដល់ប្រហែល ១លាននាក់ ។ ចំនួនបាត់បង់នេះ ធ្វើឱ្យមានឱនភាពនៃអត្រាកំណើត ព្រោះអ្នកបាត់បង់ជីវិតសុទ្ធតែជាយុវវ័យ និងមជ្ឈិមវ័យដែលពោរពេញដោយថាមពលក្នុងសកម្មភាពផ្នែកសេដ្ឋកិច្ច ។ មិនតែប៉ុណ្ណោះ បញ្ហាក្មេងកំព្រា និងជនពិការជាបន្ទុកយ៉ាងធ្ងន់សម្រាប់រដ្ឋបន្ថែមទៀត ។ មហន្តរាយខាងផ្នែកសម្ភារៈ បំផ្លាញដល់រោងចក្រទាំងឡាយ ដីធ្លី ផ្ទះសំបែងយ៉ាងច្រើនសម្បើម ។ រោងចក្រសហគ្រាសទាំងនោះត្រូវការស្តារ និងកសាងជាថ្មីឡើងវិញ ។ វិបត្តិហិរញ្ញវត្ថុ ប្រទេសជាច្រើនបានជំពាក់បំណុលគេ ហើយត្រូវប្រឈមមុខនឹងវិបត្តិអតិផរណា ។ នៅទីបំផុត វិបត្តិផ្លូវចិត្តអំពើកេងប្រវ័ញ្ច សេចក្តីភ័យខ្លាច ភាពល្វីងជូរចត់នៃជនរងគ្រោះទាំងឡាយដោយសារសង្គ្រាមជាបន្ទុកដែលត្រូវដោះស្រាយនៅចំពោះមុខអតិផរណា និងជោគជ័យនៃពួកនិកាសនិយម ។

ផ្ទុយទៅវិញ ប្រទេសមួយចំនួនដែលនៅខាងក្រៅទ្វីបអឺរ៉ុបឆ្លៀតឱកាសទាញយកផលប្រយោជន៍ពីសង្គ្រាម ក្លាយជាប្រទេសឧស្សាហកម្មដូចជា កាណាដា អាហ្សង់ទីន ប្រេស៊ីល ជប៉ុន សហរដ្ឋអាមេរិក ។ សហរដ្ឋអាមេរិកធ្លាប់ជាកូនបំណុលនៃប្រទេសនៅអឺរ៉ុបក្នុងឆ្នាំ 1914 បានក្លាយជាប្រទេសម្ចាស់បំណុលក្នុងពិភពលោក ហើយជាអ្នកក្តាប់ទុកពាក់កណ្តាលនៃចំនួនមាសទាំងអស់ដែលស្តុកទុក ។ ប្រទេសនៅអឺរ៉ុបត្រូវបាត់បង់ឧត្តមភាពសេដ្ឋកិច្ចដោយសារសង្គ្រាមលោកនេះ ។

# 2. សន្ធិសញ្ញាសន្តិភាពនានា

## 2.1. ចំណុច 14 ខ របស់លោកវិលសុន

ថ្ងៃទី 8 ខែមករា ឆ្នាំ 1918 លោកវិលសុន(Wilson) ប្រធានាធិបតីសហរដ្ឋអាមេរិក(1913-1921) បានធ្វើសន្ទរកថាដោយប្រកាសនូវចំណុច 14ខរបស់លោក ដែលជាមូលដ្ឋានគ្រឹះនៃការងារសន្តិភាព ដូចជា :

1. អនុសញ្ញាទាំងឡាយនៃសន្តិភាពសាធារណៈ
2. សេរីភាពនៃដែនសមុទ្រទាំងឡាយ
3. ការលុបចោលនូវរបាំងគយទាំងឡាយ
4. ការកាត់បន្ថយគ្រឿងសព្វាវុធ
5. បទបញ្ជានៃការទាមទារទាំងឡាយដែលឈរលើផលប្រយោជន៍ប្រជាជន
6. ការចាកចេញពីទឹកដីរុស្ស៊ីហើយនិងសេរីភាពនៃការជឿនលឿនរបស់ប្រទេស
7. ការជួសជុលប្រទេសបែលហ្ស៊ិក
8. អាល់សាសនិងឡូរ៉ែនជាទឹកដីរបស់ប្រទេសបារាំង
9. ព្រំប្រទល់របស់ប្រទេសអ៊ីតាលីដោយពាក់ព័ន្ធទៅនឹងសញ្ជាតិនានា
10. ស្វ័យភាពនៃជនជាតិអូទ្រីស-ហុងគ្រី
11. ផ្លូវចូលទៅកាន់សមុទ្រនៃប្រទេសស៊ែប៊ី
12. ចក្រភពអូតូម៉ង់កំណត់ប្រទេសតួកគី ។ សេរីភាពនៃច្រកសមុទ្រទាំងឡាយ
13. សេរីភាពនៃការចូលដោយសេរីទៅក្នុងសមុទ្ររបស់ប្រទេសប៉ូឡូញ
14. ការបង្កើតសង្គមប្រជាជាតិមួយ ។

## 2.2. សន្ធិសញ្ញាសន្តិភាព

ដោយភ័យខ្លាចការវាយលុកនានាពីសំណាក់កងទ័ពសម្ព័ន្ធមិត្តមកលើពួកខ្លួនដែលកំពុងចុះខ្សោយ អាល្លឺម៉ង់ត្រូវទទួលចុះហត្ថលេខាលើយុទ្ធសន្តិភាពមួយនៅថ្ងៃទី 11 ខែវិច្ឆិកា ឆ្នាំ 1918 ។

ថ្ងៃទី 18 ខែមករា ឆ្នាំ 1919 សន្និសីទមួយបានបើកសម័យប្រជុំនៅទីក្រុងប៉ារីសដើម្បីរៀបចំសន្ធិសញ្ញាសន្តិភាពមួយ ដែលមានប្រទេសមួយចំនួនបានចូលរួមផង ។ សន្និសីទនេះដឹកនាំដោយមនុស្សសំខាន់ 4រូប មានលោកវិលសុន Wilson (ស.រ.អា) ក្លេម៉ង់សូ Clémenceau (បារាំង) ឡូតហ្សក Lord George (រាជាណាចក្ររួម) និងលោក អរឡង់ដូ Orlando (អ៊ីតាលី) ។ ចំណែកប្រទេសដែលចាញ់សង្គ្រាម មិនអាចចូលរួមរៀបចំសេចក្តីសម្រេចនានានៃសន្និសីទនេះបានឡើយ ។

នៅថ្ងៃទី 28 ខែមិថុនា ឆ្នាំ 1919 សន្ធិសញ្ញាវែរសៃប្រព្រឹត្តទៅរវាងប្រទេសបារាំងជាមួយសម្ព័ន្ធមិត្តរបស់ខ្លួន និងអាល្លឺម៉ង់។ តាមសន្ធិសញ្ញានេះ អាល្លឺម៉ង់ត្រូវលះបង់ចោលដែនដីអាណានិគមរបស់ខ្លួនទាំងអស់។ តំបន់អាល់សាស ឡូរ៉ែន ប្រគល់ឱ្យបារាំង រដ្ឋប៉ូស្នាន(Posnan) ត្រូវប្រគល់ឱ្យប្រទេសប៉ូឡូញវិញ។ ទឹកដីអាល្លឺម៉ង់ 15%ត្រូវពុះបំបែកជាពីរផ្នែក។ កងទ័ពរបស់អាល្លឺម៉ង់ត្រូវកម្រិតឱ្យនៅត្រឹមចំនួន 100 000នាក់ ដោយគ្មានរទេះតង់ និងគ្មានយន្តហោះ។ តំបន់ត្រើយខាងឆ្វេង និងត្រើយខាងស្តាំមួយផ្នែកនៃ ទន្លេរ៉ាំង(Rhin)ត្រូវហាមឃាត់គ្រប់ការរៀបចំបំពាក់សម្ភារៈសឹក។

សន្ធិសញ្ញាវែរសៃត្រូវបានបង្គ្រប់ដោយ :

- សន្ធិសញ្ញាសាំងហ្ស៊ែម៉ាំង(Saint Germain)ជាមួយនឹងអូទ្រីសនៅថ្ងៃ 10 ខែកញ្ញា ឆ្នាំ 1919
- សន្ធិសញ្ញាណើយី(Neuilly)ជាមួយប៊ុលហ្គារីនៅខែ ខែវិច្ឆិកា ឆ្នាំ 1919
- សន្ធិសញ្ញាទ្រីយ៉ាណុង(Trianon)ជាមួយនឹងហុងគ្រីនៅថ្ងៃ 4 ខែមិថុនា ឆ្នាំ 1920
- សន្ធិសញ្ញានៅក្រុងសែវ(Sevres)ជាមួយប្រទេសតួកគីនៅថ្ងៃទី 10 ខែសីហា ឆ្នាំ 1920
- សន្ធិសញ្ញាសន្តិភាពទាំងប៉ុន្មានខាងលើនេះបានបែងចែកប្រទេសអូទ្រីស ប្រទេសហុងគ្រី និងប្រទេសតួកគី ព្រមទាំងបង្កើតរដ្ឋយូហ្គោស្លាវី និងឆេកូស្លូវ៉ាគី។

## 3. ការបង្កើតសង្គមប្រជាជាតិ



*សមាជិកអចិន្ត្រៃយ៍នៃសង្គមប្រជាជាតិ*

លោក វូឌ្រូ វីលសុន ប្រធានាធិបតីអាមេរិក ស្ថាបនិកសន្តិភាពបានផ្ដើមគំនិតបង្កើតសង្គមប្រជាជាតិមួយដើម្បីចៀសវាងចម្បាំងជាថ្មីទៀត ។

អត្ថបទគោលការណ៍នៃសង្គមប្រជាជាតិត្រូវបានយល់ព្រមទទួលយកជាផ្លូវការនៅថ្ងៃទី 29 ខែមេសា ឆ្នាំ 1919 ។ ក្នុងបទបញ្ញត្តិនៃគោលការណ៍សង្គមប្រជាជាតិនេះ រដ្ឋទាំងឡាយសន្យាថានឹងត្រូវបន្ថយសព្វាវុធ ត្រូវបញ្ជូនការវិវាទរបស់ខ្លួនឱ្យតុលាការអន្តរជាតិជំនុំជម្រះ ហើយមិនត្រូវប្រើកម្លាំងដើម្បីដោះស្រាយការវិវាទរបស់ខ្លួន មុនរយៈពេល 3ខែក្រោយពីតុលាការបានវិនិច្ឆ័យឡើយ ។

សង្គមប្រជាជាតិមានទីស្នាក់ការនៅទីក្រុងហ្សឺណែវ ។ សង្គមប្រជាជាតិមានអង្គការផ្សេងៗជាច្រើនដូចជា :

- មហាសន្និបាតដែលនៅក្នុងនោះគ្រប់ប្រទេសជាសមាជិកមិនថាធំ ឬតូច ត្រូវមានមួយសំឡេងដូចគ្នាក្នុងការពិភាក្សាដោះស្រាយបញ្ហាផ្សេងៗ ។
- ក្រុមអភិបាលមួយដែលមានសមាជិក 9រូប ជាសមាជិកអចិន្ត្រៃយ៍ 5រូបជាតំណាងមហាអំណាចទាំង 5 សមាជិក 4រូបទៀតត្រូវជ្រើសរើសរៀងរាល់ឆ្នាំដោយមហាសន្និបាត ។
- ការិយាល័យអចិន្ត្រៃយ៍មួយ
- តុលាការអន្តរជាតិមួយសម្រាប់ជំនុំជម្រះអធិករណ៍រវាងប្រជាជាតិមានទីស្នាក់ការនៅទីក្រុងឡាអេ(ហូឡង់) ។
- ការិយាល័យអន្តរជាតិគ្រប់ជំពូកស្ថិតនៅក្រោមអំណាចសង្គមប្រជាជាតិ ។

សង្គមប្រជាជាតិគ្មានកម្លាំងនិងមធ្យោបាយគ្រប់គ្រាន់ដើម្បីធានាសន្តិសុខអន្តរជាតិឡើយ គឺមានតែកម្លាំងខាងផ្លូវចិត្តតែប៉ុណ្ណោះ ។ ក្នុងករណីនេះ សង្គមប្រជាជាតិមិនអាចរារាំងផ្លូវចម្បាំងបានឡើយ ។ ពិភពលោកមានសន្តិភាពមួយខណៈពេលរហូតដល់ឆ្នាំ 1939 ពួកហ្វាស៊ីសនិយមអាល្លឺម៉ង់បានបង្កសង្គ្រាមលោកលើកទី 2ម្តងទៀត ។

## ? សំណួរ

1. តើលោកវិលសុនបង្កើតចំណុច 14ខនៅពេលណា ? ដើម្បីអ្វី ?
2. តើសន្និសីទដើម្បីសន្តិភាពនៅទីក្រុងប៉ារីសកើតឡើងនៅពេលណា ? ដោយសារអ្វី ?
3. តើមេដឹកនាំសន្និសីទដើម្បីសន្តិភាពនេះមានអ្នកណាខ្លះ ? ហើយប្រទេសដែលចាញ់សង្គ្រាមបានចូលរួមប្រជុំដែរឬទេ ? ព្រោះអ្វី ?
4. តើមានសន្ធិសញ្ញាអ្វីទៀតដែរឬទេ ?
5. តើសង្គមប្រជាជាតិជាអ្វី ? តើអ្នកពេញចិត្តចំពោះការបង្កើតអង្គការអន្តរជាតិនេះឬទេ ? ព្រោះអ្វី ?

# 3 សង្គ្រាមលោកលើកទី២ (១៩៣៩_១៩៤៥)

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីមូលហេតុនាំឱ្យកើតសង្គ្រាមលោកលើកទី 2
- បង្ហាញពីផលវិបាកនៃសង្គ្រាម
- បណ្តុះស្មារតីស្រឡាញ់សន្តិភាពនិងការអភិវឌ្ឍ ។

សង្គ្រាមលោកលើកទី 2 ពីឆ្នាំ 1939 ដល់ 1945 បានធ្វើឱ្យមនុស្សជាតិស្គាល់ការខូចខាតឥតគណនា ។ នេះជាលទ្ធផលនៃមហិច្ឆតារបស់ពួកហ្វាស៊ីសអ៊ីតាលី ណាស៊ីអាល្លឺម៉ង់ និងយោធានិយមជប៉ុនដែលចង់ត្រួតត្រាពិភពលោក ។

## 1. មូលហេតុនៃសង្គ្រាម

មូលហេតុសំខាន់ៗដែលនាំឱ្យមានមហាសង្គ្រាមលោកផ្ទុះឡើងមាន 3 ចំណុចសំខាន់គឺ

### 1.1. បញ្ហាសេដ្ឋកិច្ច

ស្ថានភាពសេដ្ឋកិច្ចអាល្លឺម៉ង់បានរីកលូតលាស់យ៉ាងឆាប់រហ័ស ។ នៅមុនសង្គ្រាម ប្រទេសអាល្លឺម៉ង់បានក្លាយទៅជាមហាអំណាចសេដ្ឋកិច្ចមួយយ៉ាងរឹងមាំក្នុងចំណោមបណ្តាប្រទេសនៅអឺរ៉ុប ។

ប្រទេសអាល្លឺម៉ង់ស្វែងរកទីផ្សារ (ពិភពលោក) សម្រាប់លក់ផលិតផលឧស្សាហកម្មរបស់ខ្លួនដោយលំបាក ដូច្នេះពួកគេមានបំណងដណ្តើមយកទីផ្សារពីមហាអំណាចអាណានិគមនិយមអង់គ្លេស បារាំង សហរដ្ឋអាមេរិក នៅអាស៊ី និងអាហ្វ្រិក ។ មហិច្ឆតានេះពើបប្រទះនិងការទប់ទល់សងវិញយ៉ាងខ្លាំងក្លាពីមហាអំណាចទាំងនោះ ។

### 1.2. បញ្ហានយោបាយ

ក្រោយការឡើងកាន់អំណាច អ៊ីត្លែបានបង្កើតកម្មវិធីនយោបាយរបស់គណបក្សសង្គមជាតិនិយម ឬណាស៊ី (Nazi) ដូចជា ៖

- ធ្វើឱ្យសាសន៍អាល្លឺម៉ង់មានឈាមបរិសុទ្ធ ហើយខ្លាំងពូកែ

- បណ្ដុះមនោសញ្ចេតនាស្នេហាសង្គមនិងប្រពៃណីរបស់ជនជាតិអាល្លឺម៉ង់
- ប្រមូលផ្ដុំជនជាតិអាល្លឺម៉ង់ទាំងអស់ដោយមានមេដឹកនាំតែម្នាក់
- ហែកសន្ធិសញ្ញាក្រុងវែរសៃចោល (Versailles) ដើម្បីសម្រេចនយោបាយត្រួតត្រាពិភពលោកទាំងមូលនិងការសម្រេចកម្មវិធីនយោបាយខាងលើ ។ ការដាក់ចេញកម្មវិធីនេះបានធ្វើឱ្យមានផលប៉ះពាល់ជាច្រើនចំពោះសន្តិភាពពិភពលោក ពិសេសត្រង់ចំណុចចុងក្រោយបង្អស់ ។

### 1.3. បញ្ហាយោធា

បក្សណាស៊ីអ៊ីទ្លែបានសមគំនិតឃុបឃិតគ្នាជាមួយមហាអំណាចចក្រពត្តិនិយមបស្ចិមប្រទេសផង និងស្ដាបនាឧស្សាហកម្មសឹកមួយយ៉ាងធំផងដើម្បីសម្រេចបំណងត្រួតត្រាពិភពលោកទាំងមូល ។ ក្នុងរយៈពេលមួយដ៏ខ្លី កងទ័ពអាល្លឺម៉ង់បានប្រែក្លាយទៅជាកងទ័ពមួយយ៉ាងសាហាវឃោរឃៅ ខ្លាំងពូកែ បំពាក់ដោយអាវុធយុទ្ធភណ្ឌទំនើបព្រមទាំងមានការហ្វឹកហាត់យ៉ាងតឹងរ៉ឹងជាងកងទ័ពនៃប្រទេសនានានៅអឺរ៉ុប ។

## 2. លេសនៃសង្គ្រាម

លោកអ៊ីទ្លែបានរិះរកគ្រប់មធ្យោបាយដើម្បីហែកសន្ធិសញ្ញាវែរសៃ ព្រោះសន្ធិសញ្ញានេះជាឧបសគ្គដល់សេចក្ដីប៉ងប្រាថ្នា ត្រួតត្រាពិភពលោកទាំងមូលរបស់ខ្លួន ។

បក្សណាស៊ីអ៊ីត្លែបានស្ដាបនាឧស្សាហកម្មសឹកមួយយ៉ាងឆាប់រហ័សព្រមទាំងរៀបចំកងទ័ពដែលបំពាក់អាវុធទំនើបៗ ។ ម្យ៉ាងទៀត ដោយមានការគាំទ្រពីពួកនាយទុននៅសហរដ្ឋអាមេរិក អង់គ្លេស បារាំងជួយស្ដារសេដ្ឋកិច្ចឱ្យរីកចម្រើន អាល្លឺម៉ង់បានពង្រឹងកម្លាំងឱ្យកាន់តែរឹងមាំ ។ នយោបាយគាំទ្ររបស់នាយទុនដោយសង្ឃឹមថានិងយកអ៊ីត្លែធ្វើជាឧបករណ៍នយោបាយមួយសម្រាប់ទប់ទល់ និងសហភាពសូវៀត ។ នៅខែ មីនា ឆ្នាំ 1938 អ៊ីត្លែបានយកប្រទេសអូទ្រីសមកភ្ជាប់នឹងរដ្ឋរបស់ខ្លួន ។ នៅខែ កញ្ញា អ៊ីទ្លែយកតំបន់មួយរបស់ឆេកូស្លូវ៉ាគី ។ នៅខែ មីនា ឆ្នាំ 1939 បក្សណាស៊ីអាល្លឺម៉ង់ត្រួតត្រាឆេកូស្លូវ៉ាគីទាំងមូល ។

ក្នុងសន្និសីទក្រុងមុយនិច ថ្ងៃទី 29-30 ខែកញ្ញា ឆ្នាំ 1938 មហាអំណាចលោកខាងលិចមានអ៊ីតាលី បារាំង អង់គ្លេស បានសម្រេចយកតំបន់ស៊ុយដែត(Sudétes)នៃប្រទេសឆេកូស្លូវ៉ាគីទៅឱ្យអ៊ីត្លែដោយពុំបានសួរសហភាពសូវៀត និងប្រជាជនឆេកូស្លូវ៉ាគីឡើយ ។

កិច្ចព្រមព្រៀងទីក្រុងមុយនិច គឺជាការក្បត់មួយរបស់មហាអំណាចអង់គ្លេស អ៊ីតាលី បារាំងដែលលក់ផលប្រយោជន៍ប្រជាជនឆេកូស្លូវ៉ាគីទៅឱ្យអ៊ីត្លែ ។ កិច្ចសមគំនិតនៃមហាអំណាចខាងលើគឺចង់បំពេញចិត្តអ៊ីត្លែដើម្បីបញ្ចៀសការវាយលុកចូលប្រទេសរបស់ខ្លួន ហើយឱ្យអ៊ីត្លែបង្វែរទិសដៅទៅរកសហភាពសូវៀតវិញ ។

នៅថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 1939 ដោយបានទទួលបញ្ជាពីអ៊ីត្លែ កងទ័ពអាល្លឺម៉ង់បានចូលឈ្លានពានប្រទេសប៉ូឡូញដោយយកលេសថាកងទ័ពប៉ូឡូញបានរំលោភឆ្លងព្រំដែនប្រទេសខ្លួននៅភូមិភាគខាងលិច ។ បន្ទាប់មក អង់គ្លេស បារាំងប្រកាសសង្គ្រាម និងពួកណាស៊ីអាល្លឺម៉ង់ ហើយអណ្តាតភ្លើងនៃសង្គ្រាមលោកលើកទី 2 ក៏បានឆេះរាលដាលនៅពេលនោះដែរ ។

## 3. ដំណាក់កាលសំខាន់ៗនៃសង្គ្រាមលោកលើកទី 2

### 3.1. ការវាយលុកនៃកងទ័ពអាល្លឺម៉ង់ អ៊ីតាលី ជប៉ុន



អ៊ីត្លែ



មូសូលីនី



តូសូ

ចាប់ពីឆ្នាំ 1939-1941 កងទ័ពអាល្លឺម៉ង់បានវាយយកបានប្រទេសប៉ូឡូញ ដាណឺម៉ាក បែលហ្ស៊ិក ហូឡង់ ន័រវែស បារាំង យូហ្គោស្លាវី ក្រិក ។ល ។

នៅប្រទេសបារាំងលោកសេនាប្រមុខ ប៉េតាំង (Henri Philippe Petain) ដែលក្នុងពេលនោះបានឡើងធ្វើជានាយករដ្ឋមន្ត្រីបានចុះហត្ថលេខាលើយុទ្ធសន្តិភាពមួយជាមួយអ៊ីត្លែចុះចាញ់កងទ័ពអាល្លឺម៉ង់ ប៉ុន្តែឧត្តមសេនីយ៍សាលដឺហ្គោល (Charles Degaulle) បានភៀសខ្លួនទៅកាន់ទីក្រុងឡុង ប្រមូលអ្នកស្នេហាជាតិបារាំងបន្តការតស៊ូទប់ទល់នឹងកងទ័ពអាល្លឺម៉ង់តទៅទៀត ។

នៅឆ្នាំ 1941 ប្រទេសរុស្ស៊ីត្រូវកងទ័ពអាល្លឺម៉ង់វាយប្រហារដោយមិនបានប្រកាសសង្គ្រាមឱ្យដឹងជាមុន ។ នៅមហាសមុទ្រប៉ាស៊ីហ្វិក កងទ័ពអាកាសជប៉ុនបានវាយប្រហារដោយមិនបានប្រកាសជាមុនទៅលើនាវាចម្បាំងរបស់សហរដ្ឋអាមេរិកនៅកំពង់ផែភាលហាប៊ (PEARL HARBOUR) នៃរដ្ឋហាវៃបណ្តាលឱ្យខូចខាតយ៉ាងដំណំ ។ នៅថ្ងៃទី 7 ខែធ្នូ ឆ្នាំ 1941 សហរដ្ឋអាមេរិកចូលរួមក្នុងសង្គ្រាមលោកលើក ទី 2 ។ ម្យ៉ាងទៀត នៅអាស៊ីកងទ័ពជប៉ុនដណ្តើមបានហុងកុង ហ្វីលីពីន ឥណ្ឌូណេស៊ី សិង្ហបុរី ម៉ាឡេស៊ី ភូមា ថៃ ... តែក្នុងរយៈពេល 2-3 ខែប៉ុណ្ណោះ ។

## 3.2. ការទប់ទល់របស់កងទ័ពរុស្ស៊ី និងអង់គ្លេស

បន្ទាប់ពីវាយប្រហារគ្នាយ៉ាងសាហាវឃោរឃៅមក កងទ័ពរុស្ស៊ីវាយដណ្ដើមបានក្រុងស្តាលីនក្រាតមកវិញនៅ ខែកុម្ភៈ ឆ្នាំ 1943 ។ ចាប់ពីពេលនោះមក កងទ័ពរុស្ស៊ីបានវាយសម្រុកលើកងទ័ពហ្វាស៊ីសអាល្លឺម៉ង់ និងបង្ខំឱ្យកងទ័ពអាល្លឺម៉ង់ដកថយពីគ្រប់សមរភូមិ ។

កងទ័ពអង់គ្លេសបានវាយរុញច្រានកងទ័ពអ៊ីតាលី និងអាល្លឺម៉ង់ពីប្រទេសអេហ្ស៊ីបរហូតដល់ប្រទេសទុយនេស៊ី។ ដោយមានជំនួយពីកងទ័ពបារាំង និងកងទ័ពអាមេរិកដែលទើបបញ្ជូនឡើងគោកនៅម៉ារ៉ុក និងអាល់ហ្សេរី កងទ័ពសម្ព័ន្ធមិត្តបានដេញកងទ័ពណាស៊ីអាល្លឺម៉ង់ និងអ៊ីតាលី រហូតដល់កោះស៊ីស៊ីល (SICILE) និងប្រទេសអ៊ីតាលីតែម្ដង ។ ដោយប្រឈមមុខនឹងស្ថានភាពបរាជ័យ ព្រះមហាក្សត្រអ៊ីតាលី បានផ្ដាច់ទំនាក់ទំនងជាមួយមូសូលីនី ហើយព្រះអង្គសព្វព្រះទ័យចុះព្រះហស្ថលេខាលើយុទ្ធសន្តិភាពជាមួយអង់គ្លេស និងអាមេរិកជាការបញ្ចប់សង្គ្រាមនៅអ៊ីតាលី ។

កងទ័ពអាកាសរបស់ប្រទេសអង់គ្លេស និងអាមេរិកបានបន្តទម្លាក់គ្រាប់បែកឥតឈប់ឈរទៅលើគ្រប់តំបន់ឧស្សាហកម្មដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាល្លឺម៉ង់ ។ នៅពេលជាមួយគ្នានោះប្រទេសជាច្រើនដែលធ្លាប់ធ្លាក់ក្នុងកណ្ដាប់ដៃអ៊ីត្លែ បានបង្កើតចលនាស្នេហាជាតិដោយក្រោកឡើងកាន់អាវុធយ៉ាងក្លាហានប្រឆាំងតបតនឹងកងទ័ពណាស៊ីអាល្លឺម៉ង់ ។ នៅមហាសមុទ្រប៉ាស៊ីហ្វិកកងទ័ពជប៉ុនបានដកថយចេញបន្តិចម្ដងៗពីមូលដ្ឋានដែលខ្លួនបានដណ្ដើមយកនៅពេលចាប់ផ្ដើមសង្គ្រាម ។

## 3.3. ការវាយលុករបស់កងទ័ពសម្ព័ន្ធមិត្តឆ្នាំ 1944

កងទ័ពអង់គ្លេស និងកងទ័ពសហរដ្ឋអាមេរិកបានប្រមូលផ្ដុំគ្នានៅប្រទេសអង់គ្លេស រួចបានឡើងគោកនៅឆ្នាំ 1944 នៅតំបន់ណ័រម៉ង់ឌី (Normandie) ក្រោមបញ្ជាការរបស់ឧត្ដមសេនីយ៍ អាមេរិកឈ្មោះអៃសិន ហោវើ (Eisenhower) ។

កងទ័ពសម្ព័ន្ធមិត្តបានវាយច្រានកងទ័ពអាល្លឺម៉ង់ដល់ក្រុងប៉ារីស ដោយរំដោះក្រុងនេះក្នុងខែសីហា ឆ្នាំ 1944 ហើយបន្តរុញកងទ័ពសត្រូវដល់ទន្លេរ៉ាំង (Rhin) ។ នៅពេលនោះកងទ័ពបារាំងនិងកងទ័ពអាមេរិកបានឡើងគោកនៅភូមិភាគប្រូវ៉ង់ (Provence) ព្រមទាំងបានវាយផ្ចប់កងទ័ពអាល្លឺម៉ង់តាមទន្លេរ៉ូន (Rhone) ។

## 3.4. បរាជ័យរបស់កងទ័ពហ្វាស៊ីសអាល្លឺម៉ង់ និងជប៉ុន

កងទ័ពសហរដ្ឋអាមេរិក និងទ័ពសូវៀតបានទៅរួមគ្នានៅទីក្រុងប៊ែរឡាំងនាថ្ងៃទី 25 ខែមេសា ឆ្នាំ 1945 ។ នៅថ្ងៃទី 30 ខែមេសា ឆ្នាំ 1945 អ៊ីត្លែបានផុតសម្លាប់ខ្លួនឯង បន្ទាប់មកនៅថ្ងៃទី 9 ខែឧសភា ឆ្នាំ 1945 ប្រទេសអាល្លឺម៉ង់បានទម្លាក់អាវុធចុះចាញ់ដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ។

ប្រទេសទាំងឡាយដែលធ្លាប់ធ្លាក់ក្នុងកណ្ដាប់ដៃអ៊ីតែ្លបានរំដោះខ្លួន និងប្រកាសឯករាជ្យរៀងៗខ្លួន ។ នៅថ្ងៃទី 2 ខែកញ្ញា ឆ្នាំ 1945 ប្រទេសជប៉ុនត្រូវទម្លាក់អាវុធចុះចាញ់ បន្ទាប់ពីសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកបរមាណូ 2 គ្រាប់ទៅលើទីក្រុងហ៊ីរ៉ូស៊ីម៉ា (Hiroshima) នៅថ្ងៃទី 6 ខែសីហា ឆ្នាំ 1945 និងណាកាសាគី(Nagasaki) នៅថ្ងៃទី 9 ខែសីហា ឆ្នាំ 1945 ។ ប្រទេសជប៉ុនត្រូវបាត់បង់នូវទឹកដីទាំងអស់ដែលខ្លួនដណ្ដើមបានពីមុន ហើយសង្គ្រាមលោកលើកទី 2 ក៏ត្រូវបញ្ចប់ដោយការបរាជ័យនៃរបបយោធានិយមជប៉ុន ។

# 4. ផលវិបាកនៃសង្គ្រាមលោកលើកទី 2

សង្គ្រាមលោកលើកទី 2 បានធ្វើឱ្យខូចខាតយ៉ាងច្រើនទាំងជីវិតមនុស្សទាំងសម្ភារៈ ទាំងនយោបាយ រួមទាំងហេដ្ឋារចនាសម្ព័ន្ធសង្គមទាំងមូល ។

## 4.1. ផលវិបាកខាងមនុស្ស

សង្គ្រាមឆ្នាំ 1939-1945 បានធ្វើឱ្យបាត់បង់ជីវិតមនុស្សប្រមាណ 45 លាននាក់ ។ ការបាត់បង់ដ៏ច្រើននេះបណ្ដាលពីឥទ្ធិពលនៃការទម្លាក់គ្រាប់បែក នយោបាយបំបាត់ពូជសាសន៍ដែលអ៊ីតែ្លបានអនុវត្តទៅលើជនជាតិជ្វីបការបាញ់សម្លាប់ និងស្លាប់ដោយប្រការផ្សេងៗទៀត ។

## 4.2. ផលវិបាកខាងសម្ភារៈ

មានការខូចខាតទ្រព្យសម្បត្តិយ៉ាងច្រើនឥតគណនា ដែលបណ្ដាលមកពីការទម្លាក់គ្រាប់បែក ការបាញ់ផ្ដក់ដាក់គ្នា ការបាញ់រះពីលើយន្ដហោះ ការដុតបំផ្លាញធ្វើឱ្យទីក្រុងទាំងឡាយឱ្យក្លាយជាផេះដូចជា ទីក្រុងហាំប៊ួក(Hambourg) រ៉ូទែដាំ (Rotterdam) វ៉ាស្សូវី (Varsovie) ... ។

ចំពោះប្រទេសដែលធ្លាក់ក្នុងកណ្ដាប់ដៃហ្វាស៊ីសអាល្លឺម៉ង់ ក្នុងពេលសង្គ្រាមភោគទ្រព្យទាំងអស់ត្រូវមហាអំណាចនេះរឹបអូសយកមួយភាគធំ ដូចជាភោគទ្រព្យខាងកសិកម្ម ឧស្សាហកម្មជាដើម ។

## 4.3. ផលវិបាកខាងនយោបាយ និងការបាត់បង់ទឹកដី

ដោយទទួលបរាជ័យក្នុងសង្គ្រាមប្រទេសអាល្លឺម៉ង់ អ៊ីតាលី និងជប៉ុនត្រូវបាត់បង់ទឹកដីដែលខ្លួនបានដណ្ដើមយកពីមុនអស់វិញដូចជាប្រទេសអូទ្រីស ឆេកូស្លូវ៉ាគី ភូមិភាគខាងលិចអាល់បានី អាណាខេត្តម៉ាន់ជូរី ប្រទេសកូរ៉េ ។ល។

ប្រទេសអាល្លឺម៉ង់ត្រូវបែងចែកជា 4តំបន់គឺ តំបន់ស្ថិតក្រោមការត្រួតត្រារបស់ប្រទេសអង់គ្លេស សហរដ្ឋអាមេរិក បារាំង និងសហភាពសូវៀត ។ ទីក្រុងបែរឡាំងក៏ត្រូវបែងចែកជា 4ដូចប្រទេសទាំងមូលដែរ ។

ផលវិបាកខាងនយោបាយដ៏សំខាន់ គឺការចាប់កំណើតនៃប្រទេសដែលកាន់របបសង្គមនិយមមួយចំនួនមាន អាល្លឺម៉ង់ខាងកើត ប៉ូឡូញ ឆេកូស្លូវ៉ាគី យូហ្គោស្លាវី អាល់បានី ប៊ុលហ្គារី ម៉ុងហ្គោលី កូរ៉េខាងជើង ចិនប្រជាមានិត ហុងគ្រី ... ។

## 5. ដំណោះស្រាយក្រោយសង្គ្រាម

បន្ទាប់ពីធ្វើសន្និសីទជាច្រើនដងចាប់ពីឆ្នាំ 1943-1955 នៅក្រុងតេអេរ៉ង់ (Teheran) យ៉ាល់តា (Yalta) ប៉ូតស្តាម(Potsdam)មហាអំណាចទាំង 3មានអាមេរិក សូវៀត និងអង់គ្លេសបានចេញសេចក្តីសម្រេច :

- សហភាពសូវៀតត្រូវបានរដ្ឋទាំងប៉ុន្មានរបស់ខ្លួនដែលអ៊ីត្លែរដណ្តើមយកក្នុងពេលសង្គ្រាម ។
- គ្រប់ប្រទេសទាំងឡាយដែលបាត់បង់ឈ្មោះចាប់ពីឆ្នាំ 1938 មកដោយសារតែការភ្ជាប់ប្រទេសទាំងនោះចូលទៅក្នុងប្រទេសអាល្លឺម៉ង់ត្រូវបានទទួលស្គាល់ឡើងវិញក្នុងក្របខ័ណ្ឌព្រំដែនចាស់របស់ខ្លួនដូចជាប្រទេសឆេកូ និងអូទ្រីសជាដើម ។
- ប្រទេសអាល្លឺម៉ង់ត្រូវបែងចែកជា 4តំបន់ដោយស្ថិតក្រោមការត្រួតត្រារបស់មហាអំណាច 4 មានអាមេរិក សូវៀត អង់គ្លេស និងបារាំង ។
- អាមេរិកត្រូវទទួលសិទ្ធិត្រួតត្រាប្រទេសជប៉ុនតែម្នាក់ឯង ។ ឯមហាអំណាចឈ្នះសង្គ្រាមដទៃទៀតមានសិទ្ធិរឹបអូសយកទឹកដីដែលជប៉ុនដណ្តើមក្នុងពេលសង្គ្រាមមកត្រួតត្រាក្រោមអាណានិគមរបស់ខ្លួនដូចជា អង់គ្លេស បារាំង និងហូឡង់ជាដើម ។

## ? សំណួរ

1. ចូររៀបរាប់ពីបុព្វហេតុនៃសង្គ្រាមលោកលើកទី 2 ។
2. តើហេតុអ្វីបានជាកងទ័ពអាល្លឺម៉ង់ អ៊ីតាលី និងជប៉ុនបង្កសង្គ្រាមលោកលើកទី 2នេះឡើង ?
3. ចូររៀបរាប់ផលវិបាកនៃសង្គ្រាមលោកលើកទី 2 ។
4. ចូរពន្យល់ពីដំណោះស្រាយក្រោយសង្គ្រាមលោកលើកទី 2 ។

# 4 អង្គការសហប្រជាជាតិ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីកំណើតអង្គការសហប្រជាជាតិ និងរចនាសម្ព័ន្ធគ្រប់គ្រង
- ❑ បង្ហាញពីសមត្ថកិច្ចនៃអង្គការសហប្រជាជាតិ
- ❑ ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ពង្រឹងចំណងមិត្តភាពជាសាកល ។

អង្គការសហប្រជាជាតិបានបង្កើតឡើងនៅថ្ងៃទី 24 ខែតុលា ឆ្នាំ 1945 ដោយមានសមាជិកចំនួន 51 ប្រទេស ប៉ុន្តែនៅពេលនោះពុំទាន់មានទីស្នាក់ការនៅឡើយ ។ រហូតដល់ថ្ងៃទី 11 ខែ ធ្នូ ឆ្នាំ 1945 ទើបសភាសហរដ្ឋអាមេរិកបានបោះឆ្នោតជាឯកច្ឆន្ទសម្រេចយកទីស្នាក់ការនៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។

## 1. ទិសដៅ និងគោលការណ៍របស់អង្គការសហប្រជាជាតិ

ធម្មនុញ្ញអង្គការសហប្រជាជាតិមាន 111 មាត្រា ។ មាត្រាទី 1 និងមាត្រាទី 2 បានចែងពីទិសដៅ និងគោលការណ៍ :

### 1.1. ទិសដៅ

មាត្រាទី 1 ចែងពីទិសដៅនៃអង្គការសហប្រជាជាតិ

- រក្សាសន្តិសុខ និងសន្តិភាពពិភពលោកដោយចាត់វិធានការយ៉ាងមានប្រសិទ្ធភាពដើម្បីបង្ក្រាប និងបញ្ចៀសរាល់ការគំរាមកំហែងសន្តិសុខ ព្រមទាំងធ្វើការគាបសង្កត់រាល់អំពើរំលោភ ឬធ្វើឱ្យខូចដល់សន្តិភាពពិភពលោក ។
- ពង្រីកទំនាក់ទំនងមិត្តភាពរវាងប្រជាជាតិទាំងឡាយ ដោយឈរលើការគោរពសិទ្ធិប្រជាពលរដ្ឋ និងចាត់វិធានការផ្សេងៗដើម្បីពង្រឹងសន្តិភាព ។
- ធ្វើឱ្យមានសហប្រតិបត្តិការអន្តរជាតិខាងផ្នែកសេដ្ឋកិច្ច ប្រាជ្ញា ឬមនុស្សធម៌ដោយគ្មានការប្រកាន់ពូជសាសន៍ ភេទ ភាសា និងសាសនា ។
- ស្ថិតក្នុងក្របខ័ណ្ឌដែលប្រជាជាតិនានាខិតខំប្រឹងប្រែងដើម្បីឆ្ពោះទៅរកសេចក្តីបញ្ចប់រួមគ្នា ។

## 1.2. គោលការណ៍

ចំណុចជាគោលការណ៍នៅក្នុងមាត្រាទី 2គឺ

- សមាជិកទាំងអស់ត្រូវបំពេញកាតព្វកិច្ចដោយជឿជាក់លើធម្មនុញ្ញនៃអង្គការសហប្រជាជាតិ
- សមាជិកទាំងអស់ត្រូវដោះស្រាយរាល់ជម្លោះអន្តរជាតិដោយមធ្យោបាយសន្តិភាពនៅក្នុងលក្ខខណ្ឌមិនធ្វើឱ្យខូចខាតដល់សន្តិភាព សន្តិសុខ និងយុត្តិធម៌
- ត្រូវអត់ធ្មត់រាល់អំពើគំរាមកំហែង និងការប្រើកម្លាំងប្រឆាំងនឹងប្រទេសណាមួយនៅក្នុងទំនាក់ទំនងអន្តរជាតិរបស់ខ្លួន
- ធម្មនុញ្ញមិនអនុញ្ញាតឱ្យអង្គការសហប្រជាជាតិធ្វើអន្តរាគមន៍ក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសណាមួយឡើយ ។

# 2. ស្ថាប័ននានា

អង្គការសហប្រជាជាតិមានស្ថាប័នសំខាន់ៗចំនួន6គឺ មហាសន្និបាត លេខាធិការដ្ឋាន ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាសន្តិសុខ តុលាការអន្តរជាតិ និងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ។

## 2.1. មហាសន្និបាត

មហាសន្និបាតប្រចាំឆ្នាំ គឺជាវេទិកាជួបជុំប្រទេសជាសមាជិកដើម្បីពិភាក្សា និងអនុម័តលើសេចក្តីសម្រេចផ្សេងៗនៅរៀងរាល់ខែកញ្ញា ។ ភាសាផ្លូវការដែលគេប្រើក្នុងមហាសន្និបាត មានភាសាអង់គ្លេស បារាំង អេស្ប៉ាញ អារ៉ាប់ រុស្ស៊ី និងចិន ។

## 2.2. ក្រុមប្រឹក្សាសន្តិសុខ

នៅថ្ងៃទី 01-01-1966ក្រុមប្រឹក្សានេះមានសមាជិកសរុប 11 ប្រទេស ។ ដោយសមាជិក អ.ស.ប. ចេះតែកើនឡើងជាលំដាប់ ទើបក្រុមប្រឹក្សាសន្តិសុខបន្ថែមសមាជិករហូតដល់ 15ប្រទេសនៅឆ្នាំ 1988 ដោយមានប្រទេសមហាអំណាចអចិន្ត្រៃយ៍ចំនួន 5គឺ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស សហភាពសូវៀត បារាំង និងចិន ។ ចំណែកសមាជិកធម្មតា 10ប្រទេសគឺ អាល់ហ្សេរី អាហ្សង់ទីន ប្រេស៊ីល សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ អ៊ីតាលី ជប៉ុន នេប៉ាល់ សេណេហ្កាល់ យូហ្គោស្លាវី និងស៊ីមបាវេ ។

ក្រុមប្រឹក្សាសន្តិសុខ ជាអង្គការនីតិប្រតិបត្តិមានតួនាទីពង្រឹងសន្តិភាពពិភពលោក ។ ម្យ៉ាងទៀតប្រសិនបើប្រទេសជាសមាជិកណាមួយដែលទាក់ទងក្នុងរឿងជម្លោះមិនព្រមអនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនោះ ក្រុមប្រឹក្សានេះនឹងចាត់វិធានការពីរយ៉ាងគឺ ៖

### ក. ទណ្ឌកម្មមិនប្រើកម្លាំង

- ធ្វើការពិភាក្សាតាមផ្លូវទូត
- ដាក់ទណ្ឌកម្មសេដ្ឋកិច្ច ផ្ដាច់ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ បិទផ្លូវគោក ផ្លូវអាកាសនាំឱ្យប្រទេសនោះមានវិបត្តិសង្គមនិងវិបត្តិសេដ្ឋកិច្ច ។

### ខ. ទណ្ឌកម្មដោយប្រើកម្លាំង

បញ្ជូនទ័ពមួកខៀវទៅហ៊ុមព័ទ្ធ បញ្ជូននាវាចម្បាំងទៅក្នុងដែនទឹកឬបើកការវាយប្រហារតាមផ្លូវអាកាស ដើម្បីគាបសង្កត់ប្រទេសនោះឱ្យទទួលយកលក្ខខណ្ឌរបស់ក្រុមប្រឹក្សាសន្តិសុខ ដូចជាសង្គ្រាមឈូងសមុទ្រពែក្សនៅឆ្នាំ 1991 របស់អង្គការសហប្រជាជាតិប្រឆាំងជាមួយនិងប្រទេសអ៊ីរ៉ាក់ដែលមិនព្រមដកទ័ពចេញពីប្រទេសគូវ៉ែត ។

## 2.3. តុលាការអន្តរជាតិ

តុលាការអន្តរជាតិមានចៅក្រមចំនួន 15នាក់ មានអាណត្តិ 9ឆ្នាំ ជ្រើសតាំងដោយមហាសន្និបាតចំនួន 1/3 (5នាក់)ក្នុងរយៈពេល 3ឆ្នាំម្ដង ។ ចៅក្រមដែលត្រូវបានជ្រើសរើសគឺជាមនុស្សមានសីលធម៌ល្អ តាមលក្ខខណ្ឌប្រទេសមួយជ្រើសរើសចៅក្រមម្នាក់ ។

## 2.4. លេខាធិការដ្ឋាន

អង្គការសហប្រជាជាតិមានអគ្គលេខាជាប្រធានដែលមានអាណត្តិ 5ឆ្នាំ ជ្រើសតាំងដោយមហាសន្និបាត ។ អគ្គលេខាធិការអង្គការសហប្រជាជាតិមានចំនួន 8រូប ហើយចាប់ពីលោកទ្រីវ លីមកដល់ពេលបច្ចុប្បន្នលោក បាន គីមូន ។


*លោក ទ្រីវ លី*


*លោក ដាក់ហាំ ម៉ាសូល*


*លោក អ៊ូ ថាន់*


*លោក ឃើត វ៉ាលហេម*


*លោក សាវីយេ ប៉េរ៉េឌឺគូអេយ៉ា*


*លោក ប៊ូត្រូស ប៊ូត្រូសហ្កាលី*


*លោក កូហ្វី អាណាន់*


*លោក បាន គីមូន*

**លោក ទ្រីវ លី** (1946-1952) ជាអគ្គលេខាធិការដំបូងបង្អស់ មានសញ្ជាតិន័រវែស ត្រូវបានតែងតាំងជាអគ្គលេខានៅថ្ងៃទី 1 ខែកុម្ភៈ ឆ្នាំ 1946 ដល់ថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 1950លោកត្រូវតែងតាំងបន្តដល់ឆ្នាំ 1952 ។

- លោក ដាក់ហាំម៉ាស្កូល (1953-1961) ជាតិស៊ុយអែត ត្រូវតែងតាំងជាអគ្គលេខានៅថ្ងៃទី 10 ខែមេសា ឆ្នាំ 1953 ដល់ថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 1961 ។
- លោក អ៊ូ ថាន់ (1961-1971) ជាតិភូមា ត្រូវតែងតាំងជាអគ្គលេខានៅ ថ្ងៃទី 03 ខែវិច្ឆិកា ឆ្នាំ 1961 លុះដល់ថ្ងៃទី 02 ខែធ្នូ ឆ្នាំ 1966 លោកត្រូវតែងតាំងជាអគ្គលេខានៅអាណត្តិទី 2 ដែលបញ្ចប់នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1971 ។
- លោក ឃើត វ៉ាលហែម (1972-1981) ជាតិអូទ្រីស ត្រូវតែងតាំងជាអគ្គលេខានៃអង្គការសហប្រជាជាតិនៅថ្ងៃទី 01 ខែមករា ឆ្នាំ 1972 និងតែងតាំងនៅអាណត្តិទី 2 នៅខែធ្នូ ឆ្នាំ 1976 បញ្ចប់នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1981 ។
- លោក សាវីយេ ប៉េរ៉េដឺគូអេឡា (1982-1991) ជាតិប៉េរូ ត្រូវបានតែងតាំងជាអគ្គលេខានៅថ្ងៃទី 01 ខែមករា ឆ្នាំ 1982 បញ្ចប់អាណត្តិទី 2 នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1991 ។
- លោក ប៊ូត្រូស ប៊ូត្រូសកាលី (1992-1996) ជាតិអេហ្ស៊ីប ត្រូវបានតែងតាំងជាអគ្គលេខាអង្គការសហប្រជាជាតិថ្ងៃទី 01 ខែមករា ឆ្នាំ 1992 បញ្ចប់អាណត្តិថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1996 ។
- លោក កូហ្វី អាណាន់ (1997-2006) ជាតិហ្គាណា ត្រូវបានតែងតាំងជាអគ្គលេខាអង្គការសហប្រជាជាតិនៅថ្ងៃទី 01 ខែមករា ឆ្នាំ 1997 បញ្ចប់អាណត្តិទី 2 នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2006 ។
- លោក បាន គីមូន (2007) ជាតិកូរ៉េ ត្រូវបានតែងតាំងជាអគ្គលេខាអង្គការសហប្រជាជាតិនៅថ្ងៃទី 01 ខែមករា ឆ្នាំ 2007 ។

## 2.5. ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម

ក្រុមប្រឹក្សានេះមានសមាជិកចំនួន 54 ប្រទេស តែងបើកសម័យប្រជុំចំនួន 2 ដងក្នុងមួយឆ្នាំ ដើម្បីពិភាក្សាលើបញ្ហាសេដ្ឋកិច្ច និងបញ្ហាជំនួយដល់ប្រទេសតតិយលោក ។

ក្រុមប្រឹក្សានេះជួយលើកស្ទួយជីវភាពប្រជាជន អភិវឌ្ឍសេដ្ឋកិច្ចពិភពលោក និងតាមឃ្លាំមើលសិទ្ធិមនុស្សដែលមានអង្គការផ្សេងៗទៀតជាចំណុះ ដូចជាអង្គការការងារអន្តរជាតិ អង្គការស្បៀងអាហារពិភពលោក (WFP) អង្គការរូបិយវត្ថុអន្តរជាតិ (IMF) ។ល ។

## 2.6. ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សានេះទទួលបន្ទុកគ្រប់គ្រងផ្នែករដ្ឋបាលលើប្រទេសទាំងឡាយដែលជាអតីតអាណានិគមរបស់អ៊ីតាលី អាល្លឺម៉ង់ និងជប៉ុន ។

## ? សំណួរ

1. ចូររៀបរាប់ពីមូលហេតុនៃការបង្កើតអង្គការសហប្រជាជាតិ ។
2. តើអង្គការសហប្រជាជាតិមានអគ្គលេខាធិការប៉ុន្មានរូបហើយ ? ឈ្មោះអ្វីខ្លះ ?
3. តើស្ថាប័នរបស់អង្គការសហប្រជាជាតិមានប៉ុន្មាន ? អ្វីខ្លះ ?

# 5 សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីគោលបំណងនៃការបង្កើតសមាគមអាស៊ាន
- ❑ បង្ហាញពីប្រទេសជាសមាជិកអាស៊ានទាំង 10
- ❑ ចេះប្រៀបធៀបផលប្រយោជន៍និងគុណវិបត្តិនៃសមាជិកអាស៊ាន ។

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថា អាស៊ាន ASEAN (Association of South East Asian Nations) បង្កើតឡើងដើម្បីធ្វើសហប្រតិបត្តិការគ្នានៅក្នុងតំបន់ ដើម្បីពង្រឹងសន្តិសុខ រក្សាសន្តិភាព ។

## 1. ប្រវត្តិអាស៊ាន

អាស៊ាន ត្រូវចុះហត្ថលេខាបង្កើតឡើងដោយប្រទេសចំនួន 5 នៅទីក្រុងបាងកក មានប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី សិង្ហបុរី ថៃ និងហ្វីលីពីន នៅថ្ងៃទី 8 ខែសីហា ឆ្នាំ 1967 ។

- ប្រទេសព្រុយណេ ចូលជាសមាជិកទី 6 នៅថ្ងៃទី 8 ខែមករា ឆ្នាំ 1984
- ប្រទេសវៀតណាម ចូលជាសមាជិកទី 7 នៅថ្ងៃទី 28 ខែកក្កដា ឆ្នាំ 1995
- ប្រទេសឡាវ ចូលជាសមាជិកទី 8 នៅថ្ងៃទី 23 ខែកក្កដា ឆ្នាំ 1997
- ប្រទេសមីយ៉ាន់ម៉ា ចូលជាសមាជិកទី 9 នៅថ្ងៃទី 23 ខែកក្កដា ឆ្នាំ 1997
- ប្រទេសកម្ពុជា ចូលជាសមាជិកទី 10 នៅថ្ងៃទី 30 ខែមេសា ឆ្នាំ 1999
- ប្រទេសទីម័រខាងកើត និងប៉ាពួញូគីនេ បានត្រៀមខ្លួនចូលជាសមាជិកអាស៊ាននៅពេលខាងមុខនេះផងដែរ ។

## 2. និមិត្តសញ្ញាអាស៊ាន និងទង់ជាតិប្រទេសសមាជិកអាស៊ាន




*និមិត្តសញ្ញាអាស៊ាន*

- ពណ៌ខៀវ : តំណាងឱ្យសន្តិភាព និងស្ថិរភាព
- ពណ៌ក្រហម : តំណាងឱ្យសេចក្តីក្លាហាន និងភាពស្វាហាប់
- ពណ៌ស : តំណាងឱ្យភាពបរិសុទ្ធ និងស្មោះត្រង់
- ពណ៌លឿង : តំណាងឱ្យភាពសម្បូររុងរឿង
- ដើមស្រូវទាំង 10 : តំណាងឱ្យសុបិនរបស់បិតាបង្កើតអាស៊ានដែលចង់ប្រមូលផ្តុំប្រទេសទាំង 10 នៅអាស៊ីអាគ្នេយ៍ឱ្យក្លាយទៅជាសមាគមមួយដែលមានសាមគ្គីភាព ។
- ពណ៌ទាំងអស់របស់ទង់អាស៊ាន : តំណាងឱ្យពណ៌នៃទង់ជាតិរបស់ប្រទេសជាសមាជិកទាំងអស់ ។
- ទង់អាស៊ាន : តំណាងឱ្យសមាគមអាស៊ានមួយដែលមានស្ថិរភាព និងសន្តិភាព ។

## 3. មូលហេតុនៃការបង្កើតអាស៊ាន

មូលហេតុសំខាន់នៃការបង្កើតអាស៊ានគឺ

- ប្រមូលផ្តុំទីផ្សារអាស៊ីអាគ្នេយ៍ដើម្បីធ្វើការអភិវឌ្ឍរួមគ្នា និងដើម្បីធ្វើការប្រកួតប្រជែងលើទីផ្សារអន្តរជាតិ
- ធ្វើសហប្រតិបត្តិការក្នុងតំបន់ ដោយឈរលើស្មារតីស្មើភាពគ្នាលើវិស័យសេដ្ឋកិច្ច ។

## 4. ការបង្កើតតំបន់សន្តិភាពសេរី និងអព្យាក្រឹត ZOPFAN

**( Zone of Peace Freedom and Neutrality )**

នៅថ្ងៃទី 27 ខែវិច្ឆិកា ឆ្នាំ 1971 ZOPFAN ត្រូវបានបង្កើតឡើងនៅទីក្រុងកូឡាឡាំពួ ។

- សមាជិកអាស៊ានប្តេជ្ញាខិតខំរក្សាតំបន់អាស៊ីអាគ្នេយ៍ឱ្យទៅជាតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត ដោយមិនស្ថិតក្រោមអន្តរាគមន៍នៃមហាអំណាចបរទេសឡើយ ។
- សមាជិកអាស៊ានខិតខំបង្កើនសហប្រតិបត្តិការឱ្យកាន់តែទូលាយ ដោយពង្រឹងសាមគ្គីភាព និងមិត្តភាពរវាងគ្នានិងគ្នា ។
- បន្ធូរភាពតានតឹងអន្តរជាតិ និងធ្វើឱ្យសម្រេចបានសន្តិភាពដ៏យូរអង្វែងមួយនៅអាស៊ីអាគ្នេយ៍
- គោរពបូរណភាពដែនដី ដោះស្រាយទំនាស់ដោយសន្តិវិធី និងមិនជ្រៀតចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសណាមួយឡើយ ។

## 5. សន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការ TAC

**( Treaty of Amity and Cooperation )**

នៅថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 1976 សន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការត្រូវគេចុះហត្ថលេខាក្នុងសម័យប្រជុំកំពូលអាស៊ាននៅកោះបាលី ប្រទេសឥណ្ឌូណេស៊ី ។

ក្នុងទំនាក់ទំនងរវាងគ្នានិងគ្នា សមាជិកអាស៊ានមានគោលការណ៍ដូចតទៅ :

- គោរពគ្នាទៅវិញទៅមកលើឯករាជ្យ អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិនៃសមាជិកទាំងអស់
- គោរពសិទ្ធិរបស់រដ្ឋនីមួយៗក្នុងការដឹកនាំប្រទេសខ្លួនឱ្យជៀសផុតពីការបង្ខិតបង្ខំពីខាងក្រៅ
- មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក
- ដោះស្រាយទំនាស់ដោយមធ្យោបាយសន្តិវិធី
- ប្រឆាំងចំពោះការគំរាមប្រើកម្លាំងទ័ព
- រួមសហការគ្នាយ៉ាងល្អរវាងសមាជិកទាំងអស់
- ធ្វើឱ្យតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ ។

## 6. ការបង្កើតតំបន់ពាណិជ្ជកម្មសេរី AFTA (Asean Free Trade Area)




ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលអាស៊ានក្នុងកិច្ចប្រជុំកំពូលនៅ ឆាអាំ (ប្រទេសថៃ) ឆ្នាំ 2009

នៅថ្ងៃទី 01 ខែមករា ឆ្នាំ 1993 តំបន់ពាណិជ្ជកម្មសេរី (AFTA) ត្រូវបានប្រកាសបង្កើតជាផ្លូវការ ។ AFTA មានគោលដៅទាក់ទងនឹងការបញ្ចុះតម្លៃផលិតផលមួយចំនួន បន្ទាប់មកនឹងបើកឱ្យមានពាណិជ្ជកម្មសេរី ។ ការបង្កើត AFTA មានគោលបំណងទាក់ទាញវិនិយោគទុន និងការរកទីផ្សារនៅតំបន់ឥណ្ឌូចិនផងដែរ ។ សន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី 27 នៅទីក្រុងបាងកក ថ្ងៃទី 22 ដល់ 23 ខែកក្កដា ឆ្នាំ 1994 បានចេញសេចក្តីថ្លែងការណ៍មួយបញ្ជាក់ជាថ្មីពីទិសដៅ AFTA :

- សម្រេចអនុវត្តលើការបន្ថយតម្លៃទំនិញតាមកម្មវិធីឆ្នាំ 1994
- លើកទឹកចិត្តចំពោះលំហូរចូលនៃវិនិយោគទុនបរទេស
- ឯកភាពចំពោះការភ្ជាប់ពាណិជ្ជកម្មជាមួយតំបន់ដទៃទៀតក្នុងពិភពលោក ។

## 7. ការបង្កើតវេទិកាតំបន់អាស៊ាន ARF (Asean Regional Forum)

នៅថ្ងៃទី 25 ខែកក្កដា ឆ្នាំ 1994 វេទិកាតំបន់អាស៊ាន (ARF) បានប្រកាសបង្កើតវេទិកាតំបន់អាស៊ានជាផ្លូវការ ក្នុងបំណងរឹតចំណងមេត្រីភាពក្នុងបណ្តាប្រទេសអាស៊ាន និងបណ្តាប្រទេសនានានៅតំបន់អាស៊ីប៉ាស៊ីហ្វិក ។ ARF មានតួនាទីពង្រឹងទំនុកចិត្តគ្នាទៅវិញទៅមកក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដោយការចរចានានាលើកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ និងសន្តិសុខក្នុងតំបន់ ។

### ? សំណួរ

1. តើអាស៊ានមានន័យដូចម្តេច ?
2. តើសមាគមអាស៊ានមានប្រទេសប៉ុន្មានជាសមាជិក គិតដល់ឆ្នាំ 1999 ?
3. ពីដំបូងអាស៊ានបង្កើតឡើងមានប្រទេសណាខ្លះ ? នៅទីណា ? ថ្ងៃ ខែ ឆ្នាំណា ?
4. ចូររៀបរាប់ពីការបង្កើតសន្ធិសញ្ញាឬតំបន់ពាណិជ្ជកម្មរបស់អាស៊ាន ។

## ? សំណួរបញ្ចប់ជំពូកទី១

I. ចូរគូសសញ្ញា ✓ មុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

1. សង្គ្រាមលោកលើកទី 1 ចាប់ផ្ដើមឡើងនៅខែនិងឆ្នាំ ៖

☐ ក. សីហា 1914 ☐ ខ. សីហា 1915 ☐ គ. កក្កដា 1914 ☐ ឃ. មិថុនា 1916 ។

2. សង្គ្រាមលោកលើកទី 1 បញ្ចប់នៅឆ្នាំណា ៖

☐ ក. 1915 ☐ ខ. 1916 ☐ គ. 1917 ☐ ឃ. 1918 ។

3. ប្រទេសនានាដែលបានចូលរួមនៅក្នុងសង្គ្រាមលោកលើកទី 1 ចែកជា ៖

☐ ក. 2ប្លុក ☐ ខ. 3ប្លុក ☐ គ. 4ប្លុក ☐ ឃ. 5ប្លុក ។

4. សង្គ្រាមលោកលើកទី 2 ចាប់ផ្ដើមពីឆ្នាំ ៖

☐ ក. 1938-1943 ☐ ខ. 1939-1945 ☐ គ. 1940-1943 ☐ ឃ. 1941-1944 ។

5. អង្គការសហប្រជាជាតិបង្កើតឡើងនៅឆ្នាំ ៖

☐ ក. 1940 ☐ ខ. 1942 ☐ គ. 1944 ☐ ឃ. 1945 ។

6. ប្រទេសដែលចុះហត្ថលេខាបង្កើតអាស៊ានមានចំនួន ៖

☐ ក. 2 ☐ ខ. 3 ☐ គ. 4 ☐ ឃ. 5 ។

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. ទិសដៅនៃមាត្រាទី 1 របស់អង្គការសហប្រជាជាតិតែងតែ ................................ ។
2. អង្គការសហប្រជាជាតិមានស្ថាប័នសំខាន់ៗចំនួន ................................ ។
3. សមាគមសហប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) បង្កើតឡើងដើម្បី ................................ ។
4. អគ្គលេខាអង្គការសហប្រជាជាតិជ្រើសតាំងដោយ ................................ ។

III. ចូរឆ្លើយសំណួរខាងក្រោម

1. ចូរបង្ហាញពីមូលហេតុដែលបណ្ដាលឱ្យកើតមានសង្គ្រាមលោកលើកទី 1 ?
2. តើលោកវិលសុនជានរណា ? បានធ្វើអ្វីខ្លះនៅសង្គ្រាមលោកលើកទី 1 ?
3. ចូរប្រៀបធៀបផលវិបាកនៃសង្គ្រាមលោកលើកទី 1 និងទី 2 ចំពោះមនុស្សនិងសម្ភារៈ ?
4. ចូរបង្ហាញឈ្មោះលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទាំង 8 រូប ?
5. តើមូលហេតុនយោបាយដែលឈានដល់ការបង្កើតអាស៊ានគឺអ្វីខ្លះ ?

# ជំពូកទី 2 ប្រវត្តិសាស្ត្រប្រទេសកម្ពុជា



ប្រទេសជាតិមួយដែលធ្លាប់តែរុងរឿងក្នុងសម័យបុរាណ ត្រូវធ្លាក់ក្នុងអាណានិគមនិយមបារាំងអស់រយៈពេល 90ឆ្នាំ(1863-1953) ។

ដូច្នេះការរើបម្រះដើម្បីឯករាជ្យជាតិឡើងវិញបានដើបឡើងជាបន្តបន្ទាប់ ប៉ុន្តែមិនបានជោគជ័យឡើយ ទើបតែនៅថ្ងៃទី 9 ខែវិច្ឆិកា ឆ្នាំ 1953 ទើបចលនាតស៊ូដើម្បីទាមទារឯករាជ្យដែលដឹកនាំដោយ សម្ដេចព្រះនរោត្តម សីហនុ សម្រេចបានជោគជ័យជូនប្រជារាស្ត្រ និងជាតិមាតុភូមិ ។ ប៉ុន្តែសង្គ្រាមត្រជាក់បានបំផ្លាញសេចក្ដីសុខសាន្តរបស់ប្រជារាស្ត្រខ្មែរជាបន្តបន្ទាប់ ។ នៅថ្ងៃទី 23 ខែ តុលា ឆ្នាំ 1991 ជាថ្ងៃបើកទំព័រសករាជថ្មីនាំឱ្យមានកិច្ចចរចាក្រុងប៉ារីសដើម្បីសន្តិភាពនៅប្រទេសកម្ពុជាក្រោមជំនួយឧបត្ថម្ភគាំទ្រពីអង្គការសហប្រជាជាតិហៅកាត់ UNTAC ។ វិបត្តិនយោបាយដែលបានបន្សល់ទុកពីអតីតកាលត្រូវបញ្ចប់តាមរយៈការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនាឆ្នាំ 1993 ។

# 1 អាណានិគមនិយមបារាំង (១៨៦៣_១៩៥៣)

**ចប់មេរៀននេះ សិស្សអាច**

- អធិប្បាយពីសន្ធិសញ្ញាឆ្នាំ 1863 និងឆ្នាំ 1884 និងអត្ថន័យរបស់សន្ធិសញ្ញា
- រកមូលហេតុដែលនាំទៅដល់ការត្រួតត្រារបស់បារាំងលើប្រទេសកម្ពុជា
- បណ្ដុះស្មារតីស្នេហាជាតិ ចង់បានឯករាជ្យ សេរីភាព និងមានបូរណភាពដែនដី ។

នៅអំឡុងពាក់កណ្ដាលសតវត្សទី 19 ប្រទេសបារាំងក៏ដូចប្រទេសអង់គ្លេសដែរ មានការចាប់អារម្មណ៍ខ្លាំងចំពោះទឹកដីអាណានិគមនៅភូមិភាគអាស៊ីអាគ្នេយ៍ក្នុងគោលបំណងស្វែងរកវត្ថុធាតុដើម និងទីផ្សារសម្រាប់បញ្ចេញទំនិញរបស់ខ្លួន ក្នុងគោលបំណងបង្កើតមូលដ្ឋាននាវា និងផ្លូវជំនួញមកកាន់ប្រទេសចិន ។ ហេតុនេះហើយបានជានៅរវាងឆ្នាំ 1858 និងឆ្នាំ 1887 បារាំងបានចាប់ផ្ដើមចូលត្រួតត្រាបន្តិចម្ដងៗមកលើប្រទេសកម្ពុជា វៀតណាម និងឡាវ ។

## 1. សន្ធិសញ្ញាថ្ងៃទី 11 ខែសីហា ឆ្នាំ 1863 និងការចូលត្រួតត្រាកម្ពុជា

### 1.1. ស្ថានភាពប្រទេសកម្ពុជា

នៅសតវត្សទី 19 ប្រទេសខ្មែរស្ថិតនៅក្រោមអំណាចត្រួតត្រាយួន និងសៀម ។ នៅក្នុងរាជ្យព្រះបាទអង្គឌួង(1841-1860) សៀម និងយួននៅប្រចាំការអមព្រះអង្គដើម្បីសម្រេចរាជកិច្ចជំនួសស្ដេចខ្មែរ ។ ចំពោះទង្វើគាបសង្កត់បែបនេះ ព្រះបាទអង្គឌួងខិតខំរកគ្រប់មធ្យោបាយដើម្បីរំដោះប្រទេសចេញពីយួន និងសៀម ។



*ព្រះបាទនរោត្តម (គ.ស. 1861-1904)*

នៅឆ្នាំ 1854 ព្រះអង្គឌួងបានឱ្យរាជទូតខ្មែរទៅទាក់ទងនឹងកុងស៊ុលបារាំងនៅសិង្ហបុរី ប៉ុន្តែពុំបានសម្រេចដូចបំណង ព្រោះសៀមបានដឹងព័ត៌មាននេះ និងគំរាមព្រះអង្គថា "បើព្រះអង្គព្រមចុះសន្ធិសញ្ញាសម្ព័ន្ធភាពជាមួយបារាំងដែលមានដឺម៉ុងទីញីជាតំណាងនោះ សៀមនឹងលើកទ័ពចូលមកកម្ទេចខ្មែរជាពុំខាន" ។ ដូចនេះ ការចុះសន្ធិសញ្ញាសម្ព័ន្ធភាពបារាំង-ខ្មែរត្រូវផ្អាក ។ នៅថ្ងៃទី 19 ខែតុលា ឆ្នាំ 1860 ព្រះបាទអង្គឌួងក៏ចូលទិវង្គត ។ រាជបុត្រច្បងរបស់ព្រះអង្គនាមសត្ថាប្រឡឹងឡើងគ្រងរាជសម្បត្តិស្នងដោយមាននាមសម្រាប់រាជ្យថា ព្រះបាទនរោត្តម ។

ក្នុងឆ្នាំ 1861 មានចលនាបះបោរដឹកនាំព្រះអង្គម្ចាស់ស៊ីវត្ថា គាំទ្រដោយស្នងសួរ និងកំហែងយុទ្ធាបានលើកទ័ពមកវាយដល់ភ្នំពេញ ព្រះបាទនរោត្តមបានភៀសខ្លួនទៅក្រុងបាងកកដោយយកទាំងបញ្ចក្សេត្រទៅជាមួយផង ។ នៅឆ្នាំ 1862 សៀមបាននាំព្រះអង្គមកស្រុកខ្មែរវិញ ដោយសម្លាប់កំហែងយុទ្ធ ចំណែកស៊ីវត្ថាភៀសខ្លួនទៅឡាវ រួចសុគតនៅឆ្នាំ 1892 ។

## 1.2. ស្ថានភាពនយោបាយបារាំង

នៅគ. ស. 1862 លោកឧត្តមនាវីត្រីបូណា (Bonard) ទេសាភិបាលនៃដែនដីកូសាំងស៊ីនបានធ្វើដំណើរមកប្រទេសខ្មែរ ដោយបំណងចង់ស្គាល់ស្ថានភាពប្រទេសនេះ ។ ឆ្លៀតឱកាសនេះ លោកទេសាភិបាលក៏បានចូលគាល់សម្តេចព្រះនរោត្តម ព្រះអង្គបានទទួលលោកយ៉ាងរាក់ទាក់ ។ ទេសាភិបាលរូបនេះយល់ថា ប្រទេសបារាំងមានសិទ្ធិលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរ ហើយកិច្ចការចាំបាច់របស់បារាំងគឺត្រូវការពារប្រទេសនេះដែលជាប់ទាក់ទងទៅនឹងសន្តិសុខនៃដែនដីកូសាំងស៊ីន ។ ម្យ៉ាងទៀត បារាំងកម្ចាត់ឱ្យអស់នូវឧបាយកលសម្ងាត់ទាំងឡាយរបស់សៀមដែលអាចគំរាមកំហែងដល់ផលប្រយោជន៍របស់ខ្លួននៅឥណ្ឌូចិន ។ នៅឆ្នាំ 1863 លោកទេសាភិបាលកូសាំងស៊ីនថ្មីឈ្មោះដឺឡាហ្គ្រង់ឌីយ៉ែរបានទូលពីបំណងបារាំងសព្វគ្រប់ដល់ព្រះរាជាខ្មែរដើម្បីឱ្យព្រះអង្គព្រមដាក់ប្រទេសខ្មែរឱ្យបារាំងជួយការពារ ។ បារាំងបានថ្វាយនូវគម្រោងសន្ធិសញ្ញាមួយ ហើយនៅថ្ងៃទី 11 ខែសីហា ឆ្នាំ 1863 លោកឌឺឡាហ្គ្រង់ឌីយ៉ែរបានចុះហត្ថលេខាក្នុងនាមលោកផ្ទាល់លើសន្ធិសញ្ញាមិត្តភាពការពារ និងពាណិជ្ជកម្មមួយជាមួយសម្តេចព្រះនរោត្តមដែលបានទទួលយល់ព្រមទាំងរារែកព្រះទ័យ ។ សន្ធិសញ្ញាលើកទី 1 នេះជាសន្ធិសញ្ញាដាក់ប្រទេសខ្មែរក្រោមអាណាព្យាបាលរបស់បារាំង ។

សន្ធិសញ្ញាថ្ងៃទី 11 ខែសីហា ឆ្នាំ 1863 ត្រូវផ្ញើទៅប្រទេសបារាំងដើម្បីសុំសច្ចាប័នពីព្រះចៅអធិរាជបារាំងណាប៉ូឡេអុងទី 3 ។ ក្នុងចន្លោះពេលដែលបារាំងមិនទាន់អនុម័តលើសន្ធិសញ្ញានេះ សៀមចេះតែឱ្យតំណាងខ្លួនមកគំរាមកំហែងព្រះបាទនរោត្តមជាញឹកញយ ។

ព្រះបាទនរោត្តមទ្រង់បានធ្វើសន្ធិសញ្ញាសម្ងាត់មួយជាមួយព្រះចៅសៀមចុះថ្ងៃទី 01 ខែធ្នូ ឆ្នាំ 1863 ដោយទទួលស្គាល់ថា ប្រទេសកម្ពុជាជាសាមន្តរដ្ឋរបស់សៀមដដែល និងយល់ព្រមលះបង់ឱ្យប្រទេសសៀមនូវខេត្តបាត់ដំបង អង្គរ មង្គលបុរី សិរីសោភ័ណ កំពង់ស្វាយ និងពោធិ៍សាត់ ។ លុះបារាំងបានដឹងរឿងនេះ ក៏បង្ខំយកពីសៀមមកវិញ ។

នៅខែមីនា ឆ្នាំ 1864 សន្ធិសញ្ញាខ្មែរ-បារាំងត្រូវបានផ្ញើត្រឡប់ពីបារាំងមកវិញ ។ ផ្អែកលើសន្ធិសញ្ញានេះ លោកទេសាភិបាលបារាំងនៅកូសាំងស៊ីនបានតម្រូវឱ្យព្រះចៅសៀមបញ្ជូនគ្រឿងសម្រាប់រាជ្យមកក្រុងឧដុង្គយ៉ាងឆាប់រហ័ស ហើយធ្វើពិធីអភិសេកព្រះបាទនរោត្តមនៅថ្ងៃទី 3 ខែមិថុនា ឆ្នាំ 1864 ។ ប្រទេសកម្ពុជាបានធ្លាក់ក្នុងកណ្តាប់ដៃបារាំងវិញ ។

## 1.3. ខ្លឹមសារសន្ធិសញ្ញាថ្ងៃទី ១១ ខែសីហា ឆ្នាំ 1863

- ព្រះចៅអធិរាជនៃប្រទេសបារាំងមានសិទ្ធិ និងផ្ដល់នូវការការពារដល់ព្រះរាជាខ្មែរ ។
- ព្រះចៅអធិរាជនៃប្រទេសបារាំងនឹងតែងតាំងរេស៊ីដង់ម្នាក់ដែលមានឋានៈជាមន្ត្រីជាន់ខ្ពស់ឱ្យនៅអមព្រះរាជាខ្មែរ ឯព្រះរាជាខ្មែរនឹងតែងតាំងរេស៊ីដង់ខ្មែរម្នាក់ឱ្យនៅអមលោកទេសាភិបាលកូសាំងស៊ីនវិញ ។
- កប៉ាល់បារាំងមានសេរីភាពពេញលេញក្នុងការធ្វើជំនួញក្នុងដែនទឹកខ្មែរដោយមិនបង់ពន្ធអ្វីទាំងអស់ លើកលែងតែពន្ធអាភៀន ។ ឯកប៉ាល់ខ្មែរមានសិទ្ធិគ្រប់គ្រាន់ក្នុងការធ្វើជំនួញក្នុងកំពង់ផែទាំងឡាយនៃដែនដីកូសាំងស៊ីនវិញដែរ ។
- រដ្ឋាភិបាលខ្មែរត្រូវសន្យាថានឹងការពារពួកអ្នកផ្សាយសាសនា ពួកអ្នកប្រាជ្ញបារាំង និងជនជាតិបារាំងជាទូទៅដែលរស់នៅ ឬធ្វើជំនួញក្នុងទឹកដីខ្មែរ ។ ចំណែកជនជាតិខ្មែរដែលរស់នៅក្នុងទឹកដីជាកម្មសិទ្ធិរបស់បារាំងនឹងត្រូវបានទេសាភិបាលនៃទឹកដីនោះការពារវិញដែរ ។
- ព្រះចៅអធិរាជបារាំងសន្យាថានឹងរៀបចំឱ្យប្រទេសកម្ពុជាបានស្ថិតក្នុងសន្តិភាព និងរបៀបរៀបរយ និងការពារចំពោះការវាយលុកទាំងឡាយមកពីខាងក្រៅ ។ បារាំងជួយខ្មែរក្នុងការដកហូតពន្ធគយ និងផ្ដល់ភាពងាយស្រួលក្នុងការធ្វើគមនាគមន៍តាមសមុទ្រ ។
- ជាថ្នូរវិញ ប្រទេសកម្ពុជាព្រមឱ្យសម្បទានដល់ប្រទេសបារាំងនូវដីត្រង់តំបន់ជ្រោយចង្វាដើម្បីស្ថាបនាឃ្លាំងផ្ទុកធ្យូងថ្ម ឃ្លាំងសម្រាប់ផ្ដល់ស្បៀងដល់កប៉ាល់បារាំង និងបន្ទាយសម្រាប់ទាហានស្នាក់នៅ ។ បើកសិទ្ធិឱ្យបារាំងកាប់ឈើក្នុងព្រៃទាំងឡាយសម្រាប់ស្ថាបនាកប៉ាល់ ។

ដូច្នេះ ទោះបីភាគីខ្មែរចាញ់ប្រៀបខាងភាគីបារាំងខ្លះក៏ដោយ ក៏បារាំងពុំទាន់ដកហូតអំណាចពីព្រះរាជាខ្មែរទាំងស្រុងនៅឡើយ ។

## 1.4. ចលនាតស៊ូនឹងការត្រួតត្រារបស់បារាំង

ទោះបីសន្ធិសញ្ញាថ្ងៃទី 11 ខែសីហា ឆ្នាំ 1863 ផ្ដល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមកក៏ដោយ ក៏មានអ្នកស្នេហាជាតិបានក្រោកឈរកាន់អាវុធប្រឆាំងនឹងការប៉ុនប៉ងដាក់និមអាណានិគមរបស់បារាំងក្នុងការត្រួតត្រាប្រទេសខ្មែរដែរ ។ នៅឆ្នាំ 1864 លោកអាចារ្យស្វាបានភៀសខ្លួនទៅបង្កទ័ព និងបានវាយយកខេត្តទ្រាំង ហើយបន្តឆ្ពោះមកភ្នំពេញទៀត ។ នៅខែឧសភា 1866 លោកពោធិ៍កំបោរមានដើមកំណើតនៅខេត្តរោងដំរី បានភៀសខ្លួនមកខេត្តរោងដំរី ហើយបង្កទ័ពទៅវាយបារាំង ។ ខែធ្នូ ឆ្នាំ 1866 លោកបានលើកទ័ពឆ្ពោះទៅរាជធានីឧដុង្គ ។ ចលនាតស៊ូរបស់អ្នកអង្គម្ចាស់ស៊ីវត្ថាប្រឆាំងបារាំង ។ ប៉ុន្តែចលនាតស៊ូទាំងនោះត្រូវទទួលបរាជ័យទាំងអស់ ។

### 1.5. សន្ធិសញ្ញាបារាំង-សៀម ថ្ងៃទី 15 ខែកក្កដា ឆ្នាំ 1867

ថ្ងៃទី 15 ខែកក្កដា ឆ្នាំ 1867 ស្តេចសៀម និងព្រះចៅអធិរាជបារាំងបានធ្វើសន្ធិសញ្ញារួមគ្នាមួយ ។ តាមរយៈសន្ធិសញ្ញានេះ ស្តេចសៀមទទួលស្គាល់ជាឱឡារិកនូវអាណាព្យាបាលភាពរបស់បារាំងមកលើប្រទេសកម្ពុជា ។ ចំណែកបារាំងបានសន្យាថា មិនវាយយកប្រទេសខ្មែរទៅបញ្ចូលក្នុងអាណានិគមរបស់ខ្លួនទេ ហើយបានទទួលស្គាល់ថា ខេត្តបាត់ដំបង អង្គរ និងសិរីសោភ័ណស្ថិតនៅក្រោមការត្រួតត្រារបស់សៀម ។ នៅឆ្នាំ 1867ដដែល ព្រះបាទនរោត្តមទ្រង់បានលើករាជធានីពីឧដុង្គទៅតាំងនៅភ្នំពេញវិញ ។

## 2. អនុសញ្ញាថ្ងៃទី 17 ខែមិថុនា ឆ្នាំ1884 និងការធ្វើអាណានិគម

### 2.1. កំណែទម្រង់ទូទៅ

ព្រះបាទនរោត្តមបានសម្រេចព្រះទ័យធ្វើកំណែទម្រង់នយោបាយតាមព្រះរាជបញ្ញត្តិចុះថ្ងៃទី 15 ខែមករា ឆ្នាំ 1877 ក្រោយពីបានចរចាជាច្រើនលើកជាមួយតំណាងប្រទេសបារាំងដើម្បីអភិវឌ្ឍប្រទេសឱ្យបានរីកចម្រើនលូតលាស់ទាន់សម័យនឹងគេ ។

គម្រោងការកំណែទម្រង់ទាំងអស់ពុំបានទទួលជោគជ័យទាំងស្រុងទេ ។ ផ្ទុយទៅវិញ ការអនុវត្តត្រូវជួបឧបសគ្គជាច្រើនបណ្តាលមកពីប្រតិកម្មពីសំណាក់មន្ត្រីជាច្រើន និងពួកមេបំណុល ។ ដោយទទួលរបាយការណ៍មិនរលូន រដ្ឋាភិបាលបារាំងក៏មានការមន្ទិលសង្ស័យទៅលើសុឆន្ទៈរបស់ព្រះរាជា ។ លោកហ្ស៊ូល ហ្វេរី (Jules Ferry) ជានាយករដ្ឋមន្ត្រីបារាំងបានសម្រេចចិត្តថាត្រូវតែងតាំងអាណាព្យាបាលពិតប្រាកដលើប្រទេសខ្មែរ ជំនួសការការពារដែលមានតាំងពីមុនមក ។ នៅថ្ងៃទី 17 ខែមិថុនា ឆ្នាំ 1884 លោកសាល ថុមសុន (Charles Thomson) បានចតកប៉ាល់នៅមុខព្រះរាជវាំងភ្នំពេញ ហើយមកបង្ខំឱ្យព្រះបាទនរោត្តម ដែលកំពុងផ្ទុំឱ្យចុះហត្ថលេខាលើអនុសញ្ញាមួយដែលបានដកហូតអំណាចទាំងអស់ពីព្រះអង្គ ។ ខ្លឹមសារនៃមាត្រាទាំងអស់មានដូចជា ៖

- ព្រះមហាក្សត្រត្រូវទទួលស្គាល់នូវកំណែទម្រង់ផ្នែករដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មដែលសាធារណរដ្ឋបារាំងយល់ថា គួរតែធ្វើក្នុងអនាគតកាល ។
- ក្នុងការគ្រប់គ្រងខេត្ត និងក្រសួងនានា មន្ត្រីខ្មែរត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាណាព្យាបាលបារាំង ។
- គ្រប់ក្រសួងដែលមានប្រើវិស្សុករ គឺបារាំងកាន់កាប់ដោយផ្ទាល់ ។
- រដ្ឋាភិបាលបារាំងអាចតែងតាំងរេស៊ីដង់ និងរេស៊ីដង់រងឱ្យត្រួតពិនិត្យមន្ត្រីខ្មែរនៅទីរួមខេត្ត ។

- ចំណាយទាំងឡាយរបស់រាជការខ្មែរ និងរបស់រដ្ឋការអាណាព្យាបាលបារាំងជាបន្ទុករបស់ប្រទេសកម្ពុជា ។
- ព្រះរាជាត្រូវទទួលប្រាក់បៀវត្សរ៍ដែលមានកម្រិតជាក់លាក់ ហើយមិនអាចខ្ចីប្រាក់ដោយគ្មានការយល់ព្រមពីរដ្ឋាភិបាលបារាំងឡើយ ។
- ពិធីក្នុងព្រះរាជាណាចក្រទាំងមូល ពីដើមជាកម្មសិទ្ធិផ្ដាច់មុខរបស់ព្រះមហាក្សត្រ ឥឡូវអាជ្ញាធរបារាំង និងខ្មែរអាចរៀបចំឱ្យមានកម្មសិទ្ធិឯកជនខាងពិធីបាន ។
- ក្រុងភ្នំពេញត្រូវគ្រប់គ្រងដោយមន្ត្រីបារាំងម្នាក់ អមដោយក្រុមប្រឹក្សាមួយមានសមាជិកជាជនជាតិបារាំង 6នាក់ ជនបរទេស 4នាក់(ចិន ចាម និងវៀតណាម) និងខ្មែរ 3នាក់ ។

ក្រោយអនុសញ្ញាថ្ងៃ 17 ខែមិថុនា ឆ្នាំ 1884 ព្រះរាជាខ្មែរត្រូវបាត់បង់អំណាចស្វ័យភាពក្នុងការគ្រប់គ្រងស្ទើរទាំងស្រុង ។ ដូច្នេះ ព្រះបាទនរោត្តមបានរកមធ្យោបាយគ្រប់យ៉ាងដើម្បីរំដោះប្រទេសរបស់ព្រះអង្គឱ្យរួចពីការត្រួតត្រារបស់អាណានិគមបារាំង ។ ចំណែកប្រជាពលរដ្ឋខ្មែរ ក៏មានប្រតិកម្មយ៉ាងខ្លាំងក្លាចំពោះអនុសញ្ញាថ្ងៃទី 17 ខែមិថុនា ឆ្នាំ 1884 នេះដែរ ។

### 2.2. អនុសញ្ញាថ្ងៃទី 26 ខែមករា ឆ្នាំ 1887

អនុសញ្ញានេះបានផ្ដល់អំណាចយ៉ាងទូលាយថែមទៀតដល់តំណាងប្រទេសបារាំងនៅអមព្រះរាជាខ្មែរ ដោយអនុញ្ញាតឱ្យបារាំងចូលរួមក្នុងកិច្ចប្រជុំទាំងឡាយរបស់គណៈរដ្ឋមន្ត្រីដើម្បីផ្ដល់យោបល់ផ្សេងៗ ។ ក្នុងករណីដែលមានការសំខាន់ត្រូវដោះស្រាយនោះ វត្តមានរបស់តំណាងប្រទេសបារាំងជាការចាំបាច់ ។

## 3. បញ្ហាដែនដីកម្ពុជាក្រោម ឬកូសាំងស៊ីន

នៅរវាងឆ្នាំ 1856 និង 1862 បារាំងបានចូលវាយយកទីក្រុងព្រៃនគរនិងខេត្តបីទៀតនៅជុំវិញក្រុងនេះ ។ នៅឆ្នាំ 1862 ព្រះចៅធូឌិកគ្មានសមត្ថភាពទប់ទល់ជាមួយបារាំង ព្រមចុះហត្ថលេខាលើសន្ធិសញ្ញាមួយទទួលស្គាល់ការកាន់កាប់របស់បារាំងលើក្រុងព្រៃនគរ និងខេត្តទាំងបីនោះ ។ ក្រោយពីបានតាំងខ្លួនធ្វើជាអ្នកជិតខាង បារាំងបានចូលមកពាក់ព័ន្ធជាមួយព្រះរាជាខ្មែរព្រះបាទនរោត្តម ។

- នៅឆ្នាំ 1864 ព្រះបាទនរោត្តមអមដោយលោកឌូដា ដឺឡាហ្គ្រេ (Doudart de Lagrée) បានយាងទៅជួបលោកទេសាភិបាលដឺឡាហ្គ្រង់ឌីយេនៅព្រៃនគរ ហើយធ្វើសំណូមពរឱ្យបារាំងបង្វិលសងខេត្តទាំងបីមកខ្មែរវិញ គឺលង់ហោរ មាត់ជ្រូក និងពាម ។ ឯបារាំងបានទទួលពាក្យពីព្រះអង្គរឿងនេះហើយ ។ ប៉ុន្តែនៅ គ.ស. 1867 ខេត្តទាំងបីនេះជាកន្លែងយួនធ្វើសកម្មភាព

ប្រឆាំងបារាំង ពួកគេបានវាយយកខេត្តទាំងបីនេះ ហើយបញ្ចូលខេត្តទាំង 6រួមគ្នាបង្កើតជាដែនដីរបស់ខ្លួនឈ្មោះកូសាំងស៊ីន ដោយបំភ្លេចពាក្យសន្យាជាមួយព្រះបាទនរោត្តម ។

ដូចនេះចាប់ពីឆ្នាំ 1867 ទឹកដីកម្ពុជាក្រោមទាំងមូលក្លាយជាអាណានិគមរបស់បារាំង ឯកម្ពុជាលើតាមលក្ខន្តិកៈជាប្រទេសក្រោមអាណាព្យាបាល ។ ម្ល៉ោះហើយ អាជ្ញាធរបារាំងនៅកូសាំងស៊ីនតែងតែធ្វើការកែប្រែបន្ទាត់ព្រំដែនតាមទំនើងចិត្ត ដោយសំអាងលើបញ្ហានយោបាយ និងសេដ្ឋកិច្ច ។ សកម្មភាពធ្វើការកែប្រែរដ្ឋបាលសុទ្ធតែចំណេញទឹកដីទៅខាងកូសាំងស៊ីនជានិច្ច ។ បារាំងមិនអើពើដល់ការតវ៉ារបស់ព្រះរាជាខ្មែរ ឬស្នើសួរព្រះរាជយោបល់ឡើយ ។

ចាប់ពីឆ្នាំ 1893 ដល់ 1914 ប្រទេសខ្មែរត្រូវបាត់បង់ទឹកដីថែមទៀតព្រមទាំងកោះក្នុងសមុទ្រភាគខាងត្បូង ដូចជាកោះត្រឡាចជាដើម ។ បារាំងកេងប្រវ័ញ្ចយកតំបន់រដ្ឋបាលទាំងនោះទៅបញ្ចូលក្នុងអាណានិគមកូសាំងស៊ីន ។ នៅទីបំផុតដែនដីរដ្ឋបាលទាំងនោះត្រូវធ្លាក់ក្រោមការគ្រប់គ្រងរបស់ប្រទេសអាណ្ណាមទាំងអស់ ។

## ? សំណួរ

1. នៅក្នុងរាជព្រះបាទអង្គឌួង តើទ្រង់បានសម្រេចបំណងក្នុងការរើបម្រះចេញពីការជ្រៀតជ្រែករបស់យួន និងសៀមឬទេ ? ព្រោះអ្វី ?
2. ហេតុដូចម្ដេចបានជាបារាំងអាចចូលទាក់ទងជាមួយព្រះបាទនរោត្តមបាន ?
3. តើសន្ធិសញ្ញាថ្ងៃទី 11 ខែសីហា ឆ្នាំ 1863 មានអត្ថន័យជារួមដូចម្ដេច ? តើមានចលនាតស៊ូរបស់ប្រជារាស្ត្រខ្មែរចំពោះការត្រួតត្រារបស់បារាំងដែរឬទេ ? វីរភាពបុព្វបុរសស្នេហាជាតិរូបណាអ្នកពេញចិត្តជាងគេ ? ព្រោះអ្វី ?
4. ក្រោយពីសន្ធិសញ្ញាថ្ងៃទី 11 ខែសីហា ឆ្នាំ 1863 តើមានកិច្ចព្រមព្រៀងអ្វីទៀតដែរឬទេ ? ដើម្បីអ្វី ?
5. តើអនុសញ្ញាថ្ងៃទី 17 ខែមិថុនា ឆ្នាំ 1884 មានអត្ថន័យជារួមដូចម្ដេច ? តើមានកិច្ចព្រមព្រៀងអ្វីទៀតដែរឬទេ ? តើអ្នកពេញចិត្តដែរឬទេ ? ពីព្រោះអ្វី ?

# 2 សម័យសង្គមរាស្ត្រនិយម (១៩៥៥_១៩៧០)

**ចប់មេរៀននេះ សិស្សអាច**

- អធិប្បាយនយោបាយក្នុង និងក្រៅប្រទេស វិស័យសេដ្ឋកិច្ច វប្បធម៌ និងសង្គមកិច្ចក្នុងសម័យសង្គមរាស្ត្រនិយម
- វិភាគពីការអភិវឌ្ឍជាតិ និងភាពរុងរឿងក្នុងសម័យសង្គមរាស្ត្រនិយម
- អនុវត្តតាមគំរូល្អរបស់មេដឹកនាំដែលធ្វើឱ្យប្រទេសរីកចម្រើន សុខសន្តិភាព និងសម្បូររុងរឿង ។

ប្រទេសកម្ពុជាសម័យសង្គមរាស្ត្រនិយមឋិតនៅក្រោមការដឹកនាំរបស់សម្តេចព្រះនរោត្តមសីហនុ ។ ព្រះអង្គទ្រង់ប្រសូតនៅថ្ងៃទី 31 ខែតុលា ឆ្នាំ 1922 ជាព្រះរាជបុត្ររបស់ព្រះបាទនរោត្តមសុរាម្រិត និងព្រះមហាក្សត្រីយានី ស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្នសិរីវឌ្ឍនា ។



*សម្តេចព្រះនរោត្តមសីហនុ*

## 1. នយោបាយក្នុងប្រទេស

ក្រោយបានឯករាជ្យនៅថ្ងៃទី 9 ខែវិច្ឆិកា ឆ្នាំ 1953 ប្រទេសកម្ពុជាត្រូវប្រឈមមុខនឹងឧបសគ្គជាច្រើន គឺការកសាង និងស្តាបនាប្រទេសជាតិឡើងវិញ ។ ក្នុងឋានៈព្រះអង្គជាព្រះមហាក្សត្រព្រះបាទនរោត្តមសីហនុ ទ្រង់បានព្រោសប្រទានដល់ប្រជារាស្ត្រនូវរដ្ឋធម្មនុញ្ញលើកដំបូងបង្អស់ នៅថ្ងៃទី 6 ខែឧសភា ឆ្នាំ 1947 ក្នុងគោលបំណងកសាងប្រទេសជាតិឱ្យទៅជាកោះសន្តិភាព ។ រដ្ឋធម្មនុញ្ញនេះត្រូវបានកែលម្អជាបន្តបន្ទាប់ រហូតមកទល់នឹងការទម្លាក់ព្រះអង្គ នៅឆ្នាំ 1970 ។

សម្តេចព្រះនរោត្តមសីហនុបានដាក់រាជ្យសម្បត្តិនៅថ្ងៃទី 3 ខែមីនា ឆ្នាំ 1955 ក្នុងរាជបំណងផ្សារភ្ជាប់ទំនាក់ទំនងទៅនឹងប្រជារាស្ត្រ ។ ព្រះបិតាព្រះអង្គដែលគ្រងរាជ្យបន្ត បានថ្វាយនូវឋានៈចំពោះព្រះអង្គជា "សម្តេចព្រះឧបយុវរាជនៃកម្ពុជា" ។ នៅថ្ងៃទី 24 ខែមីនា ឆ្នាំ 1955 ព្រះអង្គបានបង្កើតចលនាមហាជនដ៏ទូលំទូលាយមួយមានឈ្មោះថា "សង្គមរាស្ត្រនិយម" ប្រជារាស្ត្រខ្មែរចំនួន 99.80% សម្តែងឆន្ទៈគាំទ្រ ។ ចលនាសង្គមរាស្ត្រនិយមបានធ្វើឱ្យមានកម្លាំងឯកភាព និងចូលរួមគ្រប់និន្នាការ គណបក្សនយោបាយ ដូចជាគណបក្សរាជានិយម ប្រជាធិបតេយ្យ និងឆ្វេងនិយមបានរំសាយខ្លួន ចូលមករួមក្នុងចលនានេះ ។

អាស្រ័យហេតុនេះហើយ ទើបចលនាសង្គមរាស្ត្រនិយមបានទទួលជោគជ័យយ៉ាងធំធេងក្នុងការបោះឆ្នោតបង្កើតស្ថាប័ននីតិប្បញ្ញត្តិនៅឆ្នាំ 1955 ដោយមានសំឡេងគាំទ្រពីសំណាក់ប្រជាពលរដ្ឋចំនួន 83% ។

ព្រះអង្គបានបង្កើតឱ្យមានសមាជជាតិដែលជាវេទិកាប្រជាធិបតេយ្យរបស់មហាជនដ៏ទូលំទូលាយ ដោយមានព្រះអង្គជាអ្នកដឹកនាំសកម្មភាពដោយផ្ទាល់ ។ នៅខែធ្នូ ឆ្នាំ 1957 សមាជជាតិត្រូវដាក់បញ្ចូលនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ព្រះអង្គបានបង្កើតចលនា "យុវជនរាជសង្គមនិយមខ្មែរ" ដែលជាកម្លាំងមួយរបស់ប្រទេស បន្ថែមលើកងជីវពលនារីក្លាហាន ដែលមានតាំងពីសម័យទាមទារឯករាជ្យឆ្នាំ 1953 ។

## 2. នយោបាយក្រៅប្រទេស

ប្រទេសកម្ពុជាបានចូលជាសមាជិកពេញសិទ្ធិរបស់អង្គការសហប្រជាជាតិ នៅថ្ងៃទី 14 ខែធ្នូ ឆ្នាំ 1955 អាស្រ័យដោយកិត្យានុភាពដ៏ត្រចះត្រចង់នៃព្រះរាជាណាចក្រកម្ពុជា ។

សម្តេចព្រះនរោត្តមសីហនុបានប្រកាន់ខ្ជាប់នូវនយោបាយអព្យាក្រិត និងមិនចូលបក្សសម្ព័ន្ធ ហើយរួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសផ្សេងៗលើពិភពលោក ។

នៅក្នុងសេចក្តីប្រកាសសុឆន្ទៈនយោបាយអព្យាក្រិតរបស់សម្តេចនរោត្តមសីហនុ ទ្រង់បានបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជាមិនប្រើអាវុធក្នុងការដោះស្រាយទំនាស់ជាមួយប្រទេសដទៃឡើយ ។ ប៉ុន្តែ ដរាបណាមានការគំរាមកំហែងដោយយោធាបរទេសណាមួយនោះមកលើប្រទេសកម្ពុជា ព្រះរាជាណាចក្រកម្ពុជានឹងប្រើសិទ្ធិការពារខ្លួនដើម្បីការពារឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ខ្លួន តាមរយៈការប្រកាសសុំជំនួយជាអាវុធពីអង្គការសហប្រជាជាតិ និងប្រទេសជាមិត្ត ។

នៅថ្ងៃទី 16 ខែ ឧសភា ឆ្នាំ 1955 មានការចុះហត្ថលេខាស្តីពីការសុំជំនួយយោធា និងសេដ្ឋកិច្ចរវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរដ្ឋាភិបាលកម្ពុជា ។ ប៉ុន្តែជំនួយនេះ សហរដ្ឋអាមេរិកបានផ្តល់ឱ្យតែរដ្ឋាភិបាលណាដែលប្រឆាំងនឹងចលនាកុម្មុយនីស្ត ។ ជំនួយបែបនេះ ធ្វើឱ្យប៉ះពាល់ដល់នយោបាយអព្យាក្រិតភាពនៃកម្ពុជា ។

ព្រះអង្គបានយាងទៅចូលរួមក្នុងសន្និសីទកំពូលអាហ្វ្រិក អាស៊ី លើកទី 1 នៅទីក្រុងបានឌុង ប្រទេសឥណ្ឌូណេស៊ី ដើម្បីពង្រឹង និងពង្រីកខ្លឹមសារនយោបាយក្រៅប្រទេស ហើយនៅទីនោះព្រះអង្គប្រកាសពីអព្យាក្រិតភាពរបស់ព្រះរាជាណាចក្រកម្ពុជា ។

នៅឆ្នាំ 1956 នៅទីក្រុងប្រ៊ីយ៉ូនី សាធារណរដ្ឋសហព័ន្ធសង្គមនិយម យូហ្គោស្លាវី ព្រះអង្គបានឡាយព្រះហស្តលេខាជាមួយប្រធានាធិបតីទីតូ បន្ទាប់មកជាមួយប្រធានាធិបតីណាស៊ែរ នៃសាធារណរដ្ឋអារ៉ាប់រួម ប្រធានាធិបតីស៊ូការណូនៃប្រទេសឥណ្ឌូណេស៊ី នាយករដ្ឋមន្ត្រីនេរុនៃប្រទេសឥណ្ឌាលើធម្មនុញ្ញនៃចលនាមិនចូលបក្សសម្ព័ន្ធ ។ ដូចនេះ ព្រះអង្គជាស្ថាបត្យករមួយរូបនៃចលនានេះ ។ ព្រះអង្គត្រូវបានសមាជិកសភាជាតិបោះឆ្នោតជ្រើសតាំងជាឯកច្ឆន្ទ ជាប្រមុខរដ្ឋកម្ពុជានៅឆ្នាំ 1960 ក្នុងឱកាសដែលព្រះបិតាព្រះអង្គចូលទិវង្គត ។ ពីដើមឆ្នាំ 1960 រហូតដល់ 1970 សហរដ្ឋអាមេរិកធ្វើការជ្រៀតជ្រែកមកលើប្រទេសកម្ពុជាឥតឈប់ឈរ ។ នៅឆ្នាំ 1961 ព្រះអង្គបានយាងចូលក្នុងសន្និសីទនៃប្រទេសមិនចូលបក្សសម្ព័ន្ធ នៅទីក្រុងបែលក្រាតប្រទេសយូហ្គោស្លាវី ។

ស្នាព្រះហស្តមួយទៀតរបស់សម្តេចព្រះនរោត្តមសីហនុ គឺការប្ដឹងតុលាការអន្តរជាតិទាមទារយកដី និងប្រាសាទព្រះវិហារ ដែលប្រទេសថៃបានបញ្ជូនកម្លាំងទ័ពចូលមករំលោភកាន់កាប់ដោយខុសច្បាប់ ចាប់តាំងពីឆ្នាំ 1954 មកឱ្យមាតុភូមិ និងប្រជារាស្ត្រខ្មែរវិញនៅថ្ងៃទី 15 ខែមិថុនា ឆ្នាំ 1962 ។

នៅថ្ងៃទី19 ខែវិច្ឆិកា ឆ្នាំ 1963 រាជរដ្ឋាភិបាលបានទាត់ចោលជំនួយសហរដ្ឋអាមេរិក ហើយនៅថ្ងៃទី 3 ខែ ឧសភា ឆ្នាំ 1965 ផ្ដាច់ចំណងការទូតជាមួយសហរដ្ឋអាមេរិកថែមទៀត ។

នៅថ្ងៃទី 23 ខែ តុលា ឆ្នាំ 1961 រាជរដ្ឋាភិបាលកម្ពុជាបានបង្ខំផ្ដាច់ទំនាក់ទំនងខាងការទូតជាបណ្ដោះអាសន្នជាមួយថៃ និងកាត់ផ្ដាច់ទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាមខាងត្បូង នៅថ្ងៃទី 27 ខែសីហាឆ្នាំ1963 ដើម្បីឆ្លើយតបទៅនឹងការឈ្លានពានបូរណភាពដែនដី និងការកាប់សម្លាប់ ឆក់ប្លន់ប្រជារាស្ត្រខ្មែរស្លូតត្រង់នៅតាមព្រំដែន ដោយមិនគោរពច្បាប់អន្តរជាតិ ។

# 3. សមិទ្ធផលសម័យសង្គមរាស្ត្រនិយម

## 3.1. វិស័យកសិកម្ម

សម្តេចព្រះនរោត្តមសីហនុបានយកព្រះទ័យទុកដាក់លើគោលនយោបាយពង្រីកដីកសិកម្ម ការជ្រើសរើសពូជស្រូវ ការប្រើជីធម្មជាតិគួបផ្សំនឹងជីគីមី ការធ្វើនយោបាយទឹក ការពង្រីកផ្នែកគមនាគមន៍ និងទេសចរណ៍ ធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើនខ្លាំង ។ នៅឆ្នាំ 1955 ផលស្រូវនៅប្រទេសកម្ពុជាមានចំនួន 1 484 000 តោន ហើយកើនឡើងដល់ 3 250 000 តោននៅឆ្នាំ 1968 ។

ក្នុងឆ្នាំ 1955 ផលិតផលកៅស៊ូមាន 25 000 តោន ។ ចំនួននេះបានកើនឡើងដល់ 51 000 តោនក្នុងឆ្នាំ 1968 ។ នៅឆ្នាំ 1964 ផលកប្បាសមាន 5 000 តោន នៅក្នុងចំនួននេះ 2 000 តោនសម្រាប់រោងចក្រវាយនភ័ណ្ឌក្នុងប្រទេស និង 3 000 តោនទៀតសម្រាប់នាំចេញ ។

រាជរដ្ឋាភិបាលបានចាប់ផ្តើមធ្វើយុទ្ធនាការឃោសនាអំពីការចាក់ថ្នាំបង្ការ និងពង្រីកវិស័យចិញ្ចឹមសត្វឱ្យមានការរីកចម្រើន ជាពិសេសនៅតាមជនបទដែលជាប្រភពម្ហូបអាហារ និងការនាំចេញ ។ ដើម្បីរក្សាកម្លាំងអូសទាញឱ្យបានល្អ រាជរដ្ឋាភិបាលបានចាត់ក្រុមបសុពេទ្យ ឱ្យចាក់ថ្នាំបង្ការរោគរាតត្បាតដល់សត្វពាហនៈ គ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ។

ដោយមានការព្រួយបារម្ភពីភាពរាំងស្ងួត សម្តេចព្រះប្រមុខរដ្ឋទ្រង់បានបង្កើតឱ្យមានកម្មវិធីរុក្ខទិវា នៅគ្រប់ខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ។ វិស័យនេសាទមានការរីកចម្រើនជាលំដាប់ អាចធានាលើកស្ទួយជីវភាពប្រជាពលរដ្ឋផង និងនាំចេញផង ។



*កសិករកំពុងប្រមូលផលស្រូវ*

## ៣.2. វិស័យគមនាគមន៍

នៅឆ្នាំ 1955 រាជរដ្ឋាភិបាលបានពង្រីកកំពង់ផែនៅភ្នំពេញនិងបានកសាងកំពង់ផែសមុទ្រមួយនៅក្រុងព្រះសីហនុ ហើយបានពង្រីកថែមទៀតនៅឆ្នាំ 1964 ។

នៅឆ្នាំ 1958 ពង្រីកអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង និងកសាងអាកាសយានដ្ឋានថ្នាក់អន្តរជាតិ ក្នុងខេត្តសៀមរាប សម្រាប់ពង្រីកវិស័យទេសចរណ៍ជាតិ និងអន្តរជាតិ ។

នៅឆ្នាំ 1960 បានស្ថាបនាផ្លូវរថភ្លើងភ្ជាប់ពីភ្នំពេញទៅក្រុងព្រះសីហនុ និងកសាងស្ពានដ៏ទំនើបមួយកាត់បឹងទន្លេសាប គឺស្ពានជ្រោយចង្វារ ។ ឆ្នាំ 1961 បានពង្រីកទំនាក់ទំនងអន្តរជាតិ ដោយភ្ជាប់ខ្សែទូរស័ព្ទជាមួយក្រុងតូក្យូ សាន់ហ្វ្រាន់ស៊ីស្កូ អូសាកា ... ។ល ។

## ១.១. វិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម

រាជរដ្ឋាភិបាលបានជំរុញការកសាងរោងចក្រមួយចំនួន មានរោងចក្រវាយនភ័ណ្ឌនៅកំពង់ចាម រោងចក្រក្តារបន្ទះនៅដីឥដ្ឋខេត្តកណ្តាល រោងចក្រក្រដាសនៅឆ្លូងខេត្តក្រចេះ រោងចក្រស៊ីម៉ងត៍ នៅចក្រីទីងខេត្តកំពត រោងចក្របាវក្រចៅនៅដូនទាវខេត្តបាត់ដំបង រោងចក្រស្ករសនៅកំពង់ត្រាំខេត្តកំពង់ស្ពឺ រោងចក្រកែវ និងកៅស៊ូក្នុងខេត្តកណ្តាល រោងចក្រដំឡើងត្រាក់ទ័រ រោងចក្រចម្រាញ់ប្រេងកាត និងរោងចក្រស្រាបៀរនៅក្រុងព្រះសីហនុ។ ក្រៅពីនេះស្ថាបនាទំនប់វារីអគ្គិសនីនៅស្ទឹងប្រាលគីរីរម្យ និងនៅព្រែកត្នោតក្នុងខេត្តកំពង់ស្ពឺ។

វិស័យពាណិជ្ជកម្មបាននាំចេញនូវផលិតផលកសិកម្មដូចជា ស្រូវ កៅស៊ូ ឈើ ត្រី សត្វពាហនៈ ម្រេច ពោត សណ្តែក ហើយនាំចូលនូវផលិតផលសម្រាប់បម្រើឧស្សាហកម្មមានគ្រឿងចក្រ ឧបករណ៍អគ្គិសនី គ្រឿងបន្លាស់ គ្រឿងបរិក្ខារសុខាភិបាល ។ល។



*រោងចក្រកង់ឡាន តាខ្មៅ*

## ៣.៤. វិស័យវប្បធម៌

រាជរដ្ឋាភិបាលបានពង្រីកវិស័យវប្បធម៌ ដោយកសាងអគារសិក្សា បណ្តុះបណ្តាលបុគ្គលិកសិក្សាគ្រប់ភូមិសិក្សា ។ ផ្នែកសិក្សាបច្ចេកទេសបានរួមចំណែកយ៉ាងសកម្មក្នុងការធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានវឌ្ឍនភាព ។ ផ្នែកឧត្តមសិក្សាត្រូវបានពង្រីកជាលំដាប់ ។ នៅថ្ងៃទី 13 ខែមករា ឆ្នាំ1960 សាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវបានបង្កើតឡើង និងមានមហាវិទ្យាល័យជាច្រើនដូចជា មហាវិទ្យាល័យនីតិសាស្ត្រ មហាវិទ្យាល័យវេជ្ជសាស្ត្រ មហាវិទ្យាល័យវិទ្យាសាស្ត្រ មហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រជាដើម ។ ការបញ្ជូននិស្សិតឱ្យទៅសិក្សានៅបរទេស និងទទួលនិស្សិតបរទេសមករៀននៅក្នុងប្រទេសត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ ។ នៅឆ្នាំ 1957 រាជរដ្ឋាភិបាលបានស្ថាបនាអគារនៅបូរីសកលវិទ្យាល័យនាទីក្រុងប៉ារីសអស់ទឹកប្រាក់ 45 លានរៀលសម្រាប់និស្សិត និងកម្មសិក្សាការីស្នាក់នៅ ។

ក្នុងផែនការ 5ឆ្នាំរបស់ព្រះអង្គ (1960-1965) មានគោលការណ៍ពង្រីកសមត្ថភាពបុគ្គលិកសិក្សាឱ្យបានប្រសើរ ព្រមទាំងពង្រីកមធ្យមសិក្សា ឧត្តមសិក្សា ជាពិសេសការសិក្សាបច្ចេកទេសឱ្យកាន់តែរីកចម្រើនឡើង ។ ក្នុងក្របខ័ណ្ឌជំនួយ ព្រះអង្គបានបែងចែកមួយភាគធំសម្រាប់វិស័យសិក្សាធិការ ។

រាជរដ្ឋាភិបាលបានអញ្ជើញគ្រូបង្វឹកមកពីអន្តរជាតិសម្រាប់កីឡាបាល់ទាត់ កីឡាបាល់បោះ កីឡាអត្តពលកម្ម កីឡាវាយសីដើម្បីពង្រឹងនិងពង្រីកវិស័យកីឡា ជាពិសេស ការបង្កើតពហុដ្ឋានជាតិកីឡាអូឡាំពិក ដែលអាចទទួលទស្សនិកជនបានចំនួន 50 000 នាក់ ។ វិស័យសាសនារដ្ឋាភិបាលបានខិតខំផ្សព្វផ្សាយលទ្ធិពុទ្ធសាសនាយ៉ាងទូលំទូលាយ ដោយបង្កើតឱ្យមានសាលាបាលី ចាប់ពីពុទ្ធិកបឋមសិក្សារហូតដល់មហាវិទ្យាល័យ ។

## ៣.៥. វិស័យសង្គមកិច្ច

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើបញ្ហាសុខភាពជាចម្បងព្រមទាំងបានបំផុសឱ្យពលរដ្ឋចូលរួមសកម្មភាពក្នុងការថែទាំសុខភាព ដែលក្នុងនោះមានយុទ្ធនាការចាក់ថ្នាំបង្ការរោគរាតត្បាត ការអនុវត្តក្បួនអនាម័យ ការសិក្សាពីវិធានការការពារ និងព្យាបាលជំងឺជាដើម សកម្មភាពកំឡុង 5ឆ្នាំនៃការងារសុខាភិបាល(ឆ្នាំ 1961 )គឺ ៖

- ការចាក់ថ្នាំការពារ : ជំងឺអុតសម្រេចបាន 174 043 នាក់ ជំងឺអាសន្នរោគសម្រេចបាន 1 340 នាក់ ជំងឺគ្រុញចាញ់សម្រេចបាន 636 408 នាក់
- ការឃោសនាអប់រំ : ការចូលសម្អាតភូមិដ្ឋានបាន 14 ភូមិ ចាក់ធ្វើបឋកថាស្ដីពីអនាម័យបាន 187 លើក ។
- ការកសាងមន្ទីរពេទ្យ សាលារៀន វិទ្យាស្ថានស្រាវជ្រាវវេជ្ជសាស្ត្រជាមូលដ្ឋានសម្រាប់អនុវត្តកិច្ចការថែទាំសុខាភិបាល ។
- បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាចំពោះការបណ្ដុះបណ្ដាលអ្នកឯកទេសពេទ្យគ្រប់ផ្នែក ព្រមទាំងបញ្ជូនឱ្យទៅសិក្សានៅបរទេស ។
- ការរៀបចំទីក្រុង ការឈូសឆាយបង្កើតភូមិ និងសង់លំនៅស្ថានជូនប្រជារាស្ត្រ ការសង់អគារសាធារណៈ ការជីកអណ្ដូង ស្រះ ប្រឡាយ ដើម្បីឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋ ។ល ។



*ពហុកីឡដ្ឋានជាតិអូឡាំពិក*

ដើម្បីបង្ការការរាំងស្ទះដល់ដំណើរការអភិវឌ្ឍសង្គមជាតិ រាជរដ្ឋាភិបាលបានបង្កើតឱ្យមានគណៈកម្មការជាតិ បំបាត់អំពើពុករលួយដែលមានសម្ដេចព្រះសីហនុចូលរួមផ្ទាល់ក្នុងកិច្ចបោសសំអាតអំពើពុករលួយ និងអំពើអសកម្មនានា ។ សមាសភាពនៃគណៈកម្មការជាតិ រួមមានទីប្រឹក្សាជាន់ខ្ពស់នៃរាជបល្ល័ង្កមួយរូប តំណាងប្រជារាស្ត្រ 3រូប សមាជិកនៃក្រុមប្រឹក្សាព្រះរាជាណាចក្រ 2រូប រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គាធិការខាងកិច្ចការព្រះរាជាណាចក្រ និងតំណាងមួយរូបឬច្រើនរូបនៃគណៈកម្មាធិការការពារកិត្តិយសនៃក្រុមរាជការព្រះរាជាណាចក្រកម្ពុជា ដែលមានសម្ដេចព្រះនរោត្តម សីហនុជាប្រធាន ។ ព្រះរាជកិច្ចដឹកនាំផ្ទាល់នេះ ចាប់ផ្ដើមឡើងនៅឆ្នាំ 1961 ។

## ? សំណួរ

1. ប្រទេសកម្ពុជាសម័យសង្គមរាស្ត្រនិយមដឹកនាំដោយអ្នកណា ? ពីឆ្នាំណាដល់ឆ្នាំណា ?
2. ចូរស្រង់ព្រឹត្តិការណ៍សំខាន់ៗមកបញ្ជាក់តាមកាលបរិច្ឆេទ ចំពោះនយោបាយក្នុង និងក្រៅប្រទេសនាសម័យសង្គមរាស្ត្រនិយម ?
3. តើគេចាត់ទុកប្រទេសកម្ពុជាក្នុងសម័យសង្គមរាស្ត្រនិយមជាប្រទេសដូចម្ដេច ? តើអ្នកពេញចិត្តសម័យនោះទេ ? ព្រោះអ្វី ?
4. នៅឆ្នាំ 1955 តើគណបក្សនយោបាយណាខ្លះដែលរំសាយខ្លួនចូលជាមួយសង្គមរាស្ត្រនិយម ? ហើយការបោះឆ្នោតបង្កើតស្ថាប័ននីតិប្បញ្ញត្តិទទួលលទ្ធផលដូចម្ដេច ?

# 3 សម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)

**ចប់មេរៀននេះ សិស្សអាច**

- យល់ដឹងពីការចូលកាន់អំណាចនៃសាធារណរដ្ឋខ្មែរ(1970-75) និងផលវិបាក
- រកមូលហេតុនៃការរលំរលាយរបស់របបសាធារណរដ្ឋខ្មែរ
- ស្រលាញ់សន្តិភាព និងការអភិវឌ្ឍ ស្អប់ខ្ពើមសង្គ្រាម ។

នៅដើមឆ្នាំ 1970 សម្ដេចនរោត្តមសីហនុមិនបានស្ថិតនៅក្នុងប្រទេសកម្ពុជា ដោយព្រះអង្គបានចេញទៅសម្រាក និងព្យាបាលជំងឺនៅប្រទេសបារាំង រួចយាងទៅសហភាពសូវៀត ។ ក្នុងឱកាសនោះឧត្តមសេនីយ៍លន់ នល់ នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលស្រោចស្រង់ជាតិ ព្រះអង្គម្ចាស់ស៊ីសុវត្ថិសិរីមតៈ និងបក្សពួកបានធ្វើសេចក្ដីប្រកាសស្ដីពីការផ្ដួលរំលំព្រះអង្គពីអំណាចនៅថ្ងៃទី 18 ខែមីនា ឆ្នាំ 1970 ។ ស្ថានភាពទូទៅនៅក្នុងប្រទេសកម្ពុជាស្ថិតក្នុងភាពវឹកវរយ៉ាងខ្លាំង ។

## 1. ការឈានចូលកាន់អំណាចនៃរបបសាធារណរដ្ឋខ្មែរ

### 1.1. ស្ថានភាពនយោបាយក្នុងប្រទេសមុនរដ្ឋប្រហារ

ជុំវិញវិបត្តិនយោបាយតាំងពីឆ្នាំ 1967 ជាពិសេសនៅពាក់កណ្ដាលឆ្នាំ 1969 វិបត្តិថវិកាជាតិនៃប្រទេសបានកើនឡើងដល់កម្រិតខ្ពស់បំផុត គឺឡើងដល់ 1.500 លានរៀល ជាវិបត្តិដែលបានធ្វើឱ្យរាជរដ្ឋាភិបាលស្ថិតនៅចំពោះមុខនៃស្ថានភាពដួលរលំនៃថវិការបស់ប្រទេស ។ វិបត្តិហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរនេះបានបណ្ដាលឱ្យមជ្ឈដ្ឋានអ្នកប្រឆាំងក្នុងប្រទេសកម្រើកឡើងយ៉ាងខ្លាំង ដោយទាមទារឱ្យចាប់ផ្ដើមរៀបចំកម្មវិធីទទួលជំនួយអាមេរិក ព្រមទាំងធ្វើឱ្យនយោបាយជិតដិតជាមួយអាមេរិកឡើងវិញ ។

នៅក្នុងសម័យប្រជុំសមាជជាតិដែលធ្វើឡើងនៅខែកក្កដា ឆ្នាំ 1969 អង្គប្រជុំបានអនុម័តលើសេចក្ដីសម្រេចផ្ដល់សេចក្ដីទុកចិត្តថ្វាយសម្ដេចព្រះនរោត្តមសីហនុបង្កើតរដ្ឋាភិបាលថ្មីមួយជាបន្ទាន់ដែលមានលទ្ធភាពធានាដល់ការជំនះលើវិបត្តិសេដ្ឋកិច្ច និងនយោបាយក្នុងរយៈពេលយ៉ាងខ្លី ។ នៅខែសីហា ឆ្នាំ 1969 សម្ដេចព្រះនរោត្តមសីហនុបានទទួលយល់ព្រមបង្កើតរដ្ឋាភិបាលថ្មីឈ្មោះ "រដ្ឋាភិបាលស្រោចស្រង់ជាតិ" ដឹកនាំដោយលោក លន់ នល់ និងព្រះអង្គម្ចាស់ស៊ីសុវត្ថិសិរីមតៈ ។

សកម្មភាពរបស់ពួកប្រឆាំងក្នុងប្រទេសបានកម្រើកឡើងយ៉ាងខ្លាំងគួរក្រោយការតែងតាំងលោក លន់ នល់ ជាប្រមុខរដ្ឋាភិបាល(ខែសីហា 1969)។ ពួកគេទាំងនេះបានឈានដល់ដំណាក់កាលមួយនៅក្នុងការដណ្ដើមអំណាចឱ្យស្ថិតនៅក្នុងកណ្ដាប់ដៃបក្សពួកខ្លួនទាំងស្រុង ។

## 1.2. ស្ថានភាពនយោបាយសហរដ្ឋអាមេរិក

ក្រោយរដ្ឋប្រហារបានមួយថ្ងៃ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានធ្វើសេចក្ដីថ្លែងការណ៍ស្ដីពីការទទួលស្គាល់រដ្ឋអំណាចថ្មីនៅទីក្រុងភ្នំពេញ ដែលមានលោកលន់ នល់ និងព្រះអង្គម្ចាស់ សិរីមតៈជាអ្នកដឹកនាំ ។ នៅថ្ងៃទី 16 ខែមេសា ឆ្នាំ 1970 លោកលន់ នល់បានស្នើសុំឱ្យសហរដ្ឋអាមេរិកផ្ដល់ "ជំនួយយោធា" ជាគ្រឿងអាវុធយុទ្ធភណ្ឌ និងគ្រាប់រំសេវនានា ។ ចាប់ពីចុងខែមីនា ឆ្នាំ 1970 កងទ័ពព្រៃនគរបានវាយលុកចូលមកលើទឹកដីកម្ពុជាដើម្បីបង្ក្រាបភាពចលាចលរបស់បណ្ដាជនដែលបានក្រោកឈរឡើងការពារនយោបាយអព្យាក្រឹត ឯករាជ្យ និងបូរណភាពទឹកដី ។

ពិភពលោកទាំងមូលបានវាយតម្លៃលើសកម្មភាពទាំងនេះថាជាកិច្ចរៀបចំអន្តរាគមន៍ខាងនយោបាយដ៏ត្រង់របស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា ។ នៅថ្ងៃទី 30 ខែមេសា ឆ្នាំ 1970 កងទ័ពអាមេរិកព្រៃនគរបានចាប់ផ្ដើមវាយសម្រុកចូលទឹកដីប្រទេសកម្ពុជា ។ ដល់ចុងខែឧសភាចំនួនទាហានអន្តរាគមន៍បានកើនឡើងចំនួនដល់ 80 ពាន់នាក់ ។ ប្រតិបត្តិការរាតត្បាតដ៏ព្រៃផ្សៃបានរីកសាយទៅលើខេត្តចំនួន 10 នៅក្នុងប្រទេស ។ នៅពេលនោះកងនាវាអាមេរិកបានបិទចរាចរតាមឆ្នេរសមុទ្រប្រទេសកម្ពុជា ។

# 2. របបសាធារណរដ្ឋខ្មែរ

ក្នុងបំណងពង្រឹងគោលជំហររបស់ខ្លួន របបសាធារណរដ្ឋខ្មែរបានចាប់ផ្ដើមចាត់វិធានការមួយចំនួន ។ នៅទីក្រុងភ្នំពេញ គេបានបង្កើតបក្សនយោបាយបីគឺ បក្សសង្គមសាធារណរដ្ឋ បក្សប្រជាធិបតេយ្យ និងបក្សសាធារណរដ្ឋ ហើយលោកលន់ នល់បានធ្វើជាអ្នកដឹកនាំបក្សទីមួយ ។ នៅខែមីនា ឆ្នាំ 1972 លោកលន់ នល់បានរំលាយរដ្ឋសភា និងរដ្ឋាភិបាល ហើយបានប្រកាសខ្លួនថាជាប្រធានាធិបតីនៃសាធារណរដ្ឋ ។ នៅថ្ងៃទី 30 ខែមេសា ឆ្នាំ 1972 នៅទីក្រុងភ្នំពេញ គេបានធ្វើប្រជាមតិដើម្បីអនុម័តលើរដ្ឋធម្មនុញ្ញថ្មីដែលនៅក្នុងនោះគេបានចារិករបបនយោបាយប្រទេសយកឈ្មោះថា "សាធារណរដ្ឋ" ។ នៅថ្ងៃទី 30 ខែកក្កដា ឆ្នាំ 1972 មានការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ។ នៅថ្ងៃទី 3 ខែកញ្ញា ឆ្នាំ 1972 មានការជ្រើសរើសតំណាងរាស្ត្រសម្រាប់រដ្ឋសភា ហើយនៅថ្ងៃទី 17 ខែកញ្ញា ឆ្នាំ 1972 មានការបោះឆ្នោតជ្រើសរើសព្រឹទ្ធសភា ។ បក្សសង្គមសាធារណរដ្ឋបាន

ទទួលកន្លែងទាំងអស់នៅក្នុងរដ្ឋសភាជាតិ និងនៅព្រឹទ្ធសភា ។ នៅខែមេសា ឆ្នាំ 1973 នៅទីក្រុងភ្នំពេញមានការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ដែលមានលោកលន់ នល់ ជាប្រធាន ហើយនៅខែឧសភា "រដ្ឋាភិបាលវិសាមញ្ញមួយ" ត្រូវបានបង្កើតឡើង ។ នៅចុងខែមីនា ឆ្នាំ 1974 ក្រុមប្រឹក្សានយោបាយត្រូវរំសាយ គេបានបង្កើតក្រុមប្រឹក្សានីតិប្រតិបត្តិមួយជំនួសដែលមានលោកលន់ នល់ជាប្រធាន ។ ពួកសាធារណរដ្ឋបានប្ដេជ្ញាថា ជំរុញប្រទេសឱ្យទៅដល់ប្រជាធិបតេយ្យផ្នែកនយោបាយ និងសង្គមត្រូវបំបាត់ឱ្យអស់នូវអំពើជិះជាន់ សង្កត់សង្កិន និងអំពើខុះអព្យាស្រ័យដើម្បីឆ្ពោះទៅរកសុភមង្គល និងសម្បូរសប្បាយនៃប្រជាពលរដ្ឋខ្មែរ ។

## ១. ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងជ័យជំនះលើរបបសាធារណរដ្ឋខ្មែរ

នៅថ្ងៃទី 23 ខែមីនា ឆ្នាំ 1970 សម្ដេចនរោត្ដមសីហនុបានថ្លែងការណ៍នៅទីក្រុងប៉េកាំង ដោយប្រកាសមិនទទួលស្គាល់រដ្ឋាភិបាល និងរដ្ឋសភានៃរបបសាធារណរដ្ឋខ្មែរ ។ ព្រះអង្គបានប្រកាសពីបំណងចង់បង្កើតរណសិរ្សរួបរួមជាតិ និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា ។

គោលដៅរបស់រដ្ឋាភិបាលរួបរួមជាតិ គឺបង្រួបបង្រួមឯកភាពជាតិសម្រាប់ការតស៊ូប្រឆាំងអំពើឈ្លានពាននៃពួកចក្រពត្តិអាមេរិកដើម្បីផ្ដួលរំលំរបបសាធារណរដ្ឋខ្មែរ ហើយកសាងប្រទេសកម្ពុជាដ៏សម្បូររុងរឿងស្របតាមឆន្ទៈរបស់ប្រជាជនកម្ពុជា ។ នៅឆ្នាំ 1975 រណសិរ្សរួបរួមជាតិកម្ពុជាបានរំដោះ 90% នៃទឹកដីប្រទេសកម្ពុជាទាំងមូល ។

ពួកអាមេរិកបានទំលាក់ល្បងស្រោចស្រង់របបសាធារណរដ្ឋខ្មែរតាមការបង្កើតផ្លូវដែលហៅថា "ស្ពានអាកាស" ដែលភ្ជាប់អាកាសយានដ្ឋានពោធិ៍ចិនតុងនៅជាយក្រុងភ្នំពេញទៅនឹងមូលដ្ឋានសឹកអាមេរិកនៅវៀតណាមខាងត្បូង និងនៅថៃឡង់ដ៍ ។ តាមស្ពានអាកាសនេះហើយ ដែលពួកអាមេរិកបានផ្ដល់សៀង គ្រាប់រំសេវ ប្រេងឥន្ធនៈ អង្ករមកដល់ក្រុងភ្នំពេញ ។ ទោះបីយ៉ាងណា ការដួលរលំរបបសាធារណរដ្ឋខ្មែរមិនអាចជៀសផុតឡើយ ។

នៅថ្ងៃទី 1 ខែមេសា ឆ្នាំ 1975 លន់ នល់បានចាកចេញពីទីក្រុងភ្នំពេញជាមួយនាយទាហានជាន់ខ្ពស់ និងឧត្ដមសេនីយ៍ជាង 30 នាក់ ។ នៅថ្ងៃជាមួយគ្នានោះ ចំណុចយុទ្ធសាស្ត្រដ៏សំខាន់ចុងក្រោយមួយគឺអ្នកលឿងត្រូវកងកម្លាំងអ្នកស្នេហាជាតិវាយយកបាន ។

នៅថ្ងៃទី 11-12 ខែមេសា ឆ្នាំ 1975 ឯកអគ្គរដ្ឋទូតអាមេរិក(ឈ្មោះ ចនដៀន)បានប្រកាសឱ្យពលរដ្ឋអាមេរិកដែលនៅសេសសល់ចំនួន 82 នាក់ចាកចេញតាមឧទ្ធម្ភាគចក្រចំនួន 36 គ្រឿង ក្រោមកិច្ចការពាររបស់ទាហានជើងទឹកអាមេរិកចំនួន 350 នាក់ ។

នៅថ្ងៃទី 14 ខែមេសា ឆ្នាំ 1975 កងកម្លាំងស្នេហាមាតុភូមិបានដណ្ដើមយកអាកាសយានដ្ឋានពោធិ៍ចិនតុង ហើយនៅថ្ងៃទី 17 ខែមេសា ឆ្នាំ 1975 កងទ័ពរំដោះបានចូលដល់ទីក្រុងភ្នំពេញ ហើយទីក្រុងភ្នំពេញ និងទីរួមខេត្តដទៃទៀតក៏ត្រូវរំដោះជាបន្តបន្ទាប់ទូទាំងប្រទេស ។

## 4. ផលវិបាកនៃសង្គ្រាម

ជាលទ្ធផលនៃការប្រយុទ្ធដោយអាវុធ និងការទម្លាក់គ្រាប់បែករបស់អាមេរិក មានប្រជាជនកម្ពុជាជាង 1 លាននាក់បានបាត់បង់ជីវិត អ្នករបួស ក្មេងកំព្រា និងជនពិការជាច្រើននាក់ទៀត ។ ប្រជាពលរដ្ឋភៀសខ្លួនរាប់សែននាក់ គ្មានទីពឹង ព្រាត់ប្រាសគ្រួសារ ។ នៅក្នុងប្រទេស រោងចក្រឧស្សាហកម្ម 4/5 បានត្រូវបំផ្លិចបំផ្លាញ ចំការកៅស៊ូ 2/3 ត្រូវបាត់បង់ ផ្លូវថ្នល់ និងផ្លូវដែក 70-80% ត្រូវខូចខាត ហើយកំពង់ផែពាណិជ្ជកម្ម ទាំងទឹកសាប និងទឹកប្រៃទទួលការខូចខាតជាទម្ងន់ ។ នៅក្នុងតំបន់ខ្លះដែលស្ថិតក្រោមការត្រួតត្រារបស់សាធារណរដ្ឋខ្មែរ អសកម្មភាពផលិតផលខាងកសិកម្មទាំងស្រុង ចំណែកឧស្សាហកម្មបាត់បង់សមត្ថភាពផលិតរបស់ខ្លួន ឬមានសមត្ថភាពតិចតួចបំផុត បើប្រៀបធៀបទៅនឹងស្ថិតិនៃសម័យមុនសង្គ្រាម ។ មុនសង្គ្រាម ប្រទេសកម្ពុជាធ្លាប់នាំអង្ករទៅលក់នៅក្រៅប្រទេស ប៉ុន្តែប្រទេសនេះបានប្រែក្លាយជាប្រទេសនាំអង្ករចូលពីក្រៅប្រទេសវិញនៅសម័យសង្គ្រាម ។ ទំនិញចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃបានឡើងថ្លៃហួសកម្រិត អតិផរណា ប្រាក់រៀលចុះថ្លៃ ភាពឥតការងារធ្វើ អំពើពុករលួយក៏មានកម្រិតខ្ពស់ ។ ប្រទេសជាតិទាំងមូលជួបបញ្ហាច្របូកច្របល់ ខ្វះសណ្ដាប់ធ្នាប់ អចិរភាពនយោបាយ អនាធិបតេយ្យកើតមានស្ទើរគ្រប់ទីកន្លែង កូនទាហានបាត់បង់វិន័យ នាយទាហានរត់ចេញពីជួរកងទ័ព ហើយចុះចូលជាមួយកងកម្លាំងនៃអ្នកស្នេហាជាតិ ។

### ? សំណួរ

1. តើសង្គ្រាមផ្ដល់គុណវិបត្តិអ្វីខ្លះ ?
2. ក្រោយរដ្ឋប្រហារ 18 មីនា 1970 តើសម្ដេចនរោត្តមសីហនុទ្រង់បានធ្វើអ្វី ? ដើម្បីអ្វី ?
3. គោលដៅរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជាគឺធ្វើអ្វី ? តើបានសម្រេចឬទេ ?
4. ហេតុអ្វីបានជារបបសាធារណរដ្ឋខ្មែរត្រូវទទួលបរាជ័យ ?
5. តើសង្គ្រាមពីឆ្នាំ 1970-75 ផ្ដល់លទ្ធផលដូចម្ដេចខ្លះ ? តើប្អូនស្រលាញ់សង្គ្រាមឬទេ ? ព្រោះអ្វី ?

# 4 របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥_១៩៧៩)

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីការគ្រប់គ្រងប្រទេសរបស់ពួកខ្មែរក្រហមនៅកម្ពុជា
- ❑ ពន្យល់ពីចរិតផ្ដាច់ការរបស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជា
- ❑ វិភាគពីប្រជាធិបតេយ្យតែស្លាក ឬប្រជាធិបតេយ្យក្លែងក្លាយ ។

ថ្ងៃទី 17 ខែមេសា ឆ្នាំ 1975 កងទ័ពខ្មែរក្រហមបានវាយរំដោះក្រុងភ្នំពេញ និងទីរួមខេត្តនានា ។ ប្រជាជនក្រុងភ្នំពេញរីករាយអបអរសាទរនូវជ័យជំនះរបស់កងទ័ពខ្មែរក្រហមលើរបបសាធារណរដ្ឋខ្មែរ(របបលន់ នល់) ។ តែផ្ទុយទៅវិញ ពួកខ្មែរក្រហមបានគំរាមកំហែង និងបណ្ដេញប្រជាជនឱ្យចេញពីក្រុងភ្នំពេញដោយបង្ខំ ។

## 1. គោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ

ក្នុងការជម្លៀសប្រជាជនឱ្យចេញពីក្រុងភ្នំពេញ ពួកខ្មែរក្រហមបានកុហកថាឱ្យប្រជាជនចេញពីក្រុងភ្នំពេញតែ 3 ថ្ងៃទេ មិនបាច់យកអីវ៉ាន់ទៅទេ អង្គការចាំទទួលការហូបចុក ។

- អង្គការចង់បោសសំអាតក្រុងភ្នំពេញ
- ខ្លាចអាមេរិកទម្លាក់គ្រាប់បែក
- អង្គការគ្មានមធ្យោបាយដឹកស្បៀងអាហារឧបត្ថម្ភប្រជាជនក្រុងភ្នំពេញទេ ។

តាមពិតគោលការណ៍របស់ពួកខ្មែរក្រហមគឺ ៖

- ជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា
- លុបបំបាត់ផ្សារ និងរូបិយវត្ថុនានា
- កម្ទេចវត្តអារាម និងផ្សឹកព្រះសង្ឃឱ្យទៅធ្វើស្រែចំការ
- បិទសាលារៀនទូទៅ និងគ្រឹះស្ថានសិក្សាគ្រប់ជាន់ថ្នាក់
- ប្រហារជីវិតបញ្ញវន្ត មន្ត្រីរាជការក្នុងរបបចាស់ និងប្រជាជនស្លូតត្រង់
- បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស(ហូបរួម ដេករួម និងធ្វើការរួម)
- បណ្ដេញប្រជាជនវៀតណាម និងធ្វើសង្គ្រាមជាមួយវៀតណាម

- ផ្តាច់មនោសញ្ចេតនាប្តីប្រពន្ធ ឪពុកម្តាយ បងប្អូន និងគ្រួសារ ។

ក្រុមមេដឹកនាំខ្មែរក្រហមបានលើកសរសើរតាមរយៈមហាសន្និបាតជាតិលើកទី ៣ និងបានប្រកាសជាផ្លូវការនៅថ្ងៃទី 5 ខែមករា ឆ្នាំ 1976 ពីតួនាទីសំខាន់របស់ប្រជាជន ពិសេសកម្មករ កសិករដែលបានចូលរួមក្នុងសង្គ្រាមរំដោះជាតិ និងប្រជាជន ធ្វើពលិកម្មទាំងអាយុជីវិត ទាំងទ្រព្យសម្បត្តិ ទាំងមនោសញ្ចេតនា លះបង់កូនចៅ ប្តីសឹបម្រើសមរភូមិមុខគ្មានរួញរា ។ ម្យ៉ាងទៀត មហាសន្និបាតក៏បានលើកពីគុណបំណាច់ដ៏ធំធេងរបស់កងទ័ពបដិវត្តន៍កម្ពុជាទាំងបីប្រភេទ(ស្រួច តំបន់ និងឈ្លប) ដែលបានប្រយុទ្ធអង់អាចក្លាហានដើម្បីរំដោះជាតិ កសាងប្រទេសអព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ អធិបតេយ្យក្នុងបូរណភាពទឹកដីរបស់ខ្លួនក្នុងសង្គមជាតិមានសុភមង្គល យុត្តិធម៌ និងប្រជាធិបតេយ្យពិតប្រាកដ គ្មានអ្នកមាន គ្មានអ្នកក្រ គ្មានវណ្ណៈជិះជាន់គេ គ្មានវណ្ណៈត្រូវគេជិះជាន់ គឺជាសង្គមមួយដែលប្រជាជនរស់នៅដោយសុខដុមរមនា ។ មហាសន្និបាតជាតិពិសេសមួយទៀតដែលបើកសម័យប្រជុំថ្ងៃទី 25-26-27 ខែមេសា ឆ្នាំ 1975 បានឯកភាព និងអនុម័តលើគម្រោងរដ្ឋធម្មនុញ្ញមួយដែលមាន 16 ជំពូក ចែកជា 21 មាត្រា ។

ដូច្នេះកម្ពុជាប្រជាធិបតេយ្យមានរូបរាងជាស្ថាប័នជាតិពេញលេញដោយមានរដ្ឋាភិបាល សភា និងរដ្ឋធម្មនុញ្ញ តែប្រជាពលរដ្ឋខ្មែរទៅភាគច្រើនលើសលុបក្លាយជាទាសកររបស់អង្គការ ។

## 2. ការបែងចែកតំបន់រដ្ឋបាល

កម្ពុជាប្រជាធិបតេយ្យបានបែងចែកតំបន់រដ្ឋបាលនៃប្រទេសកម្ពុជាជាភូមិភាគ តំបន់ និងសមូហភាពមូលដ្ឋាន(ឃុំ និងភូមិ)

- ភូមិភាគបូព៌ា(203) : លេខាបក្សភូមិភាគ លោក សោ ភិម(សម្លាប់ឆ្នាំ 1978)មានខេត្តចំណុះ ស្វាយរៀង ព្រៃវែង កំពង់ចាមមួយផ្នែក និងក្រចេះមួយផ្នែក ហើយចែកជាតំបន់ 21-22-23 និង 24 ។
- ភូមិភាគនិរតី (405) : លេខាបក្សភូមិភាគ លោក ឈិត ជឿន ហៅតាម៉ុក(ស្លាប់ 2006)មានខេត្តចំណុះ កណ្តាល តាកែវ កំពត និងកំពង់ស្ពឺមួយផ្នែក ហើយចែកជាតំបន់ 13-25-33 និង 35 ។
- ភូមិភាគបស្ចិម (401) : លេខាបក្សភូមិភាគ លោក ជូ ជេត មានខេត្តចំណុះ កំពង់ស្ពឺមួយផ្នែក កំពង់ឆ្នាំង កំពង់សោម និងកោះកុង ហើយចែកជាតំបន់ 11-15-31-32 និង 37 ។
- ភូមិភាគពាយ័ព្យ (560) : លេខាបក្សភូមិភាគ លោក ញឹម រស់(សម្លាប់ឆ្នាំ 1978)មានខេត្តចំណុះ ពោធិ៍សាត់ និងបាត់ដំបង ។ ចែកជាតំបន់ 1-2-3-4-5-6 និង 7 ។

- ភូមិភាគឧត្តរ (303) ៖ លេខាបក្សភូមិភាគ លោក កុយ ធួន ហៅធុច(សម្រាប់ឆ្នាំ 1976)ដូរដាក់លោក កែ ពក ក្រោយមកដូរដាក់លោក កង ចាប(1977) មានខេត្តចំណុះ កំពង់ធំ សៀមរាប និងឧត្តរមានជ័យ ។ ចែកជាតំបន់ 41-42 និង 43 ។
- ភូមិភាគឦសាន (108) ៖ លេខាបក្សភូមិភាគ លោក ណៃ សារ៉ាន់ ហៅយ៉ា(សម្រាប់ 1976)មានខេត្តចំណុះ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែងមួយផ្នែក និងក្រចេះមួយផ្នែក ។ ចែកជាតំបន់ 101-102-104-105 – 107 និង 505 ។
- ភូមិភាគពិសេស ៖ ក្នុងសម័យសង្គ្រាមជាមួយ លន់ នល់ គឺក្រុងភ្នំពេញ និងតំបន់ជុំវិញ ។ ក្រោយជ័យជំនះ 17 មេសា 1975 ក្រុងភ្នំពេញ ខេត្តកំពង់ធំ និងសៀមរាបជាតំបន់ស្វយ័ត ។

## 3. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ និងបក្សកុម្មុយនីស្តកម្ពុជា

រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ និងការគ្រប់គ្រងក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្លែកទាំងស្រុងពីរបបគ្រប់គ្រងប្រទេសនានា និងរបបនយោបាយកម្ពុជាក្នុងសម័យមុនៗ ។ ក្នុងគោលបំណងបោកប្រាស់សាធារណមតិសកលលោកឱ្យឃើញថារបបនេះបានធ្វើការរៀបចំបោះឆ្នោត បង្កើតអំណាចទាំងបីតាមគោលការណ៍បែងចែកអំណាចគឺ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ ប៉ុន្តែតាមពិត របបកម្ពុជាប្រជាធិបតេយ្យមានតែអង្គការកាន់អំណាចមួយប៉ុណ្ណោះដែលប្រមូលផ្តុំសុទ្ធតែពួកនិយមជ្រុលនៅគ្រប់លំដាប់ថ្នាក់ ដែលគេហៅថាអង្គការ ។ ពាក្យអង្គការមួយម៉ាត់គ្របដណ្តប់ទាំងបក្ស ទាំងនីតិប្បញ្ញត្តិ ទាំងនីតិប្រតិបត្តិ រួមទាំងអំណាចតុលាការផង ។

### 3.1. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ 1976-1978

- ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ឬប្រមុខរដ្ឋ ប៉ុល ពត ជានាយករដ្ឋមន្ត្រី
- នួន ជា ជាប្រធានសភាតំណាងប្រជាជនកម្ពុជា អៀងសារី ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស
- វន វេត ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
- សុន សេន ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ
- ចេង អន ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ... ។

### 3.2. រចនាសម្ព័ន្ធមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា (1976-1978)

- ប៉ុល ពត លេខាបក្ស
- នួន ជា អនុលេខាបក្ស
- សមាជិកបក្សមាន ៖ សោ ភឹម អៀង សារី សុន សេន ឈិត ជឿន(តាម៉ុក) វន វេត កែ ពក ញឹម រស់ ខៀវសំផន ... ។


ទង់ជាតិសម័យកម្ពុជាប្រជាធិបតេយ្យ

# 4. រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ

ចាប់ពីថ្ងៃទី 15 ដល់ 19 ខែធ្នូ ឆ្នាំ 1975 សេចក្តីព្រាងរដ្ឋធម្មនុញ្ញមួយត្រូវបានអនុម័តដែលមានសមាជិកចូលរួមចំនួន 1000នាក់ក្នុងមហាសន្និបាតជាតិនៅទីក្រុងភ្នំពេញ ហើយបានប្រកាសដាក់ឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី 15 ខែមករា ឆ្នាំ 1976តទៅ ។

ប្រទេសកម្ពុជាត្រូវប្តូរឈ្មោះជា "កម្ពុជាប្រជាធិបតេយ្យ" ។ រដ្ឋធម្មនុញ្ញបានបង្កើតសភាតំណាងប្រជាជនចំនួន 250អាសនៈ ដែលក្នុងនោះតំណាងឱ្យវណ្ណៈកសិករ 150រូប តំណាងឱ្យវណ្ណៈកម្មករពលករ 50រូប និងតំណាងឱ្យកងទ័ពបដិវត្តន៍កម្ពុជា 50រូប ។

រដ្ឋសភាបានបើកសម័យប្រជុំតែម្តងគត់នៅខែមេសា 1976 ។

ចម្រៀងជាតិ : ចម្រៀងជាតិឈ្មោះថា "17មេសាមហាជោគជ័យ"និពន្ធដោយប៉ុលពត ។

**ទង់ជាតិ(មាត្រាទី 16)** : ទង់ជាតិពណ៌ក្រហម មានរូបប្រាសាទអង្គរវត្តកំពូលបីពណ៌លឿងនៅកណ្តាល ។ ផ្ទៃទង់ជាតិពណ៌ក្រហមជានិមិត្តរូបនៃចលនាបដិវត្តន៍ការប្រយុទ្ធមោះមុត អង់អាចក្លាហានក្នុងការរំដោះជាតិ ការពារជាតិ និងកសាងជាតិកម្ពុជា ។ ប្រាសាទកំពូលបីពណ៌លឿងជានិមិត្តរូបនៃប្រពៃណីជាតិ និងប្រជាជនកម្ពុជាដែលជាអ្នកការពារ និងស្ថាបនាប្រទេសឱ្យថ្កុំថ្កើងរុងរឿង ។

**សញ្ញាជាតិ(មាត្រាទី 17)** : ប្រព័ន្ធស្រែ និងប្រឡាយទឹកជានិមិត្តរូបនៃកសិកម្មជឿនលឿន រោងចក្រជានិមិត្តរូបនៃឧស្សាហកម្មមាន កម្រងកួរស្រូវរាងជាស្វែងក្របីព័ទ្ធពីក្រៅ ហើយមានអក្សរ "កម្ពុជាប្រជាធិបតេយ្យ"នៅពីក្រោម ។

# 5. ជីវិតរស់នៅរបស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## 5.1. ការបង្កើតសហករណ៍

នៅអំឡុងសង្គ្រាមស៊ីវិលពីឆ្នាំ 1970-1975 ប្រជាជនភាគច្រើនរស់នៅតាមស្រុកស្រែចំការក្នុងតំបន់ខ្មែរក្រហមកាន់កាប់ បានបង្កើតក្រុមប្រវាស់ដៃដែលមានសមាជិកពី 10ទៅ 30គ្រួសារក្នុងមួយក្រុម ។ ក្រោយថ្ងៃរំដោះ 17 ខែមេសា ឆ្នាំ 1975 ក្រុមប្រវាស់ដៃនេះបានក្លាយជាសហករណ៍កម្រិតទាបដែលមានសមាជិកពី 300ទៅ 400នាក់ឬទាំងភូមិតែម្តង ។ នៅដើមឆ្នាំ 1977 សហករណ៍កម្រិតទាបនេះបានរៀបចំជា"សហករណ៍កម្រិតខ្ពស់"ដែលមានសមាជិកពីមួយភូមិទៅមួយឃុំ ។

មេដឹកនាំខ្មែរក្រហមបង្កើតសហករណ៍កម្រិតខ្ពស់នេះមានបំណងបំបាត់កម្មសិទ្ធិឯកជន និងរបបមូលធន ដើម្បីពង្រឹងវណ្ណៈកម្មករ និងកសិករ ។ ពួកខ្មែរក្រហមបានបង្ខំឱ្យប្រជាជនធ្វើការពី 12ម៉ោងទៅ 15ម៉ោងក្នុងមួយថ្ងៃ ឱ្យហូបតែបបររាវលាយត្រកួន ព្រលិត គល់ចេក គល់ល្ហុង ...។ គ្មានសម្លៀកបំពាក់សមរម្យ គ្មានជម្រក គ្មានថ្នាំសង្កូវ និងបំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាង ។ ប្រជាជនកម្ពុជាត្រូវរស់នៅរួមគ្នា ហូបរួមគ្នា និងធ្វើការរួមគ្នាដូចសម័យបុរាណកាល ។

## 5.2. វណ្ណៈសង្គម

ពួកខ្មែរក្រហមបានបង្កើតវណ្ណៈសង្គមនៅក្នុងការរស់នៅ :

- មូលដ្ឋានចាស់ : ប្រជាជនដែលរស់នៅស្រុកស្រែចំការតាំងពីសម័យសង្គ្រាមស៊ីវិល(1970-1975)គឺមុនថ្ងៃរំដោះ 17 មេសា 1975 ។ ពួកគេត្រូវបែងចែកជាពីរក្រុមទៀតគឺ ពួកពេញសិទ្ធិ (គ្មានបងប្អូនរស់នៅទីក្រុង ឬអង្គការកម្ទេចទេ) ពួកគេមានសិទ្ធិគ្រប់គ្រាន់ក្នុងការងារផ្សេងៗ ។ ក្រុមមួយទៀតគឺ ពួកត្រៀម(មានបងប្អូនធ្វើការ ឬរស់នៅទីក្រុង)ពួកគេទាំងនេះត្រូវខិតខំធ្វើការដើម្បីឡើងពេញសិទ្ធិ ។
- មូលដ្ឋានថ្មី(ប្រជាជនថ្មី) : ប្រជាជនដែលទើបនិងរំដោះចេញពីទីក្រុងភ្នំពេញ ជាពួកបញ្ញើក្អែក ឬពួក 17 មេសា ។ ពួកគេត្រូវពួកខ្មែរក្រហមប្រើឱ្យធ្វើការយ៉ាងធ្ងន់ធ្ងរ បង្អត់អាហារ និងយកទៅសម្លាប់ចោលដោយគ្មានកំហុសអ្វីសោះ ។

## 5.3. ពិធីមង្គលការ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានលុបបំបាត់ប្រពៃណី ទំនៀមទម្លាប់ សាសនា និងពិធីបុណ្យផ្សេងៗ ។ តែមង្គលការពួកខ្មែរក្រហមបានផ្សំផ្គុំពួកមូលដ្ឋានចាស់ ដោយមូលដ្ឋានចាស់ រីឯមូលដ្ឋានថ្មីនិងមូលដ្ឋានថ្មី មិនឱ្យលាយឡំគ្នាឡើយ ។

ពួកគេបានហៅឈ្មោះយុវជន យុវនារីចាប់ដៃគ្នាពី 5ទៅ 10គូ 40គូទៅ 100គូ ហើយប្ដេជ្ញាចិត្តចំពោះមុខអង្គការ និងទង់បក្ស ។ ពិធីរៀបការនេះធ្វើឡើងដោយមិនខាតពេលចូលស្ដី ថៃថ្ងៃ មិនខាតម្ហូបអាហារ មិនចាំបាច់ស្លៀកសម្លៀកបំពាក់ប្រពៃណី មានតែអាវខ្មៅ ខោខ្មៅ សំពត់ខ្មៅ ក្រមាបង់កជាការស្រេច ។ ការរួចឱ្យសម្រាកបានមួយថ្ងៃ រួចចូលធ្វើការបម្រើអង្គការវិញដោយរស់នៅបែកគ្នាតាមកងចល័តរៀងៗខ្លួន រយៈពេលមួយអាទិត្យ ឬមួយខែជួបគ្នាម្ដង ។ ជនណាប្រកែកមិនព្រមទទួលយកការរៀបចំឱ្យមានគ្រួសារនេះចាត់ទុកជាខ្មាំងប្រឆាំងអង្គការ អង្គការនិងកម្ទេចចោល ។

# 6. ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ

កត្តាសំខាន់ៗដែលបណ្ដាលឱ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ៖

- កត្តាប្រជាជន : ប្រជាជនមិនពេញចិត្តនិងរបបកម្ពុជាប្រជាធិបតេយ្យដែលធ្វើបាបកាប់សម្លាប់គ្មានត្រាប្រណី បង្អត់អាហារ ប្រើធ្វើការជាទម្ងន់ ខ្វះសម្លៀកបំពាក់ ផ្ទះសំបែង ថ្នាំសង្កូវព្យាបាល ដូច្នេះ ប្រជាជនកម្ពុជាលែងគាំទ្ររបបនេះតទៅទៀត ។

- **កត្តាវិសុទ្ធ** : កម្ពុជាប្រជាធិបតេយ្យលែងទុកចិត្តគ្នាឯងតាំងពីថ្នាក់មជ្ឈិម ភូមិភាគ តំបន់ រហូតដល់ឃុំ ភូមិ ។ ដូច្នេះ ឱ្យតែពួកគេសង្ស័យលើជនណាមួយ ឬក្រុមណាមួយ ពួកគេសម្លាប់ចោលទាំងអស់ ដូចពាក្យស្លោកពោលថា "សម្លាប់ច្រឡំ ជាជាងលែងច្រឡំ" "ទុកមិនចំណេញ ដកចេញមិនខាត" ។

  ក្នុងករណីនេះ ប៉ុល ពតបានសម្លាប់កុយ ធួន ញឹម រស់ វន វេត សោ ភឹម ... ដែលគេសង្ស័យថាក្បត់ ។

- **សង្គ្រាមជាមួយវៀតណាម** : នៅឆ្នាំ 1975 ពួកខ្មែរក្រហមបានបញ្ជូនទ័ពទៅព្រំដែនវៀតណាម ហើយធ្វើសង្គ្រាមរប៉េះរប៉ោះតាមព្រំដែន ។ នៅឆ្នាំ 1977 ពួកប៉ុល ពតបានបញ្ជូនប្រជាជនវៀតណាមឱ្យទៅស្រុកគេវិញ ព្រមទាំងបានធ្វើសង្គ្រាមឈ្លានពានទៅលើប្រទេសវៀតណាមថែមទៀត ។ នៅដើមឆ្នាំ 1978 កងទ័ពវៀតណាមបានប្រើកាំភ្លើងទំនើបនិងយន្តហោះវាយបកមកលើកងទ័ពប៉ុល ពតវិញ ។ នៅថ្ងៃទី 2 ខែធ្នូ ឆ្នាំ 1978 រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានបង្កើតឡើងដែលមានលោក ហេង សំរិនជាប្រធាន ។ កងទ័ពវៀតណាម សហការជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយកងទ័ពកម្ពុជាប្រជាធិបតេយ្យឱ្យដកថយ ហើយរំដោះក្រុងភ្នំពេញនៅថ្ងៃ 7 ខែមករា ឆ្នាំ 1979 ជាស្ថាពរ ។

## ? សំណួរ

1. តើរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើបាបប្រជាជនកម្ពុជាដូចម្តេចខ្លះ ?
2. តើគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យមានអ្វីខ្លះ ?
3. តើមូលហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ?
4. តើប្អូនយល់យ៉ាងណាចំពោះអំពើដ៏ព្រៃផ្សៃរបស់ពួកខ្មែរក្រហមមកលើប្រជាជនកម្ពុជា ?

មេរៀនទី

# 5 សាធារណរដ្ឋប្រជាមានិតកម្ពុជា-រដ្ឋកម្ពុជា (១៩៧៩_១៩៩១) ព្រះរាជាណាចក្រកម្ពុជា ១៩៩៣

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីព្រឹត្តិការណ៍ជ័យជំនះ 7មករា 1979
- ប្រៀបធៀបជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាក្នុងរបបប៉ុល ពតនិងរដ្ឋកម្ពុជា
- អប់រំស្មារតីសាមគ្គីភាព ឯកភាព ស្រឡាញ់សន្តិភាព តម្កល់ផលប្រយោជន៍ជាតិជាធំ។

របបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប៉ុល ពត បានធ្វើឱ្យប្រទេសកម្ពុជាធ្លាក់ដល់ក្រោមសូន្យ និងបានធ្វើឱ្យប្រជាជនខ្មែរគ្មានទំនុកចិត្ត បាក់ស្បាត តក់ស្លុត រស់ទាំងអស់សង្ឃឹម។ ថ្ងៃ 7 ខែមករា ឆ្នាំ 1979 ជាថ្ងៃរំដោះប្រជាជនកម្ពុជាឱ្យរួចផុតពីរបបឃោរឃៅព្រៃផ្សៃប្រល័យពូជសាសន៍ដ៏ខ្មៅងងឹត។

## 1. ការបង្កើតរណសិរ្សនិងជ័យជំនះ 7 ខែមករា ឆ្នាំ1979

### 1.1. ការបង្កើតរណសិរ្សសង្គ្រោះជាតិកម្ពុជា



លោក ហេង សំរិន

របបកម្ពុជាប្រជាធិបតេយ្យបានបង្ខំប្រជាជនកម្ពុជាឱ្យធ្វើការជាទម្ងន់ បង្អត់អាហារ គ្មានថ្នាំព្យាបាល ខ្វះសម្លៀកបំពាក់ គ្មានជម្រករស់នៅសមរម្យ បំបិទសិទ្ធិសេរីភាពគ្រប់យ៉ាង ពិសេសពួកឃាតករអាវខ្មៅបានសម្លាប់ប្រជាជនកម្ពុជាដោយគ្មានកំហុស។ របបនេះប្រៀបដូចគុកឥតជញ្ជាំងឬឋាននរក។ ដោយឃើញអំពើព្រៃផ្សៃបែបនេះហើយ កម្មាភិបាលខ្មែរក្រហមមួយចំនួនបានចេញមុខប្រឆាំង ប៉ុន្តែត្រូវមេដឹកនាំខ្មែរក្រហមសម្លាប់ដូចជា លោកហ៊ូ នឹម សម្លាប់នៅឆ្នាំ 1976 លោកកុយ ធួន លេខាបក្សភូមិភាគឧត្តរ សម្លាប់នៅឆ្នាំ 1976 ។ល។

នៅឆ្នាំ 1977 ប្រជាជនខេត្តសៀមរាប បាត់ដំបង កំពង់ធំ មណ្ឌលគិរី កំពង់ឆ្នាំង និងនៅចម្ការហ្លួងបានក្រោកឡើងបង្កចលនាប្រឆាំងនឹងខ្មែរក្រហម។ ចលនាបះបោររបស់ប្រជាជនបានធ្វើឱ្យអង្គការដឹកនាំគ្រប់លំដាប់ថ្នាក់របស់ខ្មែរក្រហមចាប់ផ្តើមសម្លាប់ប្រជាជនកាន់តែច្រើន និងគ្រប់កន្លែងទូទាំងប្រទេស ពិសេសភូមិភាគនិរតី ឧត្តរ ពាយ័ព្យ និងបូព៌ា។ ចលនាបះបោររបស់ប្រជាជនកម្ពុជាកើតមានកាន់តែធំឡើងៗ ហើយរីករាលដាលពាសពេញប្រទេស ដូចជាប្រជាជននៅស្រុកត្បូងឃ្មុំ (កំពង់ចាម) ស្រុកសៀមប៉ាង(ស្ទឹងត្រែង) ស្រុកបកែវ(រតនគិរី)ជាដើម។

នៅឆ្នាំ 1978 នៅភូមិភាគបូព៌ាសមមិត្ត ហេង សំរិន ជាមេបញ្ជាការកងពលធំលេខ 4 បានដឹកនាំកុបកម្មមួយប្រឆាំងនឹងខ្មែរក្រហម ។ ពួកកុបករទាំងអស់បានចេញបណ្ដឹងអំពាវនាវឱ្យប្រជាជនកម្ពុជាទាំងអស់គ្នាក្រោកឡើងរួមសាមគ្គីជាកម្លាំង ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅថ្ងៃទី 2 ខែធ្នូ ឆ្នាំ 1978 មហាសន្និបាតរបស់អ្នកស្នេហាជាតិគ្រប់តំបន់បានធ្វើឡើងនៅមូលដ្ឋានរំដោះ ។ មហាសន្និបាតបានសម្រេចជាឯកច្ឆន្ទបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការមជ្ឈិមរណសិរ្សដែលមានសមាជិក 14រូប ក្នុងនោះសមមិត្តហេង សំរិន ជាប្រធាន ។

មហាសន្និបាតបានអនុម័តកម្មវិធីនយោបាយដូចតទៅ ៖

- ផ្ដួលរំលំរបបប្រល័យពូជសាសន៍ខ្មែរក្រហម រំដោះប្រជាជនទូទាំងប្រទេសឱ្យរួចផុតពីរណ្ដៅមរណៈ
- គោរពឆន្ទៈ និងគោលបំណងរបស់ប្រជាជនកម្ពុជា
- កសាងប្រទេសកម្ពុជាប្រកបដោយសន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យ អព្យាក្រឹត បូរណភាពទឹកដី និងសម្បូររុងរឿង ។

ចាប់ពីពេលនោះមក កម្លាំងរណសិរ្សសង្គ្រោះជាតិកម្ពុជាកាន់តែរីកធំធាត់ និងខ្លាំងក្លាឡើងៗទាំងក្នុងនិងក្រៅប្រទេស ។

## 1.2. ជ័យជំនះថ្ងៃ 7 ខែមករា ឆ្នាំ 1979



*ទិដ្ឋភាពប្រជាជនវិលទៅកាន់ស្រុកកំណើតវិញ នៅថ្ងៃរំដោះ ៧ ខែមករា ឆ្នាំ 1979*

កងកម្លាំងប្រដាប់អាវុធរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដោយមានជំនួយពីកងទ័ពវៀតណាម និងទទួលការគាំទ្រពីប្រជាជនកម្ពុជាបានរួមកម្លាំងកម្ទេចកងទ័ពខ្មែរក្រហមរំដោះប្រជាជនកម្ពុជាបានជាបន្តបន្ទាប់ ។

- ថ្ងៃទី 30 ខែធ្នូ ឆ្នាំ 1978 រំដោះបានលំផាត់ ក្រចេះ រ៉ូនសែ ទន្លេបិទ ។
- ថ្ងៃទី 3-4 ខែមករា ឆ្នាំ 1979 រំដោះបានខេត្តស្វាយរៀងនិងស្ទឹងត្រែង ។
- ថ្ងៃទី 5-6 ខែមករា ឆ្នាំ 1979 រំដោះបានអ្នកលឿងនិងទីរួមខេត្តកំពង់ចាម ។
- ថ្ងៃទី 7 ខែមករា ឆ្នាំ 1979 រំដោះបានរាជធានីភ្នំពេញ(ម៉ោង 12:30នាទី) ខេត្តតាកែវនិងក្រុងកំពង់សោម(ព្រះសីហនុ) ។

នៅថ្ងៃទី 5-8 ខែមករា ឆ្នាំ 1979 មហាសន្និបាតជាតិលើកទី 3 បានប្រារព្ធឡើងដែលមានកម្លាំងរណសិរ្សចូលរួម 66នាក់ ។ មហាសន្និបាតបានអនុម័តកម្មវិធីសង្គ្រោះជាតិ និងរំដោះប្រទេសកម្ពុជាឱ្យបានទាំងស្រុង ។

- ថ្ងៃទី 10-11 ខែមករា ឆ្នាំ 1979 រំដោះបានខេត្តសៀមរាបនិងបាត់ដំបង ។
- ថ្ងៃទី 13-14-17 ខែមករា ឆ្នាំ 1979 រំដោះបានខេត្តពោធិ៍សាត់ កោះកុង... ។ល ។

ក្នុងរយៈពេលតែ 3 សប្តាហ៍ប៉ុណ្ណោះកងទ័ពរណសិរ្សនិងកងទ័ពវៀតណាមរំដោះប្រទេសកម្ពុជាស្ទើរតែទាំងស្រុងពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។

## 2. ការកសាងសង្គមជាតិឡើងវិញ

ក្រោយថ្ងៃរំដោះ 7 ខែមករា ឆ្នាំ 1979 ប្រជាជនកម្ពុជាបានរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយបាននាំគ្នាវិលទៅរកស្រុកកំណើតរៀងៗខ្លួន ប្រជាជនខ្លះបានភៀសខ្លួនទៅដល់ជាយដែនខ្មែរ-ថៃ និងប្រជាជនខ្លះទៀតរត់ចោលស្រុកកំណើតទៅដល់ប្រទេសទី 3 មាន អាមេរិក បារាំង អូស្ត្រាលីជាដើម ។ ប្រជាជនខ្លះបាត់បង់គ្រួសារ ប្តី ប្រពន្ធ កូនចៅ បងប្អូន និងឪពុកម្តាយ ។ល ។ ខ្លះបាត់បង់ជីវិតទាំងពូជតែម្តង ។ ប្រជាជនដែលនៅសេសសល់ច្រើនតែបាត់កម្លាំង ស្ត្រីមេម៉ាយ ក្មេងកំព្រា និងជនចាស់ជរា ។ ប្រជាជនដែលរស់រានមានជីវិតភាគច្រើនខ្វះខាតកម្លាំងអូសទាញ(គោ ក្របី) ក្នុងការធ្វើស្រែចម្ការ ឬជីកជញ្ជូន ។ ប្រឈមមុខនិងបញ្ហាទាំងនេះ រដ្ឋាភិបាលបានបង្វិចិត្តបង្កើតក្រុមសាមគ្គីបង្កបង្កើនផល ឬក្រុមប្រវាស់ដៃ ។

### 2.1. ក្រុមសាមគ្គីបង្កបង្កើនផល

នៅឆ្នាំ 1979 ក្រុមសាមគ្គីបង្កបង្កើនផលត្រូវបានបង្កើតឡើងនៅតាមភូមិ ឃុំ ទូទាំងប្រទេស ។ ក្រុមសាមគ្គីបង្កបង្កើនផលត្រូវបែងចែកកម្លាំងជាបីប្រភេទ "ធ្វើការតាមកម្លាំងពលកម្មនិងទទួលផលតាមកម្លាំងពលកម្ម" ។

- កម្លាំងទី 1 ឬកម្លាំងពេញ : មានបុរស ស្ត្រី យុវជន និងអ្នកកាន់នង្គ័ល
- កម្លាំងទី 2 ឬកម្លាំងមធ្យម : មានកុមារជំទង់និងគោ ក្របី
- កម្លាំងទី 3 ឬកម្លាំងខ្សោយ : មានចាស់ជរានិងកុមារតូចៗ

*ឧទាហរណ៍ :* កម្លាំងទី 1 ទទួលបានផលស្រូវ 1 បាវ កម្លាំងទី 2 ទទួលបានកាចបាវ កម្លាំងខ្សោយទទួលបានកន្លះបាវ ។

ក្រុមសាមគ្គីបង្កបង្កើនផលមានចំនួនគ្រួសារពី 10 ទៅ 20 ឬពី 20-40 គ្រួសារក្នុង 1 ក្រុមដែលអាចប្រែប្រួលទៅតាមខេត្តផ្សេងៗគ្នា ។ នៅឆ្នាំ 1980 ឬ 1981 រដ្ឋបានបង្កើតផ្សារលក់ដូរ និងប្រាក់ចាយ (ចាប់ពី 1 កាក់ 2 កាក់ 5 កាក់ 1 រៀលរហូតដល់ 50 រៀល) ដែលធ្វើឱ្យប្រជាជនខ្លះលះបង់ស្រែចម្ការនាំគ្នាទៅលក់ដូរតាមទម្លាប់ពីមុនមក ខ្លះទៀតធ្វើស្រែផង លក់ដូរផងតាមលទ្ធភាពរបស់ពួកគេ ។ នៅឆ្នាំ 1982 ដល់ 1985 ក្រុមសាមគ្គីបង្កបង្កើនផលត្រូវបានរំសាយ អាស្រ័យទៅតាមខេត្តឬតំបន់នានាទូទាំងប្រទេស ។

## 2.2. ទិន្នផលស្រូវប្រចាំឆ្នាំ

| ឆ្នាំ | ផ្ទៃដីធ្វើស្រែ គិតជាហិកតា | បរិមាណផលស្រូវគិតជាតោន |
|---|---|---|
| 1979 | 770 510 | 265 220 |
| 1980 | 1 444 470 | 1 715 310 |
| 1981 | 1 491 650 | 1 489 610 |
| 1982 | 1 680 350 | 1 989 200 |
| 1983 | 1 739 860 | 2 039 190 |
| 1984 | 1 416 780 | 1 258 250 |
| 1985 | 1 516 000 | 1 789 490 |
| 1986 | 1 618 140 | 2 086 080 |
| 1987 | 1 427 210 | 1 813 350 |

នៅឆ្នាំ 1988 ទិន្នផលស្រូវបានកើនឡើងដល់ទៅ 2 700 000 តោនទៅ 3 000 000 តោន ហើយនៅឆ្នាំ 1990 ប្រជាជនកម្ពុជាម្នាក់អាចទទួលផលស្រូវជាមធ្យម 350 គីឡូក្រាម ។ ក្រៅពីទិន្នផលស្រូវនៅមានអាជីវកម្មព្រៃឈើ ជ័រកៅស៊ូ ផលនេសាទ(ទឹកសាប ទឹកប្រៃ) ។

## 2.3. រចនាសម្ព័ន្ធគ្រប់គ្រង 1979-1981

- សមមិត្តហេង សំរិន ជាប្រធានរដ្ឋឬប្រមុខរដ្ឋ និងជាប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា
- សមមិត្តប៉ែន សុវណ្ណ(រៀននៅវៀតណាម 1954)អនុប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ(1979-1981) និងជានាយករដ្ឋមន្ត្រី ។
- សមមិត្ត ជា ស៊ីម ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- សមមិត្តហ៊ុន សែន ជារដ្ឋមន្ត្រីក្រសួងការបរទេស
- សមមិត្តកែវ ចិន្តា ជារដ្ឋមន្ត្រីឃោសនាការ ព័ត៌មាន និងវប្បធម៌
- សមមិត្តចាន់ វេន ជារដ្ឋមន្ត្រីក្រសួងអប់រំ
- សមមិត្តចាន់ ស៊ី(រៀននៅវៀតណាម 1954)ជានាយករដ្ឋមន្ត្រីក្រោយចាប់ខ្លួនប៉ែន សុវណ្ណ ។

## 2.4. អង្គការរដ្ឋសំខាន់ៗ

អង្គការរដ្ឋសំខាន់ៗមាន 4គឺ

- គណបក្សប្រជាជនបដិវត្តន៍កម្ពុជា ដឹកនាំដោយអគ្គលេខាសមមិត្ត ប៉ែន សុវណ្ណ ជាខ្មែរឥស្សរៈធ្លាប់រៀននៅទីក្រុងហាណូយឆ្នាំ 1954 ហើយតំណែងនេះត្រូវធ្លាក់មកលើ សមមិត្តហេង សំរិន នៅខែធ្នូ 1981 ។
- ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាឬក្រុមប្រឹក្សារដ្ឋមន្ត្រីមានរដ្ឋមន្ត្រីចំនួន 17រូប ប្រធានគឺសមមិត្តប៉ែន សុវណ្ណ ហើយតំណែងនេះធ្លាក់លើសមមិត្ត ចាន់ ស៊ី(ជាខ្មែរឥស្សរៈ)នៅខែធ្នូ 1981 ។
- ក្រុមប្រឹក្សារដ្ឋដែលមានសមមិត្ត ហេង សំរិនជាប្រធាន
- សភាជាតិមានសមាជិក 117រូប បង្កើតឡើងនៅខែឧសភា ឆ្នាំ 1981 ។ នៅខែមិថុនា ឆ្នាំ 1981 សភាបើកការប្រជុំលើកទី 1 ដើម្បីជ្រើសរើសប្រធានសភា គណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សារដ្ឋ ។

ចាប់ពីថ្ងៃទី 29-30មេសា 1989 សភាបានបើកសម័យប្រជុំវិសាមញ្ញមួយដើម្បីធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញថ្មី និងប្តូរឈ្មោះពីសាធារណរដ្ឋប្រជាមានិតកម្ពុជាមកជា "រដ្ឋកម្ពុជា" រួមទាំងប្តូរទង់ជាតិ ភ្លេងជាតិ រដ្ឋធម្មនុញ្ញ ច្បាប់ប្រហារជីវិត ការពារកម្មសិទ្ធិឯកជន ការបង្កើតទីផ្សារសេរី និងទទួលស្គាល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

# 3. នយោបាយបង្រួបបង្រួមជាតិ

ក្រោយរំដោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមមេដឹកនាំធំៗ និងកងទ័ពកម្ពុជាប្រជាធិបតេយ្យបានភៀសខ្លួនទៅបង្កសង្គ្រាមនៅតាមព្រំដែនកម្ពុជា-ថៃ ។ មានក្រុមពីរទៀតគឺក្រុមសេរីការរបស់លោកសឺន សាន និងក្រុមរាជានិយមរបស់សម្តេចនរោត្តមសីហនុ បានរួមគ្នាប្រឆាំងនឹងរដ្ឋាភិបាលរដ្ឋកម្ពុជា ។ អង្គការសហប្រជាជាតិបានប្រគល់អាសនៈឱ្យពួកខ្មែរក្រហម និងសម្ព័ន្ធត្រីភាគីរបស់គេដែលដឹកនាំដោយសម្តេចនរោត្តមសីហនុ ។

ក្រុមសម្ព័ន្ធត្រីភាគីមានការឧបត្ថម្ភគាំទ្រពីអង្គការសហប្រជាជាតិ សហរដ្ឋអាមេរិក ចិន ថៃ... ។ ប៉ុន្តែនៅឆ្នាំ 1984 ចិន និងសហរដ្ឋអាមេរិកមានទំនាក់ទំនងល្អឈានទៅរកការស្រុះស្រួលរវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត នាទីក្រុងហ្សឺណែវ ឆ្នាំ 1985 ។ ទំនាក់ទំនងជាអន្តរជាតិនេះបានធ្វើឱ្យនយោបាយពិភពលោកមានការប្រែប្រួល ពិសេសសភាពការណ៍នយោបាយនៅកម្ពុជា ។

នៅខែវិច្ឆិកា ឆ្នាំ 1984 ប្រទេសបារាំងបានរៀបចំគម្រោងការជួបចរចារវាងសម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន ។ ប៉ុន្តែ គម្រោងការនេះត្រូវអាក់ខានទៅវិញដោយសារចិន និងខ្មែរក្រហមមិនយល់ព្រម ។ នៅឆ្នាំ 1985 នយោបាយនៅអាស៊ីអាគ្នេយ៍បានបើកភ្លើងពណ៌បៃតងជាសញ្ញាអនុគ្រោះដល់ការចរចាសន្តិភាពនៅកម្ពុជា ។ ទ័ពវៀតណាមត្រូវដកឱ្យអស់ពីប្រទេសកម្ពុជាត្រឹមឆ្នាំ 1990 ។

នៅឆ្នាំ 1987 ជំនួបកំពូលរវាងមហាអំណាចពីរគឺ អាមេរិក និងសូវៀតស្តីពីការលុបចំបាត់កាំជ្រួចមីស៊ីលរយៈចម្ងាយមធ្យមនាំឱ្យសភាពការណ៍នយោបាយកម្ពុជាកាន់តែប្រសើរឡើងថែមទៀត ។

នៅថ្ងៃទី 27 ខែកក្កដា ឆ្នាំ 1987 រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ីបានធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសវៀតណាម និងបានពិភាក្សាគ្នាពីរូបមន្តនៃការជួបគ្នារវាងគូវិវាទខ្មែរទាំងអស់មានពីរដំណាក់កាល :

- ការជួបគ្នារវាងភាគីខ្មែរ និងខ្មែរ
- ការជួបគ្នារវាងភាគីខ្មែរ និងប្រទេសពាក់ព័ន្ធ

នៅខែសីហា និងតុលា ឆ្នាំ 1987 រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានដាក់សំណើសន្តិភាព និងនយោបាយបង្រួបបង្រួមជាតិទៅសម្ព័ន្ធត្រីភាគីដែលមានសម្តេចនរោត្តមសីហនុជាប្រធាន ។



- ជំនួបទី 1 : នៅថ្ងៃទី 2 ខែធ្នូ ឆ្នាំ 1987 នៅទីក្រុងហ្វែអង់តាឌឺន័រ(បារាំង) រវាងសម្ដេច នរោត្ដមសីហនុ និងលោក ហ៊ុន សែនដោយបានចុះហត្ថលេខាព្រមព្រៀងរកដំណោះស្រាយ បញ្ហានៅកម្ពុជា ។
- ជំនួបទី 2 : នៅថ្ងៃទី 21-22 ខែមេសា ឆ្នាំ 1988នាប្រទេសបារាំង ប៉ុន្តែមិនបានចេញសេចក្ដី ប្រកាសរួមណាមួយឡើយ ។ ចំណែកគម្រោងជំនួបលើកទី 3-4-5ត្រូវបានលុបចោលទាំងអស់ ។

នៅថ្ងៃទី 23 ខែតុលា ឆ្នាំ 1991 កិច្ចចរចាសន្តិភាពនាទីក្រុងប៉ារីស រវាងគូវិវាទខ្មែរបានប្រារព្ធ ឡើង និងទទួលលទ្ធផលយ៉ាងល្អប្រសើរ ដោយតំណាងភាគីជម្លោះបានចាប់ដៃគ្នាយល់ព្រមធ្វើការ បោះឆ្នោតជាសកល ។ ក្រោមជំនួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិហៅកាត់អ៊ុនតាក់ (UNTAC) នៅខែតុលា ឆ្នាំ 1993 បានបោះឆ្នោតនៅកម្ពុជា ។

នៅថ្ងៃទី 24 ខែកញ្ញា ឆ្នាំ 1993 រដ្ឋធម្មនុញ្ញថ្មីត្រូវបានប្រកាសឱ្យប្រើជាទូទៅ ហើយប្រទេសត្រូវ បានចារិកឈ្មោះថា "ព្រះរាជាណាចក្រកម្ពុជា" ដែលគ្រងរាជ្យលើកទី 2 ដោយសម្ដេចនរោត្ដមសីហនុ ។

## ? សំណួរ

1. ហេតុអ្វីបានជាគេបង្កើតរណសិរ្សសង្គ្រោះជាតិកម្ពុជា ?
2. តើកត្តាអ្វីខ្លះ ដែលនាំឱ្យមានជ័យជំនះ 7 ខែមករា ឆ្នាំ 1979 ?
3. ប្រឈមនិងការលំបាកចំពោះមុខ តើរដ្ឋាភិបាលត្រូវដោះស្រាយបញ្ហាអ្វីខ្លះ ?
4. តើហេតុអ្វីចាំបាច់បង្រួបបង្រួមជាតិ ?

## សំណួរបញ្ចប់ជំពូកទី២

I. ចូរគូសសញ្ញា ✓ មុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

1. ប្រទេសកម្ពុជាស្ថិតក្រោមអាណាព្យាបាលបារាំងពីឆ្នាំ ៖

- ☐ ក. 1858-1863
- ☐ ខ. 1860-1880
- ☐ គ. 1863-1953
- ☐ ឃ. 1865-1955 ។

2. ប្រទេសកម្ពុជាសម័យសង្គមរាស្ត្រនិយមដឹកនាំដោយ ៖

- ☐ ក. ព្រះបាទនរោត្តម
- ☐ ខ. សម្តេចព្រះនរោត្តមសីហនុ
- ☐ គ. ព្រះអង្គស៊ីសុវត្ថិ
- ☐ ឃ. ស៊ីវត្ថា ។

3. សម័យសាធារណរដ្ឋខ្មែរមានរយៈពេលពីឆ្នាំ ៖

- ☐ ក. 1967-1969
- ☐ ខ. 1968-1970
- ☐ គ. 1970-1973
- ☐ ឃ. 1970-1975 ។

4. មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យមានឋានៈជាគណៈប្រធានរដ្ឋគឺ ៖

- ☐ ក. អៀង សារី
- ☐ ខ. ខៀវ សំផន
- ☐ គ. នួន ជា
- ☐ ឃ. ប៉ុល ពត ។

5. របបសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជាមានរយៈពេលពីឆ្នាំ ៖

- ☐ ក. 1978-1979
- ☐ ខ. 1979-1990
- ☐ គ. 1979-1993
- ☐ ឃ. 1980-1990 ។

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. នៅពាក់កណ្តាលសតវត្សទី 19 បារាំងចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះទឹកដីនៅភូមិភាគ ........... ។
2. ព្រះបាទនរោត្តមសីហនុជាព្រះរាជបុត្ររបស់ព្រះបាទ .......... និងមហាក្សត្រីយានី ............ ។
3. របបសាធារណរដ្ឋខ្មែរត្រូវបានប្រកាសនៅថ្ងៃទី ..................... ដោយឧត្តមសេនីយ៍ លន់ នល់ អ្នកអង្គម្ចាស់ សិរីមតៈ និងបក្សពួកក្នុងពេលដែល .................. មិនបានស្ថិតនៅក្នុងប្រទេស ។
4. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានចែកតំបន់រដ្ឋបាលជា 3 គឺ ................. និង ............ ។
5. វណ្ណៈសង្គមក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានពួក ............. និងពួក ............ (ប្រជាជនថ្មី) ។

### III. ចូរឆ្លើយសំណួរខាងក្រោម

1. តើព្រះរាជាខ្មែរបានធ្វើសំណូមពរឱ្យបារាំងបង្វិលខេត្តបីនៅកម្ពុជាក្រោមឱ្យវិញដែរឬទេ ? នៅឆ្នាំណា ? តើព្រះរាជាអង្គណា ?
2. តើសង្គមរាស្ត្រនិយមជាអ្វី ? បង្កើតឡើងដោយនរណា ? នៅឆ្នាំណា ?
3. ចូរបង្ហាញពីផលវិបាកនៃសង្គ្រាមក្នុងសម័យសាធារណរដ្ឋខ្មែរ ?
4. ដើម្បីជំលៀសប្រជាជនឱ្យចេញពីទីក្រុងភ្នំពេញ តើពួកខ្មែរក្រហមប្រើវិធីដូចម្តេច ? ដើម្បីអ្វី ?
5. តើក្រុមសាមគ្គីបង្កបង្កើនផលបង្កើតឡើងនៅឆ្នាំណា ? តើគោលការណ៍បែងចែកផលដូចម្តេចខ្លះ ?

# ជំពូកទី 3 ប្រវត្តិសាស្ត្រប្រទេសក្នុងតំបន់




ប្រទេសនៅអាស៊ីអាគ្នេយ៍ត្រូវការសន្តិភាព កិច្ចសហប្រតិបត្តិការ ទំនាក់ទំនងល្អ និងការអភិវឌ្ឍ។ យើងមិនត្រូវការសង្គ្រាមឈ្លានពានទេ។ ការដែលលើកទ័ពមកឈ្លានពានប្រទេសភូមិផងរបងជាមួយគ្នាឬប្រទេសជិតខាងជាអំពើអាក្រក់បំផុត និងជាអំពើដែលក្បត់និងគោលការណ៍របស់អង្គការសមាគមអាស៊ាន ASEAN ទាំងស្រុង។

ដូចនេះ ប្រទេសសមាជិកអាស៊ានទាំងអស់គួរថ្កោលទោសចំពោះប្រទេសណាដែលប្រព្រឹត្តល្មើសនិងគោលការណ៍របស់អាស៊ាន ASEAN។

# 1 ប្រទេសឥណ្ឌូណេស៊ី

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីស្ថានភាពភូមិសាស្ត្រ និងសេដ្ឋកិច្ចក្នុងសម័យអាណានិគមហូឡង់ និងជប៉ុន
- ❑ ប្រៀបធៀបសេដ្ឋកិច្ចប្រទេសឥណ្ឌូណេស៊ី និងប្រទេសកម្ពុជាក្រោយបានឯករាជ្យ
- ❑ ស្រង់យកបទពិសោធល្អ សម្រាប់ដោតជ័យក្នុងការអភិវឌ្ឍប្រទេសជាតិ ។

## 1. ស្ថានភាពភូមិសាស្ត្រ និងប្រជាជន

ប្រទេសឥណ្ឌូណេស៊ីជាកម្រងកោះដែលមានចំនួនប្រហែល 17 508 និងលាតសន្ធឹងតាមបណ្ដោយខ្សែអេក្វាទ័រ ប្រវែង 5 150 km ។ ប្រទេសឥណ្ឌូណេស៊ីមានកោះធំ4គឺ កោះសេឡែប កោះជ្វា កោះបរនេអូ និងកោះស៊ូម៉ាត្រា ហើយស្ថិតនៅជាប់មហាសមុទ្រ 2 គឺមហាសមុទ្រឥណ្ឌា និងមហាសមុទ្រប៉ាស៊ីហ្វិក ។ នៅពាក់កណ្ដាលឆ្នាំ 1990 ប្រទេសនេះមានប្រជាជនជាង 185 លាននាក់ ហើយបានរាយប៉ាយមិនស្មើគ្នាពាសពេញលើកោះទាំងអស់ ។

នៅប្រទេសឥណ្ឌូណេស៊ីមានក្រុមជនជាតិនិយាយភាសាជាង 300 ផ្សេងៗគ្នា ហើយក្រុមនីមួយៗមានវប្បធម៌ និងកេរដំណែលដោយឡែកៗរបស់ខ្លួន ។ នៅក្នុងប្រជុំកោះឥណ្ឌូណេស៊ីមានរដ្ឋពីរបែបធំៗគឺ រដ្ឋនៅតាមតំបន់ឆ្នេរ និងរដ្ឋកោះ ។ រដ្ឋនៅតាមតំបន់ឆ្នេរស្ថិតនៅតាមពាម តាមទន្លេប្រកបដោយផែល្អៗ ចាកផុតពីគ្រោះថ្នាក់ទាំងពួង ហើយមានការពឹងពាក់លើពាណិជ្ជកម្មតាមតំបន់និងអន្តរជាតិ ។ រីឯរដ្ឋកោះភាគច្រើនពឹងលើផលិតផលកសិកម្មគ្រប់បែបយ៉ាងដែលបានមកពីបន្ទុះភ្នំភ្លើង (ដីក្រហម) និងតំបន់ដីល្បាប់ ។

## 2. ស្ថានភាពសេដ្ឋកិច្ចក្នុងសម័យអាណានិគមហូឡង់

### 2.1. វិស័យពាណិជ្ជកម្ម

ក្នុងអំឡុងសតវត្សទី 17 ក្រុមហ៊ុនឥណ្ឌាខាងកើត និងពួកហូឡង់ បានទាក់ទងប្រជុំកោះឥណ្ឌូណេស៊ីជាលើកដំបូង តាមរយៈការធ្វើពាណិជ្ជកម្មជាមួយរដ្ឋតាមតំបន់ឆ្នេរ ។ ពួកគេមានបំណងកាន់កាប់ផ្ដាច់មុខក្នុងជំនួញគ្រឿងទេសទៅលក់នៅអឺរ៉ុប ។ ការធ្វើពាណិជ្ជកម្មផ្ដាច់មុខរបស់ហូឡង់ធ្វើ

ឱ្យប៉ះពាល់សេដ្ឋកិច្ចនៅប្រជុំកោះឥណ្ឌូណេស៊ីយ៉ាងខ្លាំង ។ ពួកគេអាចបំផ្លាញបណ្ដាញពាណិជ្ជកម្មបន្តិចម្ដងៗក្នុងតំបន់ដែលមានជីវិតរាប់រយឆ្នាំមកហើយនោះ ។ ពួកពាណិជ្ជករតូចតាចត្រូវបានគេកំណត់ព្រំដែនក្នុងការធ្វើពាណិជ្ជកម្មតាមតំបន់ ។ ពាណិជ្ជកម្មក្រៅប្រទេសត្រូវក្រុមហ៊ុនអឺរ៉ុបគ្រប់គ្រងចាត់ចែងទាំងស្រុង ហើយពាណិជ្ជកម្មរវាងតំបន់និងតំបន់ជាការទទួលខុសត្រូវដោយជនជាតិចិនដែលធ្វើអន្តោប្រវេសន៍មកពីប្រទេសចិនភាគខាងត្បូង ។

ក្រោមការគ្រប់គ្រងរបស់ពួកហូឡង់គេឃើញថា ផ្នែកសេដ្ឋកិច្ចនៅកោះស៊ូម៉ាត្រា ក្នុងរយៈពេលជាង 30ឆ្នាំដំបូងមានការផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់ ។ ស៊ូម៉ាត្រាក្លាយជាអ្នកផ្គត់ផ្គង់ថ្នាំជក់ដ៏ធំបំផុត និងមានគុណភាពល្អដាច់គេនៅក្នុងចំណោមប្រទេសផ្គត់ផ្គង់ថ្នាំជក់លើពិភពលោក ។ នៅពេលដែលបានគេរកឃើញកំណប់ប្រេងនាទសវត្សរ៍ឆ្នាំ 1920 ទឹកដីស៊ូម៉ាត្រាបានក្លាយជាទីតាំងក្រុមហ៊ុនប្រេងសែលភូមិន្ទរបស់ហូឡង់ ។

## 2.2. ផលវិបាកនៃកំណើនប្រជាជនទីក្រុង

នៅមុនទសវត្សរ៍ឆ្នាំ 1910 ទីក្រុងសំខាន់ៗនៅលើកោះជ្វាមានពលរដ្ឋចំណូលថ្មីជាច្រើនដែលធ្វើអន្តោប្រវេសន៍មកពីតំបន់ដាច់ស្រយាល ។ ទីក្រុងទាំងនេះទទួលរងគ្រោះដោយសារទឹកជំនន់ដ៏ធ្ងន់ធ្ងរនារដូវវស្សាជារៀងរាល់ឆ្នាំ ហើយប្រជាជនត្រូវរងគ្រោះដោយជំងឺគ្រុនចាញ់ និងជំងឺរាគរូសផ្សេងៗ ។ រដ្ឋាភិបាលអាណានិគមគ្មានគោលនយោបាយច្បាស់លាស់ក្នុងការពិនិត្យ និងដោះស្រាយវិបត្តិចំពោះមុខនេះបានឡើយ ។ ជីវភាពរស់នៅរបស់ប្រជាជនឥណ្ឌូណេស៊ីនៅទីក្រុងនានាស្ទើរតែទាំងអស់កាន់តែលំបាកឡើង ចាប់ពីឆ្នាំ 1920ដល់ទសវត្សរ៍ឆ្នាំ 1970 ។

## 2.3. វិស័យវប្បធម៌

ហូឡង់បាននាំមកនូវរបៀបអប់រំបែបបស្ចិមប្រទេសដើម្បីផ្ដល់នូវជំនាញចាំបាច់មួយចំនួនក្នុងការប្រើប្រាស់សេដ្ឋកិច្ចអាណានិគមដែលកំពុងតែរីកសាយ ។ សាលារៀនល្អៗបានប្រើប្រាស់ភាសាហូឡង់ ។ ប៉ុន្តែ ការចូលរៀននៅសាលាទាំងនេះជាការលំបាកចំពោះប្រជាជនឥណ្ឌូណេស៊ី ។ ក្រៅពីអ្នកទទួលបានអាហារូបករណ៍មួយចំនួនតូច សាលាទាំងនោះបានកម្រិតលក្ខខណ្ឌចំពោះកូនរបស់វរជនជាអ្នកក្រ ឬកូនមន្ត្រីរដ្ឋាភិបាល ។

ក្រៅពីសាលាអប់រំតាមបែបសាសនា សាលារៀននានាដែលយកភាសាតាមតំបន់មកប្រើជាភាសាយានមានលក្ខណៈងាយស្រួលជាងការទទួលយកការអប់រំដោយប្រើភាសាផ្សេង ។ ហេតុនេះហើយ ទើបនៅក្រោយការបញ្ចប់នៃសករាជអាណានិគមហូឡង់ អត្រាអ្នកចេះភាសាហូឡង់មានចំនួនតិចជាងរដ្ឋនានាដែលនៅក្រោមរបបអាណានិគមអឺរ៉ុបផ្សេងៗទៀត ។

## ៣. ឥណ្ឌូចិនក្នុងសម័យអាណានិគមជប៉ុន និងហូឡង់ (ជាថ្មី)

### ៣.1. ក្រោមរបបគ្រប់គ្រងជប៉ុន និងការប្រកាសឯករាជ្យ

ជប៉ុនបានចូលមកត្រួតត្រាឥណ្ឌូណេស៊ីក្នុងខែមីនា ឆ្នាំ 1942 ។ ពេលមកដល់ដំបូង ជប៉ុនបានទទួលស្វាគមន៍ពីសំណាក់ប្រជាជនឥណ្ឌូណេស៊ីដោយពួកគេបានទទួលឯករាជ្យពីហូឡង់ ថែមទាំងដក់ចិត្តយ៉ាងខ្លាំងនិងពាក្យស្លោករបស់ជប៉ុនដែលថា "ជប៉ុនគឺជាពន្លឺរស្មីនៃអាស៊ី" ។ មិនយូរប៉ុន្មាន ប្រជាជនឥណ្ឌូណេស៊ីសិក្សាស្វែងយល់ឃើញថា ពួកគេជាអ្នករងគ្រោះពីការគំរាមកំហែង ប្រមាថមាក់ងាយបំផុតពីពួកជប៉ុនទៅវិញ ។ ទោះជាយ៉ាងនេះក្តី ក៏គោលនយោបាយគ្រប់គ្រងរបស់ជប៉ុនបានផ្តល់ផលចំណេញខ្លះក្នុង រយៈពេលវែងដល់ឥណ្ឌូណេស៊ីដែរ ដូចជា ៖

- ការគ្រប់គ្រងរដ្ឋបាលមានកម្រិតខ្ពស់ដែលគេមិនធ្លាប់ទទួលបាននៅក្នុងរបបអាណានិគមមុនៗ ជាក់ស្តែងនៅក្នុងឆ្នាំ 1945 ។
- ហាមប្រើប្រាស់ភាសាហូឡង់ក្នុងពេលជប៉ុនគ្រប់គ្រង ។
- ប្រមូលផ្តុំយុវជនឥណ្ឌូណេស៊ី ផ្តល់ការហ្វឹកហ្វឺនផ្នែកយោធាដើម្បីជួយច្បាំងជប៉ុនទប់ទល់នឹងការត្រួតត្រាជាថ្មីនៃកម្លាំងហូឡង់នៅចន្លោះឆ្នាំ 1945 និង 1949 ។
- ដោះលែងមេដឹកនាំអ្នកជាតិនិយមពីពន្ធនាគាររួមទាំង ស៊ូ ការណូផងក្នុងលក្ខខណ្ឌការគាំទ្រកិច្ចការសង្គ្រាម ។

ក្រោយអាមេរិកទម្លាក់គ្រាប់បែកបរមាណូ 2 គ្រាប់លើប្រទេសជប៉ុន សង្គ្រាមនៅប៉ាស៊ីហ្វិកបានបញ្ចប់ លោកស៊ូការណូ និងមេដឹកនាំជាតិនិយមជាច្រើននាក់បានប្រកាសឯករាជ្យជាឯកតោភាគីឡើង ។ សាធារណរដ្ឋឥណ្ឌូណេស៊ីចាប់បដិសន្ធិឡើងនៅថ្ងៃទី 17 ខែសីហា ឆ្នាំ 1945 ។

### ៣.2. អាណានិគមហូឡង់លើកទី 2

ប្រទេសហូឡង់បានច្រានចោលសេចក្តីប្រកាសឯករាជ្យរបស់ឥណ្ឌូណេស៊ីដោយអះអាងពីភាពស្របច្បាប់របស់រដ្ឋាភិបាលខ្លួន ។ ហូឡង់បានចាប់ផ្តើមដំណើរការគ្រប់គ្រងឥណ្ឌូណេស៊ីជាថ្មីនាពាក់កណ្តាលឆ្នាំ 1946 ។ នៅខែធ្នូ ឆ្នាំ 1949 កិច្ចព្រមព្រៀងមួយត្រូវបានសម្រេចឡើងជាចុងក្រោយរវាងសាធារណរដ្ឋឥណ្ឌូណេស៊ី និងហូឡង់ ដែលជាការបញ្ចប់សង្គ្រាម និងការបញ្ចប់របបគ្រប់គ្រងអាណានិគមហូឡង់ ។

## 4. ឥណ្ឌូណេស៊ីក្រោយឯករាជ្យ



លោកស៊ូហារតូនិងលោកស៊ូការណូ

នៅថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 1965 ទាហានជាន់ទាបមួយក្រុមធ្វើរដ្ឋប្រហារទម្លាក់រដ្ឋាភិបាលឥណ្ឌូណេស៊ីដែលដឹកនាំដោយឧត្តមសេនីយ៍ ស៊ូហារតូ ដោយធ្វើការផ្លាស់ប្តូរជាថ្មីនូវរចនាសម្ព័ន្ធ និងការរៀបចំនយោបាយឥណ្ឌូណេស៊ី ។ ពួកគេហៅរដ្ឋាភិបាលខ្លួនថា "ចំណាត់ការថ្មី" ផ្ទុយគ្នានឹង "របៀបចំណាត់ការចាស់" របស់លោកប្រធានាធិបតី ស៊ូការណូ ។ ចំណាប់ផ្តើមដំបូងនាឆ្នាំ 1965 រដ្ឋាភិបាល "រៀបចំថ្មី" របស់ប្រធានាធិបតីស៊ូហារតូមានវិបត្តិសេដ្ឋកិច្ចកើតឡើង អតិផរណា ហេដ្ឋារចនាសម្ព័ន្ធសង្គមទន់ខ្សោយ និងសេដ្ឋកិច្ចធ្លាក់ស្រុតចុះយ៉ាងខ្លាំង ។ ក្នុងរយៈពេលជិត 30ឆ្នាំក្រោយមក ទើបសេដ្ឋកិច្ចមានលំនឹងទទួលលទ្ធផលល្អប្រសើរឡើងវិញ ។

ស្រូវជាអាហារស្បៀងយ៉ាងសំខាន់ជាងគេ ប្រជាជនឥណ្ឌូណេស៊ីពាក់កណ្តាលមានរបរធ្វើកសិកម្ម ។ ប៉ុន្តែ ទិន្នផលកសិកម្មនៅឥណ្ឌូណេស៊ីទាបមិនអាចផ្គត់ផ្គង់ប្រជាជនឥណ្ឌូណេស៊ីដ៏ច្រើនបានឡើយ ។ នៅទសវត្សរ៍ឆ្នាំ 1950 និងឆ្នាំ 1960 ប្រទេសឥណ្ឌូណេស៊ីនាំអង្ករចូលយ៉ាងច្រើន ។ ឆ្នាំ 1979 កសិកម្មមានការរីកចម្រើន ទិន្នផលស្រូវមានការកើនឡើងយ៉ាងខ្លាំង ធ្វើឱ្យជីវភាពប្រជាជនមានបម្រែបម្រួលគួរកត់សម្គាល់ ។ ក្នុងឆ្នាំ 1983 ផលិតផលស្រូវឥណ្ឌូណេស៊ីកើនលើសតម្រូវការក្នុងស្រុកជាលើកដំបូង គឺរយៈពេលប្រហែល 100ឆ្នាំកន្លងមកនេះ ។ នេះគឺជាជោគជ័យរបស់រដ្ឋាភិបាលក្នុងគោលនយោបាយកសិកម្ម ។ ក្នុងពេលចុងក្រោយ ឥណ្ឌូណេស៊ីបានប្រែក្លាយពីការអនុវត្តនយោបាយបម្រើឱ្យការនាំចូលក្នុងផ្នែកកសិកម្មទៅជានយោបាយផ្តោតលើការនាំចេញ ។ ឥណ្ឌូណេស៊ី គឺជាប្រទេសនាំចេញវាយនភ័ណ្ឌ គ្រឿងអលង្ការកែច្នៃ សម្លៀកបំពាក់ និងសេវាកម្ម ។ កំណើនសេដ្ឋកិច្ចក្នុងរយៈពេល 30ឆ្នាំចុងក្រោយនេះ បានបង្ហាញពីចំណាត់ថ្នាក់ "ជាប្រទេសដែលរីកចម្រើនលូតលាស់ថ្មីផ្នែកសេដ្ឋកិច្ច" ។

### ? សំណួរ

1. តើប្រទេសឥណ្ឌូណេស៊ីធ្លាប់នៅក្រោមអាណានិគមប្រទេសណាខ្លះ ? នៅពេលណាខ្លះ ?
2. តើអាណានិគមហូឡង់ធ្វើឱ្យប្រទេសឥណ្ឌូណេស៊ីទទួលបានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ ?
3. ក្រោយបានឯករាជ្យពីហូឡង់ តើឥណ្ឌូណេស៊ីមានសេដ្ឋកិច្ចដូចម្តេច ?
4. ចូរនិយាយពីចលនាតស៊ូទាមទារឯករាជ្យរបស់ប្រជាជនឥណ្ឌូណេស៊ី ។

# 2 ប្រទេសម៉ាឡេស៊ី

**ចប់មេរៀននេះ សិស្សអាច**

- ❑ និយាយពីទឹកដី ជនជាតិ ការបង្កើតសហព័ន្ធ សម្ព័ន្ធភាព និងឯករាជ្យភាពម៉ាឡេស៊ី
- ❑ វិភាគរកមូលហេតុនៃការបង្កើតសហព័ន្ធម៉ាឡេស៊ី និងឯករាជ្យភាពនៃម៉ាឡេស៊ី
- ❑ វិភាគគុណសម្បត្តិ និងគុណវិបត្តិដែលធ្លាប់ឋិតក្រោមរបបអាណានិគមទាំងឡាយ ។

## 1. ប្រវត្តិទឹកដី និងជនជាតិម៉ាឡេស៊ី

ប្រទេសម៉ាឡេស៊ីជារដ្ឋសហព័ន្ធ ស្ថិតនៅអាស៊ីអាគ្នេយ៍ ចែកចេញជា 2 ផ្នែក ។ មួយផ្នែកស្ថិតនៅលើឧបទ្វីបម៉ាឡេមាន 11 រដ្ឋ ។ កូឡាឡាំពួ (Kuala Lampur) ជារាជធានី ។ មួយផ្នែកទៀត មានរដ្ឋពីរគឺសារ៉ាវ៉ាក់ និងសាបា ស្ថិតនៅលើកោះបរនេអូ សណ្តូកតាមឆ្នេរសមុទ្រចិនខាងត្បូងប្រវែង 640km ។

ប្រជាជនម៉ាឡេរួមដោយជាតិពន្ធុជាច្រើនក្រុម ។ ក្រុមជនជាតិម្ចាស់ស្រុកមានចំនួនប្រមាណ 55% ច្រើនជាងគេទាំងអស់ ។ ក្រុមក្រៅពីនេះមានជនជាតិចិន មានចំនួនប្រមាណ 32% ជនជាតិឥណ្ឌាមានចំនួន 8% និង 5% ជនជាតិផ្សេងទៀត ។

ចាប់តាំងពីសតវត្សទី 15 ជនជាតិម៉ាឡេប្រកាន់សាសនាឥស្លាមដែលជាវប្បធម៌ដ៏មានមោទនភាពរបស់ពួកគេ ។ ទោះជាយ៉ាងណាក្តី នៅក្នុងសករាជអាណានិគម វប្បធម៌របស់ពួកគេត្រូវបានពុះច្រៀកដោយសង្គ្រាមអាណានិគមរបស់ពួកបស្ចិមប្រទេសជាបន្តបន្ទាប់គឺចាប់ពីឆ្នាំ 1511 ស្ថិតនៅក្រោមអាណានិគមព័រទុយហ្កាល់ ពីឆ្នាំ 1641 ប្រទេសហូឡង់ ពីឆ្នាំ 1815 ចក្រភពអង់គ្លេស ។

## 2. ការមកដល់របស់ជប៉ុន

នៅថ្ងៃទី 8 ខែធ្នូ ឆ្នាំ 1941 កងកម្លាំងយោធាជប៉ុនបានចាប់ផ្តើមវាយលុកម៉ាឡេស៊ី ។ នៅថ្ងៃទី 15 ខែកុម្ភៈ ឆ្នាំ 1942 សិង្ហបុរីជារដ្ឋដែលនៅក្រោមអំណាចអង់គ្លេសនៅអាស៊ីអាគ្នេយ៍បានដួលរលំ ។ ឯរដ្ឋសារ៉ាវ៉ាក់ និងសាបាដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង់គ្លេសបានចុះចូលជប៉ុនដោយមិនមានការប្រយុទ្ធគ្នា ។ ការគ្រប់គ្រងរបស់ជប៉ុនបានបន្តជាង 3 ឆ្នាំកន្លះ រហូតដល់របបគ្រប់គ្រងរបស់យោធាអង់គ្លេសត្រឡប់ចូលមកវិញនៅខែសីហា ឆ្នាំ 1945 ។ ក្នុងកំឡុងពេលត្រួតត្រា ជប៉ុនបានបង្ហាញដល់ជនមូស្លីមម៉ាឡេថា ខ្លួនជាអ្នកជួយឧបត្ថម្ភទំនុកបម្រុងឱ្យមានការគោរពពេញលេញចំពោះវប្បធម៌អ៊ីស្លាម ។

ពួកគេបានជំរុញឱ្យមានការស្គាល់ខ្លួនឯងច្រើនឡើងក្នុងបណ្តាជនម៉ាឡេស៊ី ហើយបានផ្តល់ឱកាសថ្មីមួយទៀតដល់ជនម៉ាឡេស៊ីលើផ្នែកគ្រប់គ្រងរដ្ឋបាល ។ ប្រជាជនម៉ាឡេស៊ីមួយចំនួនស្ថិតនៅតាមតំបន់ជ្រោយគាំទ្រជប៉ុន ប៉ុន្តែនៅឆ្នាំ 1943 ពួកម៉ាឡេស៊ីចាប់ផ្តើមមានការមិនទុកចិត្តក្រោយពេលជប៉ុនបានផ្ទេររដ្ឋម៉ាឡេស៊ីចំនួន 4នៅភាគខាងជើងទៅឱ្យប្រទេសថៃ ។

ពួកជប៉ុនប្រព្រឹត្តលើជនជាតិចិនម៉ាឡេដូចជាឈ្លើយសឹក ដែលជារឿយៗគេឃើញអំពើឃោរឃៅគួរឱ្យរន្ធត់ ។ ជនជាតិចិនម៉ាឡេបានបង្កើតនូវកងកម្លាំងតស៊ូលួចលាក់មានចំនួនច្រើនលើសលុប ដែលចលនានេះបានរីករាលដាលពាសពេញលើឧបទ្វីបម៉ាឡេស៊ី និងនៅលើដែនដីបរនេអូ ។ គេស្គាល់ថាជា "កងកម្លាំងប្រជាជនម៉ាឡេស៊ីដើម្បីប្រឆាំងនឹងជប៉ុន" ហើយរីកធំឡើងៗ គ្រប់គ្រងដោយគណបក្សកុម្មុយនីស្តម៉ាឡេស៊ី ។

ផ្ទុយទៅវិញ ពួកជប៉ុនលើកទឹកចិត្តជនជាតិឥណ្ឌាម៉ាឡេ ដោយផ្តោតលើការគិតគូរពីបញ្ហានយោបាយឥណ្ឌា ។ ប្រជាជនម៉ាឡេវ័យក្មេងជាច្រើនត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមទីកន្លែងដែលឧបត្ថម្ភដោយជប៉ុន ។

## ३. ការបង្កើតសហព័ន្ធម៉ាឡេស៊ី

នៅឆ្នាំ 1946 សារ៉ាវ៉ាក់និងបរនេអូខាងជើងទទួលរងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយសង្គ្រាមនៅដំណាក់កាលចុងក្រោយបានប្រែក្លាយជារដ្ឋទទួលរ៉ាប់រងគ្រប់បែបយ៉ាងពីអង់គ្លេស ។ នៅតំបន់ជ្រោយ អង់គ្លេសបានបង្ហាញពីផែនការក្នុងការបង្កើតនូវ "សហព័ន្ធម៉ាឡេស៊ី" ដែលរួមបញ្ចូលគ្នានូវរដ្ឋម៉ាឡេនានា ហើយបានផ្តល់សិទ្ធិស្មើភាពជាប្រជាពលរដ្ឋ ។ ប្រជាជនម៉ាឡេម្ចាស់ស្រុកមិនសប្បាយចិត្តដោយសារការមិនយកចិត្តទុកដាក់ក្នុងការផ្តល់សិទ្ធិ និងឧត្តមភាពដល់ក្រុមរបស់ខ្លួនឱ្យលើសប្រជាជនអន្តោប្រវេសន៍ ។ អង្គការជាតិរួបរួមម៉ាឡេស៊ីបានបង្កើតឡើង ហើយបង្ខំឱ្យអង់គ្លេសលះបង់នូវគំនិតបង្កើតសហភាពចោល ។ ក្រោយការជជែកចរចាគ្នាជាបន្តបន្ទាប់ អង្គការជាតិរួបរួមម៉ាឡេស៊ីបានយល់ព្រមធ្វើតាមរចនាសម្ព័ន្ធរដ្ឋបាលបែបសហព័ន្ធ និងអនុញ្ញាតឱ្យជនជាតិដែលមិនមែនជាម៉ាឡេទាំងឡាយបំពេញនូវលក្ខខណ្ឌដ៏តឹងរ៉ឹងមួយចំនួនរបស់ខ្លួន ទើបមានសិទ្ធិពេញលេញជាពលរដ្ឋម៉ាឡេ ។ សហព័ន្ធម៉ាឡេស៊ីត្រូវបានចាប់ផ្តើមឡើងនៅឆ្នាំ 1948 ។

នៅក្នុងឆ្នាំដដែលនោះ គណបក្សកុម្មុយនីស្តម៉ាឡេស៊ីបានប៉ុនប៉ងធ្វើបដិវត្តន៍មួយដោយប្រើប្រាស់យុទ្ធសាស្ត្រចម្បាំងទ័ពព្រៃ ។ អង់គ្លេសបានប្រកាសជារដ្ឋមួយឡើងក្នុងភាពអាសន្ន ហើយបានអភិវឌ្ឍគោលនយោបាយកុបកម្មតបមកវិញ ដែលទទួលការគាំទ្រយ៉ាងច្រើនលើសលុបពីសំណាក់ប្រជាជន ។ មុនដើមទសវត្សរ៍ឆ្នាំ 1950 ខ្សែភេរវកម្មរបស់គណបក្សកុម្មុយនីស្តម៉ាឡេបានត្រូវគេកាត់

បន្ថយសកម្មភាពឱ្យកាន់តែតូចទៅៗ បើទោះបីច្បាប់ស្តីពីប្រទេសស្ថិតក្នុងភាពអាសន្ននៅជាធរមានរហូតដល់ឆ្នាំ 1960 ក៏ដោយ ។



*ទុនគូ អាប់ឌុលរ៉ាម៉ាន់*



*ពលករម៉ាឡេស៊ី*

## 4. រដ្ឋាភិបាលសម្ព័ន្ធភាព និងឯករាជភាព

ក្នុងពេលដែលប្រទេសជាតិត្រូវដាក់ឱ្យស្ថិតក្នុងភាពអាសន្ន អង់គ្លេសបានសន្យាចំពោះប្រជាជនម៉ាឡេស៊ីថា ពួកគេនឹងផ្តល់នូវរដ្ឋាភិបាលផ្ទាល់ខ្លួនមួយ ។ នៅឆ្នាំ 1952 មានរូបមន្តមួយសម្រាប់រដ្ឋាភិបាលគ្រប់គ្រងផ្ទាល់ខ្លួនប្រកបដោយសក្តានុពលត្រូវបានគេរកឃើញការចងសម្ព័ន្ធភាពរវាងគណបក្សធំៗបីមាន គណបក្សរួបរួមជាតិម៉ាឡេស៊ី គណបក្សសមាគមជនជាតិចិននៅម៉ាឡេស៊ី និងគណបក្សសភាឥណ្ឌានៅម៉ាឡេស៊ី ។ នៅឆ្នាំ 1955 សម្ព័ន្ធភាពនេះបានទទួលជោគជ័យក្នុងការបោះឆ្នោតគាំទ្រក្នុងសហព័ន្ធជាលើកទី 1 ដែលមាន ទុនគូ អាប់ឌុលរ៉ាម៉ាន់ ដ៏មហិមាជាមេដឹកនាំគណបក្សសម្ព័ន្ធភាពរួបរួមជាតិម៉ាឡេស៊ី ។ ក្រោយពីទទួលជោគជ័យដ៏ធំធេងក្នុងការបោះឆ្នោតសម្ព័ន្ធភាពនៅឆ្នាំ 1956 ទុនគូ អាប់ឌុលរ៉ាម៉ាន់ មានបេសកកម្មទៅកាន់ទីក្រុងឡុងដ៍ដើម្បីចរចារកសន្តិភាពជូនប្រជាជនម៉ាឡេស៊ី។ នៅឆ្នាំ 1957 អង់គ្លេសព្រមប្រគល់ឯករាជ្យឱ្យម៉ាឡេស៊ី ហើយទុនគូ អាប់ឌុលរ៉ាម៉ាន់បានត្រូវជ្រើសតាំងជានាយករដ្ឋមន្ត្រីដំបូងគេបំផុត ។ នៅឆ្នាំ 1963 គាត់បានដឹកនាំបង្កើតជារដ្ឋសហព័ន្ធម៉ាឡេស៊ីឡើង ។ រដ្ឋបរនេអូដែលមានចំនួនជនជាតិចិនដ៏តិចតួចទៅជាធាតុផ្សំមួយបញ្ចូលគ្នាជាមួយនឹងរដ្ឋសិង្ហបុរីដែលមានចំនួនប្រជាជនច្រើនលើសលប់ឱ្យមានតុល្យភាពគ្នា ប៉ុន្តែនៅពេលនោះសិង្ហបុរីត្រូវបានគេបញ្ចូលក្នុងសហព័ន្ធ ជាមួយបញ្ហាជាច្រើនដែលមិនទាន់ដោះស្រាយ ។ 2ឆ្នាំក្រោយមក កិច្ចព្រមព្រៀងបំបែករដ្ឋសិង្ហបុរីត្រូវបានធ្វើឡើងរវាងទុនគូ អាប់ឌុលរ៉ាម៉ាន់និងលី ក្វាន់យូ នៅខែសីហា ឆ្នាំ 1965 ។

## 5. វិបត្តិឆ្នាំ 1969

នៅឆ្នាំ 1960 គេសង្កេតឃើញលទ្ធិប្រជាធិបតេយ្យនៅម៉ាឡេស៊ី ត្រូវបើកទូលាយយ៉ាងខ្លាំង។ គណបក្សប្រឆាំងដ៏សំខាន់មួយកើតចេញពីគណបក្សឥស្លាមនៃជនជាតិម៉ាឡេស៊ី និងគណបក្សសកម្មប្រជាធិបតេយ្យបានចាប់ដំណើរការកសាងរដ្ឋឥស្លាមមួយនៅម៉ាឡេស៊ី។ គណបក្សសកម្មប្រជាធិបតេយ្យបានទាក់ទាញនូវការគាំទ្រពីអ្នកបោះឆ្នោតជនជាតិចិន ដែលមិនសប្បាយចិត្តនឹងសម្ព័ន្ធភាពបែបអភិរក្ស ហើយអំណាចភាគច្រើនស្ថិតក្នុងកណ្តាប់ដៃរបស់ជនជាតិម៉ាឡេ។

ការរំជើបរំជួលផ្នែកនយោបាយកាន់តែរីករាលដាលឡើងនៅក្នុងអំឡុងពេលនៃយុទ្ធនាការបោះឆ្នោតនាខែឧសភាឆ្នាំ 1969។ លទ្ធផលនៃការបោះឆ្នោតត្រូវបានប្រកាសឡើង សំឡេងគាំទ្ររដ្ឋាភិបាលសម្ព័ន្ធភាពបានថយចុះ។ ការប៉ះទង្គិចគ្នាដោយអំពើហិង្សាបានផ្ទុះឡើងនៅកូឡាឡាំពួ។ កុបកម្មបានផ្ទុះឡើងរយៈពេល 4 ថ្ងៃ បណ្តាលឱ្យមនុស្សជាច្រើនរយនាក់ស្លាប់ និងទ្រព្យសម្បត្តិមួយចំនួនធំត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ។ រដ្ឋស្ថិតក្នុងភាពអាសន្នមួយត្រូវបានគេប្រកាសឡើង ហើយរដ្ឋាភិបាលត្រូវបានគេដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងយ៉ាងណែនរបស់អង្គការមួយ គឺក្រុមប្រឹក្សាប្រតិបត្តិការជាតិដែលមានភារៈសម្របសម្រួលសកម្មភាពរបស់យោធា និងនគរបាល។ រដ្ឋាភិបាលដែលដឹកនាំដោយក្រុមប្រឹក្សាប្រតិបត្តិការជាតិបានបញ្ចប់ត្រឹមឆ្នាំ 1971 ហើយជំនួសវិញដោយរដ្ឋាភិបាលដែលអាស្រ័យលើការបោះឆ្នោតជ្រើសរើសរបស់សភា។

## ? សំណួរ

1. សហព័ន្ធម៉ាឡេស៊ីមានរដ្ឋសមាជិកប៉ុន្មាន ? រដ្ឋណាខ្លះ ?
2. ចូរបង្ហាញពីមុខរបរក្នុងប្រវត្តិសាស្ត្រ និងក្រុមជនជាតិនៅប្រទេសម៉ាឡេស៊ី។
3. តើប្រទេសម៉ាឡេស៊ីធ្លាប់នៅក្រោមអាណានិគមប្រទេសណាខ្លះ ?
4. តើមូលហេតុអ្វីដែលបណ្តាលឱ្យសហព័ន្ធម៉ាឡេស៊ីបង្កើតឡើងបាន ? នៅពេលណា ?
5. តើប្រទេសម៉ាឡេស៊ីបង្កើតឡើងដោយសារនរណា ? ដោយហេតុអ្វី ?
6. ហេតុអ្វីបានជាមានការបំបែករដ្ឋរវាងសិង្ហបុរី និងម៉ាឡេស៊ី ?

# 3 ប្រទេសសិង្ហបុរី

**ចប់មេរៀននេះ សិស្សអាច**

- អធិប្បាយពីស្ថានភាពនយោបាយ និងសេដ្ឋកិច្ចប្រទេសសិង្ហបុរីក្រោយឯករាជ្យ
- ពន្យល់ពីមូលហេតុដែលប្រទេសសិង្ហបុរីជាប្រទេសជឿនលឿនបំផុត
- ដកស្រង់បទពិសោធល្អៗរបស់មេដឹកនាំសិង្ហបុរី ។

សិង្ហបុរីជារដ្ឋកោះ ស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នាចុងខាងត្បូងនៃឧបទ្វីបម៉ាឡេស៊ី ។ សិង្ហបុរី[1] មានផ្ទៃ 646.1km$^2$ និងមានប្រជាជន 3,05 លាននាក់នៅក្នុងឆ្នាំ 1998 ។ ប្រទេសនេះមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេបំផុតនៅលើពិភពលោក ។ ប្រជាជនភាគច្រើនជាជនជាតិចិន មានចំនួន 76.6% ជនជាតិម៉ាឡេមានចំនួន 14% និងជនជាតិឥណ្ឌាមានចំនួន 2.3% ក្រៅពីនោះមានជនជាតិផ្សេងៗទៀត ។ សិង្ហបុរីមានភាសាផ្លូវការគឺ ម៉ាឡេ អង់គ្លេស ចិន និងតាមីល ។ នៅឆ្នាំ 1987 ភាសាអង់គ្លេសត្រូវបញ្ចូលទៅក្នុងប្រព័ន្ធអប់រំរបស់រដ្ឋ ។

## 1. សាធារណរដ្ឋសិង្ហបុរីឯករាជ្យ

ពីមុនសិង្ហបុរីជារដ្ឋមួយនៅក្នុងសហព័ន្ធម៉ាឡេស៊ី តែនៅខែកញ្ញា ឆ្នាំ 1965 សិង្ហបុរីបានផ្ដាច់ចេញទៅជាសាធារណរដ្ឋឯករាជ្យមួយ ។ ការបែកចេញនេះធ្វើឡើងដោយការសម្រេចចិត្តទាំងសងខាងរវាងរដ្ឋាភិបាលម៉ាឡេស៊ី និងរដ្ឋាភិបាលសិង្ហបុរី ។

ក្រោយទទួលឯករាជ្យភាពឆ្នាំ 1965 មក ប្រទេសសិង្ហបុរីបានខិតខំធ្វើការអភិវឌ្ឍជាតិយ៉ាងខ្លាំងធ្វើឱ្យប្រទេសមានការរីកចម្រើនគ្រប់វិស័យ ។ ការរីកចម្រើនផ្នែកសេដ្ឋកិច្ចគឺជាមូលដ្ឋានចម្បងរបស់រដ្ឋាភិបាល ។

រដ្ឋាភិបាលសិង្ហបុរីដឹកនាំដោយលោកលី ក្វាន់យូ បានប្ដេជ្ញាចិត្តថា ត្រូវរៀបចំខឿនសេដ្ឋកិច្ចដោយធ្វើឱ្យមានបំលាស់ប្ដូរយ៉ាងឆាប់រហ័សនូវហេដ្ឋារចនាសម្ព័ន្ធទាំងអស់ ប្រសិនបើសិង្ហបុរីមានវិបុលភាពនោះ ។

---

1 = 572km$^2$ World Book Volume 17 Page 469 Printed 1988

# 2. ស្ថានភាពនយោបាយ

## 2.1. នយោបាយក្នុងប្រទេស

តាមរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសិង្ហបុរី សមាជិកសភាត្រូវមានចំនួន 79រូប មានអាណត្តិត្រឹម 5ឆ្នាំ ជាអ្នកជ្រើសតាំងរដ្ឋាភិបាល ។ នាយករដ្ឋមន្ត្រីទី 1 ជាប្រធានគណៈរដ្ឋមន្ត្រី ដែលជ្រើសតាំងដោយសភា ។ ប្រជាជនសិង្ហបុរីជ្រើសតាំងអ្នកតំណាងរបស់ខ្លួនដោយការបោះឆ្នោតជាសកល ។ ប្រជាជនទាំងពីរភេទមានសិទ្ធិបោះឆ្នោត ត្រូវមានអាយុយ៉ាងតិច 21ឆ្នាំ ។ ចាប់ពីឆ្នាំ 1959 រហូតដល់ឆ្នាំ 1980 ប្រទេសសិង្ហបុរីត្រូវដឹកនាំដោយគណបក្សតែមួយគត់គឺគណបក្សសកម្មភាពប្រជាជន ជាគណបក្សដែលដឹកនាំដោយលោកលី ក្វាន់យូ ។

សមាជិកភាគច្រើននៃគណបក្សសកម្មភាពប្រជាជនបានបំបែកខ្លួនទៅបង្កើតបក្សថ្មីមួយទៀត ឈ្មោះរណសិរ្សសង្គមនិយម ។ នៅក្នុងឆ្នាំ 1966 រណសិរ្សសង្គមនិយមដណ្តើមកៅអីបានចំនួន 11 នៅក្នុងសភា ចំណែកគណបក្សប្រឆាំងក៏បានកៅអី 2នៅក្នុងសភាដែរ ។ ប៉ុន្តែ នៅក្នុងការបោះឆ្នោតជាសកលនៅក្នុងឆ្នាំ 1972 ឆ្នាំ 1976 និង ឆ្នាំ 1980 គណបក្សលោកលី ក្វាន់យូដណ្តើមបានកៅអីទាំងអស់នៅក្នុងសភា ។ នៅក្នុងការបោះឆ្នោតឆ្នាំ 1984 លោកដណ្តើមកៅអីបានតែ 77 ចំណែកកៅអី 2ទៀតត្រូវបានទៅគណបក្សការងារ ។ រហូតមកដល់ដើមឆ្នាំ 1986 មានគណបក្សនយោបាយចំនួន 20ដែលប្រជែងគ្នានៅប្រទេសសិង្ហបុរី ហើយនៅឆ្នាំដែលនេះក៏មានស្ត្រី 3នាក់ក្លាយជាសមាជិកសភា ។

## 2.2. ថ្នាក់ដឹកនាំកំពូលៗ



*លោក លី ក្វាន់យូ*

លោកលី ក្វាន់យូ ជាបញ្ញវន្តមានចំណេះដឹងខ្ពស់ ធ្លាប់បានសិក្សាផ្នែកច្បាប់នៅអង់គ្លេស និងជាអ្នកនយោបាយប្រកបទៅដោយឆន្ទៈ តស៊ូស្វិតស្វាញ និងមានការលះបង់ខ្ពស់ ។ លី ក្វាន់យូ អាចបង្រួបបង្រួមអ្នកឯកទេស បញ្ញវន្តដែលមានទស្សនៈដូចគ្នាធ្វើការតស៊ូដើម្បីឯករាជ្យ ។ ក្រោយមក សម្រេចទិសដៅទំនើបកម្មសង្គមសិង្ហបុរី ។ កេរ្តិ៍ឈ្មោះ លី ក្វាន់យូបានលេចត្រដែតឡើងកាន់តែខ្លាំងចាប់ពីឆ្នាំ 1959 នៅពេលដែលគាត់ដឹកនាំរដ្ឋាភិបាល "រដ្ឋស្វ័យភាព" សិង្ហបុរី ធ្វើការអភិវឌ្ឍជាតិយ៉ាងសកម្មដើម្បីការរីកចម្រើននៃប្រទេស ។

ទោះបីមធ្យោបាយដឹកនាំមានលក្ខណៈតឹងរ៉ឹងខ្លាំងនៅពេលខ្លះយ៉ាងណាក្តី ប្រជាជនសិង្ហបុរីបានផ្តល់សំឡេងទុកចិត្តទៅលើលោកចំនួន 8 លើក ។ ថ្ងៃទី 28 ខែវិច្ឆិកា ឆ្នាំ 1990 លោក លី ក្វាន់យូ បានចេញពីតំណែងក្រោយពីបានកាន់តំណែងនាយករដ្ឋមន្ត្រីរយៈពេល 31 ឆ្នាំមកដោយបន្សល់ទុកកេរ្តិ៍ឈ្មោះរបស់លោកក្នុងនាមជានាយករដ្ឋមន្ត្រីរៀមច្បងនៅក្នុងប្រទេសសិង្ហបុរី ។

លោក ហ្គោជុកតុង បានចូលកាន់កាប់តំណែងនាយករដ្ឋមន្ត្រីដែលជាតំណែងក្រុមមេដឹកនាំបក្សជំនាន់ទី 2 ។ ការចូលកាន់អំណាចរបស់លោកបានប្រព្រឹត្តទៅដោយសន្សឹមៗ និងតាមគម្រោងច្បាស់លាស់ ដើម្បីបញ្ចៀសការប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងអំណាចដែលមានរួចហើយ ។ ហ្គោជុកតុងកើតនៅថ្ងៃទី 20 ខែឧសភា 1941 ក្នុងគ្រួសារចិនក្រីក្រមួយ ។ លោកបានសិក្សានៅសកលវិទ្យាល័យសិង្ហបុរីផ្នែកសេដ្ឋកិច្ច រួចបន្តការសិក្សានៅសហរដ្ឋអាមេរិក ។ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតវិទ្យាសាស្ត្រសង្គមនៅលើវិស័យសេដ្ឋកិច្ច ។ ពេលត្រឡប់មកដល់សិង្ហបុរីវិញ លោក ហ្គោ ជុកតុង ធ្វើការងារជាអ្នកឯកទេសសេដ្ឋកិច្ច ដែលក្រោយមកមានតំណែងជានាយកក្រុមហ៊ុននាវាចរដ្ឋ ។ គ្រាន់តែក្នុងរយៈពេលមួយយ៉ាងខ្លី គាត់អាចប្រែក្លាយក្រុមហ៊ុនដែលធ្លាប់តែខាតបង់ជានិច្ចនោះ ឱ្យទៅជាក្រុមហ៊ុនមួយនាំប្រាក់ចំណូលច្រើនសន្ធឹកសន្ធាប់ទៅវិញនៅចន្លោះឆ្នាំ 1977 ដល់ឆ្នាំ 1979 ។ ជ័យជំនះនេះបានក្លាយជាចំណុចចាប់ផ្តើមមួយយ៉ាងល្អសម្រាប់លោកក្នុងការបើកផ្លូវទៅកាន់អំណាចកំពូលនៅក្នុងប្រទេស ។ នៅក្នុងឆ្នាំ 1976 លោកត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រីទី 1 និងជារដ្ឋមន្ត្រីក្រសួងការពារជាតិសិង្ហបុរី ។

តាមសំណើរបស់លោក លី ក្វាន់យូ នាថ្ងៃទី 3 ខែធ្នូ ឆ្នាំ 1992 គេបោះឆ្នោតផ្តល់សំឡេងជាឯកច្ឆន្ទទៅឱ្យលោក ហ្គោជុក តុង ក្នុងតំណែងជាអគ្គលេខាគណបក្សសកម្មភាពប្រជាជនដែលជាតំណែងមួយយ៉ាងសំខាន់ និងដ៏មានឥទ្ធិពលនៅក្នុងគណបក្សនេះ និងនៅក្នុងប្រទេសទាំងមូល ។

# 3. ស្ថានភាពសេដ្ឋកិច្ច

## 3.1. វិស័យកសិកម្ម

ទោះបីជាផ្ទៃដីកសិកម្មមានទំហំតូចចង្អៀតក៏ដោយ ក៏ប្រទេសសិង្ហបុរីអាចរកប្រាក់ចំណូលក្នុងវិស័យនេះបាន 576 លានដុល្លារនៅឆ្នាំ 1985 ។ បន្លែស្រស់មានទិន្នផលខ្ពស់រហូតដល់ 28150 តោននៅក្នុងឆ្នាំ 1985 ស្មើនឹង 15% នៃតម្រូវការក្នុងស្រុក ។ ប្រទេសសិង្ហបុរីអាចផ្គត់ផ្គង់សាច់ដោយខ្លួនឯងព្រោះប្រជាជនពូកែចិញ្ចឹមសត្វជ្រូក និងបក្សីដែលផ្តល់ស៊ុតបានច្រើន ។ នៅឆ្នាំ 1985 សិង្ហបុរីទទួលផលនេសាទត្រីបានចំនួន 22702 តោន ត្រូវនឹង 25% នៃតម្រូវការក្នុងស្រុក ។ ប្រទេសម៉ាឡេស៊ី និងឥណ្ឌូណេស៊ីជាអ្នកលក់ឈើធំជាងគេឱ្យទៅសិង្ហបុរី ហើយសិង្ហបុរីក៏បានលក់ឈើកែច្នៃទៅវិញមានតម្លៃសរុបប្រហែល 2200 លានដុល្លារ ។

## ១.២. វិស័យថាមពល និងឧស្សាហកម្ម

ប្រទេសសិង្ហបុរីមានឧស្សាហកម្មផ្នែកអេឡិចត្រូនិក និងគីមីដែលមានទុនវិនិយោគចំនួន 4.2 ពាន់លានដុល្លារអាមេរិក ។ ថាមពលអគ្គិសនីដែលដើរដោយប្រេងមានចំនួន 2.6 លានគីឡូវ៉ាត់នៅឆ្នាំ 1974 និងកើនឡើងដល់ 3.9 លានគីឡូវ៉ាត់ក្នុងឆ្នាំ1985 ។ ប្រេងសិង្ហបុរីជាប់ចំណាត់ថ្នាក់ទី 3 បន្ទាប់ពីជប៉ុន និងចិន គេមានរោងចក្រចម្រាញ់ប្រេងដែលអាចផលិតប្រេងគ្រប់មុខចំនួន 652000 ធុងក្នុង 1 ថ្ងៃ នៅឆ្នាំ 1985 ។

## ១.៣. វិស័យទេសចរណ៍

ពួកអ្នកទេសចរបរទេសដែលចូលទស្សនាប្រទេសសិង្ហបុរី មានចំនួនកាន់តែកើនឡើងជាលំដាប់ ។ បើគិតក្នុងឆ្នាំ 1985 មានទេសចរចំនួន 3 030 970 នាក់ ។ ឆ្នាំ 1981 មានទេសចរត្រឹមតែ 2 828 622 នាក់ ។ ឆ្នាំ 1984 ប្រាក់ដែលបានមកពីវិស័យទេសចរណ៍មានចំនួន 4 249.8 លានដុល្លារសិង្ហបុរី ។ ឆ្នាំ 1985 សិង្ហបុរីមានសណ្ឋាគារចំនួន 59 ដែលមានបន្ទប់ទាំងអស់ចំនួន 19 450 ។



ក្រុងសិង្ហបុរី

## ១.៤. វិស័យពាណិជ្ជកម្ម

ប្រទេសដែលជាដៃគូពាណិជ្ជកម្មរបស់សិង្ហបុរីមានប្រទេសក្នុងសមាគមអាស៊ាន សហរដ្ឋអាមេរិក ហុងកុង ជប៉ុន អាល្លឺម៉ង់ អង់គ្លេស អូស្ត្រាលី តៃវ៉ាន់ និងប្រទេសអារ៉ាប៊ីសាអូឌីត ។ ទោះបីជាការនាំចូលលើសចំនួនពីការនាំចេញក៏ដោយ ក៏សេដ្ឋកិច្ចសិង្ហបុរីមានលំនឹង ដោយសារប្រាក់ចំណូលដែលបានមកពីវិស័យទេសចរណ៍ ការផ្ទេរទំនិញនៅក្នុងកំពង់ផែសិង្ហបុរី ហិបប្រាក់ធានារ៉ាប់រងសង្គម និងវិនិយោគទុនក្រៅប្រទេស ។

## ? សំណួរ

1. តើសិង្ហបុរីមានទីតាំងនៅឯណា ? បានទទួលឯករាជ្យនៅឆ្នាំណា ? ដោយសារអ្វី ?
2. តើមេដឹកនាំកំពូលៗនៅសិង្ហបុរីមាននរណាខ្លះ ? ហើយដឹកនាំនៅពេលណាខ្លះ ? ដូចម្តេចដែរ ?
3. តើប្អូនៗចង់ក្លាយជាមេដឹកនាំល្អៗដែរឬទេ ? ព្រោះអ្វី ?
4. ហេតុដូចម្តេចបានជាសេដ្ឋកិច្ចសិង្ហបុរីមានការរីកចម្រើននៅក្រោយពេលបានឯករាជ្យ ?

# 4 ប្រទេសថៃ

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ព្រឹត្តិការណ៍ និងរដ្ឋប្រហាររបស់ថៃ
- វិភាគពីមូលហេតុនៃរដ្ឋប្រហាររបស់ថៃ
- អប់រំស្មារតីឱ្យស្ងប់ ចេះដោះស្រាយបញ្ហាដោយបញ្ចៀសអំពើហិង្សា ។

តាមប្រវត្តិសាស្ត្រប្រទេសសៀមចែកជាបួនសម័យកាលគឺ

- សម័យសុខោទ័យ(1238-1350) សៀមបានវាយដណ្តើមយកខេត្តសុខោទ័យពីខ្មែរ និងបង្កើតរដ្ឋសៀមដោយស្តេចរាមាកំហែង ។
- សម័យអយុធ្យា (1350-1767) សៀមបានពង្រីកទឹកដីមកលើចក្រភពខ្មែរ និងត្រួតត្រាតាមដងទន្លេមេណាម ។ នៅឆ្នាំ 1767 ស្តេចភូមាបាយិនណោងវាយក្រុងអយុធ្យាខ្ទេចខ្ទីអស់ ។
- សម័យធនបុរី (1767-1800) ព្រះចៅតាក់ស៊ីន រំដោះក្រុងអយុធ្យាពីភូមា រួចលើករាជធានីមកតាំងនៅធនបុរីឆ្នាំ 1767 តែព្រះចៅតាក់ស៊ីនលោភលន់អំណាច ត្រូវព្រះចៅយ៉តហ្វា(រាមាទី 1) នៃរាជ្យវង្សចក្រីកាត់ទោសប្រហារជីវិត ។
- សម័យក្រុងបាងកក (1800 - សព្វថ្ងៃ) ព្រះចៅរាមាទី 1 នៃរាជ្យវង្សចក្រី បានឡើងសោយរាជ្យបន្តរហូតមកដល់សព្វថ្ងៃ ។

## 1. រដ្ឋប្រហារ និងការប្តូរឈ្មោះពីសៀមទៅថៃឡង់ឆ្នាំ 1932

ប្រទេសសៀមក្នុងរជ្ជកាលស្តេចប្រាយ៉ាហិប៉ុក (កូនទី 7 របស់ស្តេចជូឡាឡុងកន) បានឡើងសោយរាជ្យសម្បត្តិ ប្រទេសជាតិបានជួបប្រទះវិបត្តិហិរញ្ញវត្ថុ ។ នៅឆ្នាំ 1930 ថវិកាចំណូលរបស់ជាតិមានកង្វះខាត ការចំណាយរបស់រាជរដ្ឋាភិបាលត្រូវកាត់បន្ថយ ។ ព្រះអង្គគិតថា ការលើកតម្កើងគំនិតជាតិនិយមជាអាវុធមុខពីរ អាចនឹងស្តារសេដ្ឋកិច្ចឱ្យរីកចម្រើន និងផលប៉ះពាល់ដល់រាជបល្ល័ង្ក ។

នៅថ្ងៃទី 24 ខែមិថុនា ឆ្នាំ 1932 ជនបង្កប់នៅក្នុងជួរយោធា និងការិយាល័យជាន់ខ្ពស់បានក្រោកឈរឡើងធ្វើរដ្ឋប្រហារលើរបបរាជានិយមផ្តាច់ការ ដោយគ្មានការបង្ហូរឈាម ។ ព្រះចៅប្រាយ៉ាហិប៉ុក បានបង្ខំចិត្តទទួលយករដ្ឋធម្មនុញ្ញថ្មី និងបានប្តូរឈ្មោះប្រទេសជារាជាណាចក្រថៃឡង់ ។

ក្រោយរដ្ឋប្រហារ គេបានកែលម្អរចនាសម្ព័ន្ធសង្គមស៊ីវិលនិងយោធាដោយទទួលយកលទ្ធិប្រជាធិបតេយ្យតាមរយៈធ្វើការតែងតាំង និងជ្រើសរើសសមាជិកសភាជាតិថ្មី ។ ទោះបីជាយ៉ាងណាក៏ដោយ នៅចុងឆ្នាំ 1932 រដ្ឋសភាត្រូវបានបង្កើត ប៉ុន្តែពុំសូវមានលក្ខណៈច្បាស់លាស់ ឬជាក់លាក់ឡើយ ។ នៅឆ្នាំ 1935 ព្រះចៅអាណាន់ដា (រាមាទី 7)បានឡើងសោយរាជ្យរហូតដល់ឆ្នាំ 1945 ។



ព្រះចៅភូមិពលអតុល្យតេជ

នៅខែធ្នូ ឆ្នាំ 1945 ប្រទេសជាតិមានសភាពច្របូកច្របល់ស្រប ពេលដែលកងទ័ពជប៉ុនត្រូវដកចេញពីប្រទេសថៃផង ។ នៅខែមិថុនា ឆ្នាំ 1946 ព្រះចៅអាណាន់ដាសោយទិវង្គតដោយអាថ៌កំបាំង ។ នាយករដ្ឋមន្ត្រីថៃឈ្មោះព្រីឌីផានុមយ៉ង (Pridi Phanomyong) ដ៏ល្បីល្បាញតាំងពីអំឡុងឆ្នាំ 1932 បានសុំលាលែងពីតំណែងនៅខែមេសា ឆ្នាំ 1948 នាយករដ្ឋមន្ត្រីថ្មីឈ្មោះវិបុលសង្គ្រាមឡើងជំនួស ។ រីឯព្រះមហាក្សត្រថៃប្តូរមកព្រះចៅភូមិពលអតុល្យតេជ រហូតមកដល់សព្វថ្ងៃ ។

## 2. រដ្ឋប្រហារយោធាផ្តាច់ការឆ្នាំ 1992

នៅឆ្នាំ 1988 ឧត្តមសេនីយ៍ ប្រេមទីនស៊ូឡាណុនដា (Prem Tinsulanonda) បានចូលនិវត្តន៍ ។ លោកប្រេមបានគ្រប់គ្រងរដ្ឋាភិបាលយោធាថៃ តាំងពីឆ្នាំ 1979 ក្រោយពីឈ្នះឧត្តមសេនីយ៍គ្រាងសាក់ជូម៉ាណាន់ ។ ប៉ុន្តែក្នុងពេលកាន់អំណាច ឧត្តមសេនីយ៍ប្រេម ត្រូវបានពួកយោធាធ្វើរដ្ឋប្រហារផ្តួលរំលំលោកពីរលើកគឺ លើកទី 1 ឆ្នាំ 1981 និងលើកទី 2 នៅឆ្នាំ 1985 ប៉ុន្តែមិនបានសម្រេច ។ នៅឆ្នាំ 1988 ដោយមានការបោះឆ្នោតជ្រើសរើសនាយករដ្ឋមន្ត្រីនៅប្រទេសថៃ ប្រជាជនបានជ្រើសរើសលោកឆាតឆៃឈុនហាវ៉ាន់ (Chatchai Choonhavan) ជានាយករដ្ឋមន្ត្រី ព្រោះលោកជាមេដឹកនាំបង្រួបបង្រួមជាតិ និងបានលើកឡើងនូវនយោបាយស៊ីវិល និងផលប្រយោជន៍ក្នុងការធ្វើជំនួញ ។ លោក ឆាតឆៃ បានលើកទឹកចិត្តដល់អ្នកជំនួញធ្វើឱ្យសេដ្ឋកិច្ចថៃមានការរីកចម្រើន និងធ្វើឱ្យប្រជាជនថៃមានការគាំទ្រលោកច្រើន ។ ប៉ុន្តែពួកយោធានិយមសន្សំចិត្តធ្វើរដ្ឋប្រហារ និងធ្វើការផ្សព្វផ្សាយដល់ប្រជាជនថៃនូវចំណុចខ្សោយរបស់រដ្ឋាភិបាល ឆាតឆៃ គឺអំពើពុករលួយ ។

នៅខែមករា ឆ្នាំ 1991 ប្រជាជនថៃបានរៀបចំធ្វើរដ្ឋប្រហារដើម្បីផ្តួលរំលំរដ្ឋាភិបាលរបស់លោក ឆាតឆៃ ព្រមទាំងរដ្ឋសភា និងរដ្ឋធម្មនុញ្ញ ។ នៅពីក្រោយខ្នងរដ្ឋប្រហារមានពួកយោធាជើងគោក ជើងទឹក និងជើងអាកាស ពិសេសមានឧត្តមសេនីយ៍ សុចិន្តាក្រាប្រាយុទ្ធ (Suchinda Kra-prayoodh) ។ ក្រុមរដ្ឋប្រហារនេះបានប្រកាសឈ្មោះហៅថា (ក្រុមប្រឹក្សារក្សាសន្តិភាពជាតិ) មានតួនាទីរៀបចំវិធីសាស្ត្រថ្មីក្នុងការអភិវឌ្ឍប្រទេសជាតិ និងលទ្ធិប្រជាធិបតេយ្យ ។ រដ្ឋាភិបាលស្តីទីថ្មី បានកើតឡើងដោយមានលោក អាណាន់ ប៉ាន់យ៉ាជុន (Anad Panyachun) ជានាយករដ្ឋមន្ត្រីស្តីទី ។

ប្រទេសថៃហាក់បីដូចជាមានការស្ដាយក្រោយចំពោះរដ្ឋប្រហារឆ្នាំ 1991 រីឯអ្នកដឹកនាំក្រុមប្រឹក្សាសន្តិភាពជាតិមានសិទ្ធិបញ្ជាទៅស្ថាប័នថ្នាក់ក្រោម ។ ការបោះឆ្នោតឆ្នាំ 1992 ប្រជាជនថៃពុំមានសិទ្ធិខ្វល់ខ្វាយក្នុងការជ្រើសរើសមនុស្សដែលពួកគេពេញចិត្ត ។ នៅថ្ងៃទី 20 ខែមីនា ឆ្នាំ 1992 បាតុករជាច្រើនបានមកជួបជុំគ្នានៅទីក្រុងបាងកក ក្រោមការដឹកនាំរបស់តាបសឈ្មោះ ចំឡង ស្រីមឿង (Chanlong Srimuang) និងអតីតនាយទាហានរដ្ឋាភិបាល ។ ប្រជាជនថៃបានគាំទ្រតាមសគ្រប់ខេត្តក្រុង ។

នៅថ្ងៃទី 17-20 ខែមីនា ឆ្នាំ 1992 ឧត្តមសេនីយ៍ សុចិន្តា បានបញ្ជាឱ្យទាហានបាញ់រះទៅលើហ្វូងបាតុករ ធ្វើឱ្យបាតុករ 50 នាក់ស្លាប់ និងរងរបួសប្រហែល 300 នាក់ ។ នៅថ្ងៃទី 20 ខែមីនា ព្រះចៅភូមិពល បានប្រកាសឱ្យបញ្ឈប់សង្គ្រាមភ្លាម ។ ឧត្តមសេនីយ៍សុចិន្តាត្រូវដកចេញពីតំណែង និងតែងតាំងឧត្តមសេនីយ៍ អាណាន់ ជានាយករដ្ឋមន្ត្រី ហើយរៀបចំរដ្ឋធម្មនុញ្ញថ្មីនៅខែកញ្ញា ឆ្នាំ 1992 ។

## 3. វិបត្តិនយោបាយឆ្នាំ 2006-2010

នៅឆ្នាំ 2006 នាយករដ្ឋមន្ត្រីថៃ តាក់ស៊ិន ស៊ីណាវ៉ាត់ត្រា (Takshin Sinavatra) ត្រូវបានគេចោទប្រកាន់ពីបទអំពើពុករលួយជាមួយប្រទេសជិតខាងដូចជា កម្ពុជា មីយ៉ាន់ម៉ា សិង្ហបុរី ... ។ ស្តុកសាជីវកម្មស៊ិន(Shin Corporstion Stock)បានលក់ឱ្យរដ្ឋាភិបាលសិង្ហបុរី ដោយរួចពន្ធចំនួន 73 លានបាត (188 លានដុល្លារ)ជាការថ្លែងអំណរគុណចំពោះច្បាប់អនុគ្រោះពន្ធខ្វះគមនាគមន៍ប្រទេសសង្ហបុរី ។

បញ្ហាទាំងអស់នេះ និងពាក្យបណ្តឹងផ្សេងៗទៀតដែលបានដាក់ជូនរដ្ឋសភា ព្រះមហាក្សត្រ និងការរិះគន់របស់ឧត្តមសេនីយ៍ សុនធីប៊ុនយ៉ារ៉ាត់គ្លីន (Sonthi Boonyaratglin) ត្រូវបានធ្វើឡើងដើម្បីទទួលបានប្រជាប្រិយភាពក្នុងការប្រឆាំងនឹងលោកតាក់ស៊ិន ។ លោក តាក់ ស៊ិន បានអំពាវនាវឱ្យធ្វើការបោះឆ្នោតភ្លាមតែត្រូវរារាំងដោយពួកលទ្ធិប្រជាធិបតេយ្យ(ធ្វើពហិការមិនចូលរួម) ហើយលទ្ធផលបោះឆ្នោតក្នុងសភាជាប់លោកតាក់ស៊ិន តែគេចាត់ទុកជាមោឃៈជាបន្តបន្ទាប់ ។

នៅខែមិថុនា ឆ្នាំ 2006 ជាការរំលឹកខួបកំណើតលើកទី 60 ឆ្នាំ នៃការឡើងគ្រងរាជ្យរបស់ស្ដេចថៃភូមិពល អតុល្យតេជ តែត្រូវរំខានដោយវិបត្តិនយោបាយជាច្រើនលើកច្រើនសា ។

នៅថ្ងៃទី 19 ខែសីហា ឆ្នាំ 2006 លោកឧត្តមសេនីយ៍សុនធី ប៊ុនយ៉ារ៉ាត់គ្លីន បានដឹកនាំរដ្ឋប្រហារយោធាមួយគ្មានការបង្ហូរឈាម ទម្លាក់លោកតាក់ស៊ិនពីនាយករដ្ឋមន្ត្រី និងនិរទេសខ្លួនលោកទៅបរទេស ។ ក្រោយរដ្ឋប្រហារ គេបានតែងតាំងឧត្តមសេនីយ៍ចូលនិវត្តន៍ សារាយុទ្ធ ជូឡាណុន (Sarayud Chulanont) ជានាយករដ្ឋមន្ត្រីស្តីទី ។ ក្រោយមក តុលាការធម្មនុញ្ញបានចោទប្រកាន់ និងសម្រេចថាគណបក្សថៃរ៉ាក់ថៃ (TRT) បានបន្លំសន្លឹកឆ្នោត ហើយត្រូវរំលាយ និងបញ្ឈប់សមាជិក

សភាចំនួន 111 នាក់របស់គណបក្សនេះ ពីសភារយៈពេល 5 ឆ្នាំ ។ រដ្ឋធម្មនុញ្ញថ្មីរបស់ថៃនាពេលនោះត្រូវបានអនុម័តដោយប្រជាមតិភាគតិច ។

នៅខែមករា ឆ្នាំ 2008 គណបក្សអំណាចប្រជាជន (PPP) របស់លោកតាក់ស៊ីន បានទទួលជ័យជំនះដោយសំឡេងភាគច្រើនក្នុងសភា ហើយបានបង្កើតរដ្ឋាភិបាលថៃដែលដឹកនាំដោយលោក សាម៉ាក់ ស៊ុនដារ៉ាវេជ (Samak Sundaravej) មកពីគណបក្ស PPP ។ ប៉ុន្តែ សភាថៃមិនព្រមទទួលយក ។ ក្នុងឆ្នាំនេះដដែលប្រទេសថៃបានប្រឈមនឹងវិបត្តិនយោបាយ និងទំនាស់ជាច្រើនដូចជា ការរំជើបរំជួលនៅខេត្តភាគខាងត្បូងមាន ណារ៉ាត់ធីវ៉ាត់ ប៉ាត់ថានី យ៉ាឡា សុងខ្លា ... និងទំនាស់ជាមួយប្រទេសជិតខាងមានឡាវ មីយ៉ាន់ម៉ា ម៉ាឡេស៊ី និងកម្ពុជា ។

ក្រោយពីអង្គការយូណេស្កូ (UNESCO) ដាក់បញ្ចូលប្រាសាទព្រះវិហារខ្មែរ ជាបេតិកភណ្ឌពិភពលោក នៅទីក្រុងកេបិចប្រទេសកាណាដាកាលពីថ្ងៃទី 7 ខែកក្កដា ឆ្នាំ 2008 មក ទាហានឈុតខ្មៅថៃបានចូលឈ្លានពានប្រទេសកម្ពុជាជាច្រើនលើកច្រើនសា ដែលក្នុងនោះមានការប៉ះទង្គិចដោយអាវុធធុនធ្ងន់ទ្រាយធំ 3 លើកគឺលើកទី 1 នៅថ្ងៃទី 15 ខែកក្កដា ឆ្នាំ 2008 លើកទី 2 នៅថ្ងៃទី 15 ខែតុលា ឆ្នាំ 2008 លើកទី 3 នៅថ្ងៃទី 3 ខែមេសា ឆ្នាំ 2009 ។

## ? សំណួរ

1. តើប្រទេសសៀមបានប្តូរឈ្មោះមកជា ថៃឡង់ដ៍នៅឆ្នាំណា ? ដោយសារអ្វី ?
2. តើប្រទេសថៃមានរដ្ឋប្រហារធំៗប៉ុន្មានលើក ?
3. តើមូលហេតុអ្វីបានកើតមានវិបត្តិនយោបាយនៅក្នុងប្រទេសថៃពីឆ្នាំ 2006-2010 ?

# 5 ប្រទេសវៀតណាម

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់សង្គមវៀតណាមក្នុងសម័យអាណានិគមនិយមបារាំង និងចក្រពត្តិនិយមអាមេរិក
- រកមូលហេតុនៃការកសាងប្រទេសជាតិឱ្យរីកចម្រើន
- កោតសរសើរស្មារតីជាតិនិយមរបស់ប្រជាជនវៀតណាម ។

បើយើងនិយាយពីបដិវត្តន៍រំដោះជាតិវៀតណាម គេគិតដល់វីរភាពអង់អាចក្លាហានរបស់លោកហូ ជីមិញ ។ លោក ហូ ជីមិញ កើតនៅថ្ងៃទី 19 ខែឧសភា ឆ្នាំ 1890 ឃុំគីមលៀន ស្រុកណាមដាន ខេត្តងេទិញ(វៀតណាមខាងជើង) ។ ឈ្មោះកំណើតរបស់លោកគឺ ង្វៀន តឹតថាញ់ ពេលធ្វើបដិវត្តន៍ដូរឈ្មោះជា ង្វៀន អាយក្វុក ។ អាយុបាន 15ឆ្នាំ ចូលធ្វើការសម្ងាត់បម្រើតុបាយ ។ នៅឆ្នាំ 1920 ចូលបម្រើក្នុងបក្សកុម្មុយនីស្តបារាំង ។ នៅឆ្នាំ 1923 លោក ហូ ជីមិញ ចេញពីស្រុកបារាំងទៅសហភាពសូវៀត ។ នៅថ្ងៃទី 3 ខែកុម្ភៈ ឆ្នាំ 1930 លោកជាប្រធានបក្សកុម្មុយនីស្តឥណ្ឌូចិន(កម្ពុជា វៀតណាម ឡាវ) ។ នៅឆ្នាំ 1945 លោកបានប្រកាសឯករាជ្យឱ្យប្រទេសវៀតណាមពីអាណានិគមបារាំង ។ នៅឆ្នាំ 1954 លោក ហូ ជីមិញ បានដឹកនាំទ័ពវៀតណាមវាយបន្ទាយឌៀនបៀនភូរបស់បារាំងរហូតបារាំងទទួលបរាជ័យ ។ នៅឆ្នាំ 1954 បារាំងព្រមប្រគល់ឯករាជ្យឱ្យប្រទេសវៀតណាម ។ នៅថ្ងៃទី 3 ខែកញ្ញា ឆ្នាំ 1969 លោក ហូ ជីមិញ ស្លាប់ដោយជំងឺ ។ សព្វថ្ងៃសពរបស់លោកតាំងនៅក្នុងមឈ្ឈូសកញ្ចក់នាទីក្រុងហាណូយ ។



*លោក ហូ ជីមិញ*



*សាកសពលោក ហូ ជីមិញ*

# 1. អាណានិគមនិយមបារាំង

## 1.1. ការមកដល់នៃអាណានិគមនិយមបារាំង

ក្រុមអ្នកផ្សព្វផ្សាយសាសនារបស់ខ្ចួតបារាំង បានធ្វើសកម្មភាពនៅក្នុងប្រទេសវៀតណាមតាំងពីពាក់កណ្តាលសតវត្សទី 17មកម្ល៉េះ ។ ក្រុមនេះបានជួយអធិរាជយ៉ាឡុង (1802-1820)កម្ចាត់ពួកបះបោរតៃសឺន ។ រាជរដ្ឋាភិបាលវៀតណាមតែងប្រុងប្រយ័ត្នចំពោះការហូរចូលនៃសាសនាផ្សេងៗ ហើយធ្លាប់ប្រឆាំងយ៉ាងខ្លាំងក្លានឹងសាសនាកាតូលិក រហូតដល់មានការធ្វើទារុណកម្មទៅលើបព្វជិតសាសនាគ្រិស្តដែលនាំឱ្យបារាំងធ្វើអន្តរាគមន៍ចូលក្នុងប្រទេសវៀតណាមដើម្បីជាលេសក្នុងការការពារជនរងគ្រោះនៅឆ្នាំ 1859 ។ លុះមកដល់ឆ្នាំ 1885 ប្រទេសវៀតណាមធ្លាក់នៅក្រោមការត្រួតត្រារបស់បារាំង ។

## 1.2. ការប្រកាសឯករាជ្យពីបារាំង

លោក ហូ ជីមិញជាមេដឹកនាំចលនាតស៊ូរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន និងជាប្រធានកុម្មុយនីស្តវៀតណាមបានតស៊ូប្រឆាំងនឹងពួកអាណានិគមនិយមបារាំង និងជប៉ុនដើម្បីឯករាជ្យជាតិ ។

នៅថ្ងៃទី 2 ខែសីហា ឆ្នាំ 1945 ហូ ជីមិញបានប្រកាសឯករាជ្យនៅកណ្តាលទីលាន បាឌិញ (Ba Dinh Square) ក្នុងទីក្រុងហាណូយ ។ នៅខែកញ្ញា ឆ្នាំ 1945 ជប៉ុនចុះចាញ់សង្គ្រាមលោកលើកទី 2 បារាំងបានវិលមកត្រួតត្រាប្រទេសវៀតណាមម្តងទៀត ។

សមរភូមិឌៀនបៀនភូ (Dien Bien Phu) ជាសមរភូមិក្តៅអស់រយៈពេលជាង 8ឆ្នាំ កងទ័ព និងប្រជាជនវៀតណាមបានធ្វើការប្រយុទ្ធប្រឆាំងនឹងអាណានិគមបារាំង ។ បន្ទាប់ពីកម្លាំងវៀតណាមព័ទ្ធបន្ទាយបារាំងអស់រយៈពេល 57ថ្ងៃ ធ្វើឱ្យកងទ័ពបារាំងជាង 1ម៉ឺននាក់អត់ស្បៀង ស្ថិតក្នុងភាពទ័លច្រក ។ នៅថ្ងៃទី 7 ខែមិថុនា ឆ្នាំ 1954 បារាំងសុំចុះចាញ់ និងប្រគល់ឯករាជ្យពិតប្រាកដឱ្យប្រទេសវៀតណាម ។

# 2. ដំណាក់កាលសង្គ្រាមប្រឆាំងនឹងសហរដ្ឋអាមេរិក

សង្គ្រាមនៅវៀតណាមជាសង្គ្រាមបង្ហូរឈាមរវាងជនជាតិតែមួយ ក្រោមឥទ្ធិពលនៃសង្គ្រាមត្រជាក់របស់កំពូលមហាអំណាចពិភពលោកទាំង 2 គឺសូវៀត និងសហរដ្ឋអាមេរិក ។ សហរដ្ឋអាមេរិកយល់ថា ត្រូវតែបញ្ឈប់ការជ្រៀតជ្រែកពីសំណាក់វៀតណាមកុម្មុយនីស្តមកតំបន់ភូមិភាគកណ្តាល និងភូមិភាគខាងត្បូង ។

នៅឆ្នាំ 1965 សហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្មវៀតណាមខាងជើងដោយធ្វើការទម្លាក់គ្រាប់បែកយ៉ាងខ្លាំង ។ ប្រតិបត្តិការនេះមានឈ្មោះថា "សម្រែកផ្គរលាន់" ទិសដៅគឺ ចង់កម្ទេចភូមិករទីក្រុងនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមឱ្យទៅជាផេះ ។ សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកទៅលើវៀតណាមខាងជើងមានទំហំធំជាងសម័យសង្គ្រាមលោកលើកទី 2 ។ ដីធ្លីត្រូវផ្ទុះធ្លាយដោយរណ្ដៅគ្រាប់ នេះខ្មោចក្លិនឈ្ងៀមដោយឈាម និងរំសេវ ។ សង្គ្រាមនេះធ្វើឱ្យកងទ័ពវៀតណាមខាងជើងស្លាប់អស់ចំនួន 900 ពាន់នាក់ និង 2 លាននាក់ត្រូវរបួស រួមទាំងប្រជាជនប្រហែល 1 លាននាក់បានបាត់បង់ជីវិត ។ កងទ័ពវៀតណាមខាងត្បូងបាត់បង់ជីវិតចំនួន 250 ពាន់នាក់ របួសចំនួន 600 ពាន់នាក់ និងពិការចំនួន 4 លាននាក់ ។ នៅឆ្នាំ 1975 ទើបសហរដ្ឋអាមេរិកចាញ់សង្គ្រាមនៅឥណ្ឌូចិន ។

ចាប់ពីឆ្នាំ 1975 វៀតណាមរស់នៅដោយត្រូវកាត់ផ្ដាច់ទំនាក់ទំនងពីពិភពខាងក្រៅ មានតែសហភាពសូវៀតប៉ុណ្ណោះដែលជួយដល់វៀតណាម ហើយជំនួយនេះត្រូវកាត់បន្ថយយ៉ាងច្រើនក្រោយឆ្នាំ1985 ។ នៅពាក់កណ្ដាលឆ្នាំ 2000 សហរដ្ឋអាមេរិក និងវៀតណាមបានចុះកិច្ចព្រមព្រៀងបើកផ្លូវធ្វើពាណិជ្ជកម្មជាមួយគ្នាតាមការអនុម័តយល់ព្រមរបស់សហរដ្ឋអាមេរិកនៅឆ្នាំ 2001 ។

## ३. ការកសាងលទ្ធិសង្គមនិយមនៅក្នុងកំណែទម្រង់ ដូយម៉ូយ

ខែធ្នូ ឆ្នាំ 1996 សាធារណរដ្ឋសង្គមនិយមវៀតណាមបានប្រារព្ធបុណ្យខួប 10ឆ្នាំនៃកំណែទម្រង់របស់ខ្លួន ។ អស់រយៈពេល 10ឆ្នាំកន្លងមកដែលបក្សកុម្មុយនីស្តវៀតណាមបានប្រារព្ធមហាសន្និបាតលើកទី 6 ហើយគេបានអនុម័តនូវយុទ្ធសាស្ត្រថ្មីដើម្បីអភិវឌ្ឍសង្គមវៀតណាមឈ្មោះថា "ដូយម៉ូយ" (កំណែទម្រង់នយោបាយ) ។ "ដូយម៉ូយ" កំណត់កម្មវិធីនយោបាយថ្មីគឺ កំណែទម្រង់រ៉ាឌីកាល់ទៅលើរចនាសម្ព័ន្ធសេដ្ឋកិច្ចទាំងស្រុង និងបើកទ្វារផ្ដល់លទ្ធភាពដល់សហគ្រិនធ្វើសកម្មភាពនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចផ្សារសេរី ។ គេបានលើកឡើងកម្មវិធី "ទីផ្សារសេដ្ឋកិច្ច"ដោយពង្រឹងនយោបាយជាតិ និងឈរលើគោលការណ៍នៃបក្សកុម្មុយនីស្តជាបក្សដឹកនាំ បានកសាងទំនាក់ទំនងល្អលើឆាកអន្តរជាតិ និងតំបន់ដើម្បីដឹកនាំប្រទេសចេញឱ្យផុតពីស្ថានភាពហ៊ុមព័ទ្ធ និងទណ្ឌកម្មសេដ្ឋកិច្ចហើយចូលរួមក្នុងសមាហរណកម្មនយោបាយ និងសេដ្ឋកិច្ចលើពិភពលោក ។

## 4. ប្រទេសវៀតណាមបច្ចុប្បន្ន

ក្រោយចាញ់សង្គ្រាមនៅវៀតណាម សហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្មទៅលើប្រទេសនេះ ទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ច ។ ប៉ុន្តែនៅដើមឆ្នាំ 1994 សហរដ្ឋអាមេរិកបានអនុញ្ញាតឱ្យវៀតណាមនាំទំនិញចូលសហរដ្ឋអាមេរិកក៏ដូចជានៅអឺរ៉ុបខាងលិច ។

វៀតណាមក៏បានធ្វើទំនាក់ទំនងការទូតយ៉ាងល្អប្រសើរជាមួយអាមេរិក ។ នៅឆ្នាំ 2000 លោក ប៊ីល គ្លីនតុន ប្រធានាធិបតីសហរដ្ឋអាមេរិកបានមកធ្វើទស្សនកិច្ចនៅវៀតណាមខាងជើងជាលើកទី 1 ដើម្បីរឹតចំណងការទូតឱ្យកាន់តែប្រសើរជាងមុន ។ នៅឆ្នាំ 2006 លោក ចច ប៊ូស ប្រធានាធិបតីសហរដ្ឋអាមេរិកបានមកធ្វើទស្សនកិច្ចដើម្បីបញ្ចូលប្រទេសនេះក្នុងអង្គការពាណិជ្ជកម្មពិភពលោក ។

នៅខែមករា ឆ្នាំ 2007 ប្រទេសវៀតណាមបានចូលជាសមាជិកមិនអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិទៀត ។ ប្រទេសវៀតណាមបានរួមចំណែកក្នុងឆាកអន្តរជាតិយ៉ាងល្អប្រសើរ ។

នៅក្នុងសមាគមអាស៊ាន ប្រទេសវៀតណាមបានធ្វើសកម្មភាពយ៉ាងខ្លាំងក្លាក្នុងការបញ្ចូលប្រទេសឡាវ កម្ពុជា និងមីយ៉ាន់ម៉ាឱ្យចូលជាសមាជិកអាស៊ាន ។ សេដ្ឋកិច្ចរបស់វៀតណាមផ្លាស់ប្តូរប្រកបដោយថាមពលខ្លាំងក្លា និងជោគជ័យទាំងវិស័យកសិកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ។ វៀតណាមបានដើរតាមមាគ៌ាអភិវឌ្ឍរបស់ចិនគឺសេដ្ឋកិច្ចសេរីកុម្មុយនីស្ត នយោបាយសេរីភាវូបនីយកម្ម ជាមួយនេះដែរ មានប្រជាជន 2 លាននាក់ចូលជាសមាជិកបក្សកុម្មុយនីស្ត និង 85 លាននាក់ជាសមាជិកបក្សប្រជាជនវៀតណាម ដូច្នេះវៀតណាមទទួលជោគជ័យទាំងវិស័យនយោបាយ និងវិស័យសេដ្ឋកិច្ចនៅសតវត្សទី 21 នេះ ។

### ? សំណួរ

1. ហេតុដូចម្តេចបានជាកងទ័ពវៀតណាមខាងជើងទទួលបានជ័យជំនះលើកងទ័ពវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក ?
2. ក្រោយសង្គ្រាមឆ្នាំ 1975 សេដ្ឋកិច្ចវៀតណាមត្រូវហ៊ុមព័ទ្ធដោយលោកខាងលិច ព្រោះអ្វី ?
3. តើ "ដូយម៉ឺយ" មានគោលការណ៍ជាមូលដ្ឋានយ៉ាងណាខ្លះ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចវៀតណាម ?
4. តើវៀតណាមបច្ចុប្បន្នមានអ្វីគួរឱ្យកត់សម្គាល់ខ្លះ ?

## ? សំណួរបញ្ចប់ជំពូកទី៣

I. ចូរគូសសញ្ញា ✓ មុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

1. ក្នុងប្រវត្តិសាស្ត្រប្រទេសឥណ្ឌូណេស៊ីនៅក្រោមអាណានិគមប្រទេស ៖

☐ ក. ហូឡង់ និងជប៉ុន ☐ ខ. ព័រទុយហ្គាល់ និងហូឡង់

☐ គ. អេស្ប៉ាញ និងព័រទុយហ្គាល់ ☐ ឃ. អាមេរិក និងបារាំង ។

2. ប្រទេសម៉ាឡេស៊ីជារដ្ឋសហព័ន្ធស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ចែកជា ៖

☐ ក. 3ផ្នែក ☐ ខ. 2ផ្នែក ☐ គ. 4ផ្នែក ☐ ឃ. 5ផ្នែក ។

3. ប្រទេសសិង្ហបុរីក្លាយជារដ្ឋឯករាជ្យមួយនៅឆ្នាំ ៖

☐ ក. 1962 ☐ ខ. 1963 ☐ គ. 1964 ☐ ឃ. 1965 ។

4. ប្រវត្តិសាស្ត្រប្រទេសសៀមចែកចេញជា ៖

☐ ក. 2សម័យកាល ☐ ក. 3សម័យកាល ☐ ក. 4សម័យកាល ☐ ឃ. 5សម័យកាល ។

5. ប្រទេសវៀតណាមធ្លាក់ចូលក្នុងការត្រួតត្រារបស់បារាំងនៅឆ្នាំ ៖

☐ ក. 1870 ☐ ខ. 1880 ☐ គ. 1885 ☐ ឃ. 1890 ។

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. ការធ្វើ ..... ផ្ដាច់មុខរបស់ពួក ..... ធ្វើឱ្យប៉ះពាល់សេដ្ឋកិច្ចនៅប្រជុំកោះឥណ្ឌូណេស៊ីយ៉ាងខ្លាំង ។
2. ប្រទេសម៉ាឡេស៊ីចែកចេញជា2ផ្នែក មួយផ្នែកស្ថិតនៅលើឧបទ្វីប ................ មួយផ្នែកទៀតមានពីររដ្ឋគឺរដ្ឋ ............. និងរដ្ឋ ............... ។
3. ប្រជាជននៃប្រទេសសិង្ហបុរីភាគច្រើនជាជនជាតិ ................ មានចំនួន ...............% ។
4. ថ្នាក់ដឹកនាំកំពូលៗនៃប្រទេសសិង្ហបុរីមានជាអាទិ៍លោក ............ និងលោក .............. ។
5. នៅថ្ងៃទី 24 ខែមិថុនា ឆ្នាំ ... មានការធ្វើរដ្ឋប្រហារដោយគ្មានការបង្ហូរឈាមនៅប្រទេសសៀម ។
6. ក្នុងដំណាក់កាលសង្គ្រាមប្រឆាំងនឹងអាមេរិកនៅវៀតណាមគឺអាមេរិកចង់បញ្ឈប់ការជ្រៀតជ្រែកពីសំណាក់ ........ មកតំបន់ភាគកណ្ដាលនិងភាគ ............ ប៉ុណ្ណោះ ។

III. ចូរឆ្លើយនឹងសំណួរខាងក្រោម

1. តើប្រជុំកោះឥណ្ឌូណេស៊ីមានប៉ុន្មានបែប ? អ្វីខ្លះ ? ហើយរដ្ឋទាំងនេះប្រកបរបរអ្វីខ្លះ ?
2. ប្រទេសម៉ាឡេស៊ីធ្លាប់ស្ថិតនៅក្រោមអាណានិគមប្រទេសណាខ្លះ ? ហើយចុងក្រោយគឺប្រទេសណា ?
3. ចូរប្រៀបធៀបចំនួនប្រជាជនម្ចាស់ស្រុកក្នុងប្រទេសសិង្ហបុរី និងម៉ាឡេស៊ីគិតជាភាគរយ ?
4. តើរដ្ឋប្រហារប្រទេសថៃនៅឆ្នាំ 1932 និងរដ្ឋប្រហារយោធាផ្ដាច់ការ 1991 មានលក្ខណៈខុសគ្នាដូចម្ដេចខ្លះ ?